# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៦ លេខ ២ ខែ កុម្ភៈ

ព. ស. ២៥០៦ គ. ស. ១៩៦៤

- ភ្នំពេញ -

ខ.ទ.៩៥ ៤-៤-៦៤.

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

ផ្នែកសាសនា

- វេរកថា ព្រះសាសនមុនី កឹម–ទូ ក្រុមជំនុំ ព្រះត្រៃបិដក តែងរៀបរៀង . . . ១១១
- ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៉ូ តែងរៀបរៀង (ត) . . . ១២៦
- ព្រះវិធុរជាតក . . . . . . . . . . . . ១៣៤

ផ្នែកអក្សរសាស្ត្រ

- គួរតែប្រទៀះភាសខ្មែរបោល (វិចារណកថា) លោក ផេង-ជ្រីវ និពន្ធ . . . . ១៤៩
- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត) . . . . ១៦១
- រឿងអាប៊ូលហ្វ៉ាអ៊ីរ៉ស លោក ភ៉ាយ-ល្អុត ជំណាងភាស្ត្រ ប្រែរៀបរៀង . . . ១៦៣
- ល្បើកឡាហ្វុងតែន លោក ផេង-ជ្រីវ ប្រែពីភាសាបារាំង (ត) . . . . . ១៧១
- រឿងសាមកុក អ្នកនិពន្ធវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . ១៧៦
- រឿងព្រេងចិន (ការសងសឹកនៃទន្សាយ) លោក ភ៉ាយ-ប៊ុក ប្រែពីភាសាបារាំង (ត) . . ២០៧
- ទំនៀមទម្លាប់ខ្មែរ: លទ្ធផលនៃការប្រឡងទំនៀមទម្លាប់ខ្មែរ ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៣ ២១០

ផ្នែកកំណត់ទីផ្សប្រវត្តិការណ៍

- ប្រវត្តិនៃវត្តប្រាង្គ រៀបរៀង ដោយព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា . . . . . . . . ២១៥
- រឿងតាំងចៅអធិការ និងគ្រូសូត្រក្នុងវត្តនានា ក្នុងព្រះរាជអាណាចក្រ . . . ២២២
- ដំណឹងពីពុទ្ធសាសនបណ្ឌិត្យ . . . . . . . . . ២២៨

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០:០០

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការៈលាមក ឲ្យធ្វើល្អទៅ
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា

ប.៣.

## វេរកថា

*ព្រះសាសនមុនី ឈឹម·ទូ ក្រុមជំនុំព្រះត្រៃបិដក*

*តែងរៀបរៀង*

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ អវេរេន ច សម្មន្តិ ឯសធម្មោ សនន្តនោ ។ *ប្រែថា: ពៀរទាំងឡាយ ក្នុងលោកនេះ មិនដែលរម្ងាប់ដោយពៀរ ក្នុងកាលណាមួយទេ ពៀរទាំង-ឡាយរម្ងាប់បាន ដោយសារតែមិនមានពៀរប៉ុណ្ណោះឯង ធម៌នេះជាបវេណីរបស់អ្នកប្រាជ្ញពីបូរាណ ។*

*រឿងខាងក្រោមនេះ ជា ១ បញ្ជាក់នូវពុទ្ធឧស្សខាងលើ ។*

## ជម្លោះរវាង ក្អែក និង មៀម

*ក្នុងសម័យដែលព្រះពុទ្ធជាបរមគ្រូនៃយើងទាំងឡាយ ទ្រង់បាន ត្រាស់ដឹងឡើងក្នុងលោកហើយ ព្រះអង្គទ្រង់គង់នៅនាវត្តជេតពន ជិត ក្រុងសាវត្ថី ។ ជម្លោះរវាងក្អែកនិងមៀម ចេះតែមានជានិច្ច ជាប់តាំងពីព្រេងនាយមក ជួនកាលក្នុងវេលាថ្ងៃ ក្អែកដេញចឹក*

សម្លាប់មៀម ដល់វេលាយប់ មៀមដេញចឹកសម្លាប់ក្អែកវិញ ពីព្រោះក្អែកមើលមិនឃើញក្នុងពេលយប់ជាងពេលថ្ងៃ ។ ដូចកាលយប់ខ្លះ មៀមចឹកសម្លាប់ក្អែកអស់ជាច្រើន ក្អែកខ្លះដាច់កធ្លាក់ចុះពីចុងឈើមកលើផែនដីត្រង់អាស្រមរបស់ភិក្ខុមួយរូបដែលនៅក្នុងទីបរិវេណជិតព្រៃវត្តជេតពនជាកន្លែងដែលលោកតែងបោសសំអាតជាប្រក្រតី ។ លុះតែព្រឹក ភិក្ខុនោះតែងតែឃើញក្បាលក្អែកដាច់ធ្លាក់ចុះមកក្នុងទីជិតអាស្រមរបស់ខ្លួន ក៏យកហេតុនោះទៅប្រាប់ភិក្ខុទាំងឡាយ ភិក្ខុទាំងនោះនាំរឿងដំណើរនោះទៅក្រាបបង្គំទូលព្រះពុទ្ធជាម្ចាស់ទៀត ទើបព្រះអង្គទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ក្អែក និង មៀម នោះ ដែលកើតហេតុឈ្លោះតាស់តែងនិងគ្នា មិនមែនទើបតែនឹងមានក្នុងកាលឥឡូវនេះទេ គឺមានតាំងតែពីដើមមកជាយូរអង្វែងណាស់មកហើយ ។ ភិក្ខុទាំងឡាយ ក្រាបទូលសួរថា ចុះ ក្អែក និង មៀម ដែលមានពៀរនឹងគ្នាយ៉ាងនេះ កើតកើតមានតាំងពីកាលណាមក ព្រះអង្គ? ព្រះសម្ពុទ្ធទ្រង់សម្តែងប្រាប់ភិក្ខុទាំងឡាយនោះថា :

រឿងរ៉ាវពៀរក្អែក និង មៀម នេះ មានតាំងពីបឋមកប្បដែលទើបនឹងកើតផែនដីឡើងជាដំបូង កាលបើផែនដីកើតឡើងហើយ ឯពួកមនុស្ស និង ពួកសត្វ ក៏កើតមានឡើងដែរ ។ សម័យនោះ ទាំងមនុស្សទាំងសត្វខ្ទុំ- ទៅមានឋានៈស្មើ ៗ គ្នា គេមិនទាន់តាំងនរណាមួយឲ្យជាអ្នកមានឥស្សរ

ភាពសម្រាប់ត្រួតត្រាមើលការខុសត្រូវដល់គ្នានឹងគ្នា នៅឡើយទេ ម្ល៉ោះហើយ មនុស្សនិងសត្វទាំងនោះ កាលបើមានកិលេសគឺលោភៈ ទោសៈ មោហៈ កើតចំរើនឡើងហើយ ក៏ចេះតែមានការរំលោភឈ្លានពានបៀតបៀនគ្នាទៅវិញទៅមក ។ កាលជាខាងក្រោយមក ពួកមនុស្សបានប្រជុំពិភាក្សាគ្នាថា យើងគួរតែជ្រើសរើសនរណាម្នាក់ដែលមានរូបសម្បត្តិសមរម្យ មានប្រាជ្ញាឈ្លាសវៃ ព្រមទាំងមានចរិយា ឫកពា សណ្ដាប់ធ្នាប់ល្អ គួរជាទីពេញចិត្តនៃជនទាំងពួងឲ្យធ្វើជាធំ (ស្ដេច) សម្រាប់ត្រួតត្រាមើលការខុសត្រូវរបស់មនុស្សទាំងឡាយទូទៅ លុះប្រឹក្សាព្រមព្រៀងគ្នាហើយ ក៏លើកបុរសម្នាក់ដែលគេយល់ថា មានលក្ខណៈសមរម្យឲ្យធ្វើជាស្ដេចឡើង ហើយថ្វាយព្រះនាមថា ព្រះបាទសម្មតរាជ (ស្ដេចកើតឡើងដោយប្រជាជនសន្មត) មានតាំងពីកាលនោះមក ។

ចំណែកខាងពួកសត្វចតុប្បាទ (សត្វជើង ៤) បានប្រជុំប្រឹក្សាគ្នារើសរកសត្វឲ្យធ្វើជាស្ដេច លុះប្រឹក្សាគ្នាទៅឃើញថា សត្វសីហៈ ជាសត្វសមរម្យមានឥទ្ធិពលខ្លាំងពូកែលើសសត្វទាំងឡាយឯទៀត អាចនឹងត្រួតត្រាលើសត្វដទៃបាន ក៏ព្រមព្រៀងគ្នាលើកសត្វសីហៈតាំងឲ្យធ្វើជាស្ដេចឡើងហៅថា រាជសីហៈ ឬ រាជសីហ៍ (សីហៈ ជាស្ដេចនៃសត្វចតុប្បាទទាំងឡាយ) មានតាំងពីកាលនោះមក ។

ចំណែកខាងពួកមច្ឆា (ត្រី) ក្នុងមហាសមុទ្រ ក៏មានយោបល់យល់

ឃើញដូចជាពួកសត្វចតុប្បាទដែរ លុះប្រឹក្សាទៅ មានការព្រមព្រៀងគ្នាហើយ ក៏លើកត្រីឈ្មោះអានន្ទ ឲ្យធ្វើជាស្ដេច គ្រប់គ្រងលើត្រីទាំងឡាយទូទៅ (អានន្ទមច្ឆា ជាស្ដេចនៃត្រីទាំងឡាយ) មានតាំងពីកាលនោះមក ។

គ្រានោះ ពួកបក្សី (សត្វស្លាប) ក្នុងហិមវន្តប្រទេស បានប្រជុំគ្នានៅទីកន្លែងមួយ ប្រឹក្សាគ្នាថា ពួកមនុស្សគេជ្រើសរើសគ្នា តាំងឲ្យធ្វើជាស្ដេចសម្រាប់គ្រប់គ្រងគ្នា មានរួចហើយ ឯខាងពួកសត្វចតុប្បាទ និងពួកមច្ឆា គេក៏បានរៀបចំគ្នាឲ្យមានស្ដេចអស់ហើយដែរ នៅតែពួកយើងជាបក្សីមិនទាន់មានស្ដេចដូចគេនៅឡើយ ការនៅដោយគ្មានសេចក្ដីគោរពកោតខ្លាចគ្នាទៅវិញទៅមកដូច្នេះនេះ ជាការពុំគួរដល់ពួកយើងពល់គ្នាទេ បើដូច្នេះ ពួកយើងគួរតែជ្រើសរើសយកអ្នកណាមួយឲ្យធ្វើជាស្ដេចឡើង ។ ខណៈនោះ មៀមមានសេចក្ដីព្រួយ ដោយខ្លាចក្រែងឋានៈស្ដេចនោះបានទៅលើក្អែក ក៏ខំដើរធ្វើអន្តគមន៍និងបក្សីឯទៀត ពីមួយទៅមួយថា ពួកយើងកុំយកក្អែកឲ្យធ្វើជាស្ដេច ព្រោះក្អែកនេះ រូបអាក្រក់ណាស់ ហើយខ្មៅឃ្មឹក គ្មានសល់ចន្លោះត្រង់ណាទេ បើរូបខ្មៅហើយ ចិត្តក៏ខ្មៅអាក្រក់ដែរ ទាំងឫកពាក៏ចាបថោកទៀត ជាអ្នករបិញរបុញ ទិលខូចណាស់ បើពួកយើងលើកក្អែកឲ្យធ្វើជាស្ដេច ពួកយើងមុខជាត្រូវបានទទួលទុក្ខវេទនាអំពីក្អែកនោះវិញពុំខានឡើយ ។ ឯក្អែក បានដឹងរបាយ

កលរបស់មៀមដែលដើរញាះញង់ដូច្នោះហើយ កំគិតទុកក្នុងចិត្តថា មិនអីទេ មៀមឯងគង់តែនឹងដឹងគ្នា ។

ក្នុងពេលដែលពួកសត្វបក្សីមកជួបជុំគ្នាហើយ មានបក្សីមួយឡើងប្រកាសថា អ្នកពល់គ្នាចូរស្តាប់ខ្ញុំ ឥឡូវនេះ យើងគួរជ្រើសរើសអ្នកណាឲ្យធ្វើជាស្តេច ? បក្សីទាំងអស់នាំគ្នាគយគន់រកមើលក្នុងចំណោមបក្សីទាំងនោះទៅ ឃើញមៀមជាសត្វអង់អាច គួរឲ្យធ្វើជាស្តេច ហើយក៏បញ្ចេញយោបល់ស្របគ្នាថា ពួកយើងពេញចិត្តនឹងមៀមនេះគួរយកមៀមឲ្យធ្វើជាស្តេច ។ គ្រានោះ មានបក្សីមួយទៀតឡើងប្រកាសថា ឥឡូវបើអ្នកពល់គ្នាពេញចិត្តនឹងមៀមហើយ យើងសូមប្រកាស ៣ ដងថា អ្នកទាំងអស់គ្នា ប្រាកដជាពេញចិត្តនឹងមៀមមែនឬ? បើអ្នកណាមិនពេញចិត្តទេ ចូរឆ្លើយមក ។ ប្រកាសលើកទី ១ បក្សីទាំងអស់នៅស្ងៀម ប្រកាសលើកទី ២ ក៏គ្មានបក្សីណាឆ្លើយ ប៉ុន្តែក្អែកចំប្រឹងទ្រាំអត់មិនទាន់ថាអីក្នុងលើកទី ១ និង លើកទី ២ លុះដល់ប្រកាសលើកទី ៣ ក្អែកក៏ស្ទុះក្រោកឡើងជំទាស់ភ្លាមថា ខ្ញុំមិនពេញចិត្តទេ បើយកមៀមឲ្យធ្វើជាស្តេច ។

– ហេតុអ្វីបានជាអ្នកឯងមិនពេញចិត្តនឹងមៀម? – បានជាខ្ញុំមិនពេញចិត្តព្រោះមៀមមានលក្ខណៈមួយខុសពីគេឯទៀត ។ – មៀមមានលក្ខណៈខុសពីគេត្រង់ណាខ្លះ ចូរអ្នកឯងថាមកមើល? – ខ្ញុំមិនហ៊ានថាទេ លុះតែអ្នកទាំងអស់គ្នាអនុញ្ញាតឲ្យ ហើយក៏ចាំងទទួលខុសត្រូវផង ទើប

ខ្ញុំហ៊ានថា ៗ — អើមិនអីទេ យើងទាំងអស់គ្នាអនុញ្ញាតឲ្យហើយ ចូរថាមកចុះ! — ខ្ញុំស្ទើរតែមិនហ៊ានថាទេ ប៉ុន្តែបើអ្នកកាល់គ្នាបង្ខំឲ្យខ្ញុំថាហើយ ខ្ញុំត្រូវតែប្រថុយថាទៅចុះ អ្នកកាល់គ្នាចូរសង្កេតមើលមុខ និងភ្នែករបស់មៀមនេះចុះ មានលក្ខណៈខុសពីគេឯង មុខគាត់នេះ ខឹងដូចជា មិនខឹងភ្នែកក្រហមលៀន ជាពិសេស ចូរសង្កេតមើលទឹកមុខចុះ គាត់នេះមិនទាន់ខឹង មុខក្រញូវអាក្រក់ម៉្លេះទៅហើយ ចំណង់បើដល់ខឹងឡើង តើមុខនឹងឡើងអាក្រក់យ៉ាងណាទៅទៀត ហេតុនេះ បានជាខ្ញុំមិនពេញចិត្ត បើយើងលើកមៀមអភិសេកឲ្យធ្វើជាស្តេចកាន់អំណាចទៅ មុខមៀមមិនទាន់ខឹង អាក្រក់ម្លឹងទៅហើយ កាលបើដល់ពេលគាត់ខឹងឡើង នឹងទៅជាយ៉ាងណាទៅទៀត មុខជាធ្វើយើងទាំងអស់គ្នាឲ្យបែកបាក់ខ្ទេចខ្ទីស្លាប់អស់ជាពុំខាន ដូចជាអំបិលដែលគេដាក់ក្នុងអំបែងកំពុងក្តៅ ៗ

ក្អែក កាលបើបាននិយាយរិះគន់មៀមយ៉ាងនេះហើយ ក៏ស្រែកដោយសម្រែកយ៉ាងខ្លាំងថា «បើយកមៀមឲ្យធ្វើជាស្តេច យើងមិនព្រមជាដាច់ខាត» ហើយស្ទុះហើររត់ទៅ ៗ ឯមៀម កើតសេចក្តីក្តៅក្រហាយខ្លាំង ក៏ស្ទុះហើរដេញតាមព្យាបាទក្អែកបាត់ទៅ ៗ គ្រានោះពួកបក្សីបែកគ្នាជាពីរក្រុម : មួយក្រុមកាន់ជើងខាងក្អែក មួយក្រុមទៀតកាន់ជើងខាងមៀម ៗ បក្សីណាដែលកាន់ខាងក្អែក បក្សីនោះហៅថា ទិវាចរ (ពួកបក្សីចេញស្វែងរកចំណីតែក្នុងវេលាថ្ងៃ) បក្សីណាដែលកាន់ខាង

មៀម បក្សីនោះហៅថា ត្តិចរ ឬ កត្តិចរ (ពួកបក្សីចេញស្វែងរកចំណីតែក្នុងវេលាយប់) ដើម្បីគេចចៀសមិនឲ្យជួបនិងក្អែក ៗ ក្អែក និងមៀមដែលកើតហេតុពិពទាស់ខែងគ្នាបាទ ចងពៀរនឹងគ្នាទៅវិញទៅមកនេះ មានតាំងពីកាលនោះមក ។

បន្ទាប់ពីនោះមក បក្សីទាំងឡាយក៏នាំគ្នាលើកហង្សឲ្យធ្វើជាស្ដេចឡើង ទើបមានពាក្យហៅជាប់មកថា "ហំសរាជា ស្ដេចគឺហង្ស ឬ រាជហង្ស ហង្សជាស្ដេចនៃពួកបក្សី" មានតាំងពីកាលនោះមក ។

(តិកនិបាតជាតក)

ជម្លោះរវាង

## ពស់ និង ស្កា

កាលព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងទាំងឡាយ ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោកហើយ ទ្រង់គង់នៅនាវត្តជេតពន ជិតរាជធានីសាវត្ថី ។ គ្រានោះ ភិក្ខុទាំងឡាយនាំគ្នាដើរចូលទៅកាន់ស្រុកមួយដើម្បីបិណ្ឌបាត លុះដល់ពាក់កណ្ដាលផ្លូវ បានប្រទះឃើញពស់នឹងស្កាកំពុងតែទាស់ទែងគ្នា ទៀតទៀនគ្នាដោយកម្លាំងកាយទៅវិញទៅមក ៗ លុះដល់ទីបំផុតនៃការឈ្លោះគ្នា ពស់ក៏ដល់នូវទុក្ខពលកាត ពិការ ថមថយកម្លាំងដោយការចាញ់ទុបាយកលរបស់ស្កា ។

ភិក្ខុទាំងនោះ កាលបើត្រឡប់មកពីបិណ្ឌបាតវិញហើយ នាំគ្នាចូលទៅកាន់សំណាក់ព្រះពុទ្ធជាម្ចាស់ ហើយក្រាបបង្គំទូលអំពីដំណើរពស់នឹងស្វាកើតវិវាទតាស់ទែងនឹងគ្នា ថ្វាយព្រះអង្គទ្រង់ព្រះសណ្ដាប់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងពីរគឺ ពស់និងស្វានេះ មិនមែនទើបនឹងកើតវិវាទនឹងគ្នាក្នុងកាលឥឡូវនេះទេ គឺកើតវិវាទនឹងគ្នាយ៉ាងនេះ តាំងពីព្រេងនាយមកម៉្លេះ កាលនោះ តថាគតជាពោធិសត្វនៅឡើយ បានកើតក្នុងត្រកូលនៃព្រាហ្មណ៍នៅក្នុងស្រុកមួយជិតក្រុងពារាណសី លុះមានវ័យចំរើនធំឡើងហើយ ក៏ចេញទៅបំពេញវិជ្ជាឯនគរតក្កសិលា ។ ការសិក្សាវិជ្ជារបស់ពោធិសត្វមិនយូរប៉ុន្មាន ក៏បានចេះដឹងសព្វគ្រប់ ហើយត្រឡប់មកនៅគ្រប់គ្រងគេហដ្ឋានប្រកបអាជីវកម្មតាមប្រពៃណីរបស់ត្រកូល លុះដល់បច្ឆិមវ័យ ពោធិសត្វក៏លះបង់យកភេស ចេញទៅបួសជាឥសី តាំងអាស្រមនៅក្នុងហិមវន្តប្បទេស បានបំពេញតបធម៌ ហើយញ៉ាំងអភិញ្ញា និងសមាបត្តិឲ្យកើតឡើងនៅជាសុខសាន្តក្នុងទីនោះដោយអាស្រ័យនូវមើមឈើនិងផ្លែឈើជាអាហារ ។

នៅចុងទីបញ្ចប្រក្រមនៃតាបសជាពោធិសត្វ មានស្វាមួយធ្លើវូងនៅក្នុងដំបូកមួយ មានពស់មួយនៅទីងគល់ឈើជិតស្វានោះដែរ ។ សត្វទាំងពីរនេះវេលាឃើញគ្នាកាលណា រមែងតែឈ្លោះបៀតបៀនគ្នាជាធម្មតា ។ ពស់ជាសត្វលង់ ហើយខ្ពិលមិនចេះធ្វើវូងនៅ ឃើញស្វាមានវូងនៅ

ស្រួល ក៏គិតថា អញនឹងសម្លាប់ស្កានោះយកធ្វើជាអាហារផង នឹងយករូងវាទៅផង ។ ឯស្កា ក៏បានដឹងថា ពស់បំរុងនឹងព្យាបាទខ្លួនឲ្យវិនាសជីវិត ក៏ប្រុងស្មៀតប្រយ័ត្នខ្លួនជានិច្ច ដើម្បីតទល់នឹងពស់នោះវិញដែរ ។ ពោធិសត្វបានឃើញពស់នឹងស្កា ទាស់ទែងគ្នាស្ទើរតែរាល់ថ្ងៃ ក៏ព្យាយាមឲ្យឱវាទចំពោះសត្វទាំងពីរឲ្យមានសាមគ្គីរួបរួមគ្នា កុំឲ្យទាស់ទែងនឹងគ្នាតទៅទៀត ។ ឯពស់នឹងស្កា ដោយអំណាចបានស្តាប់ឱវាទតាបសហើយ ក៏ផ្អាកឈប់ឈ្លោះគ្នាដែរ ប៉ុន្តែកំហឹងនឹងការចងគំនុំនឹងគ្នាទៅវិញទៅមក ពុំទាន់រលត់បាត់នៅឡើយ ។

ថ្ងៃមួយ ពស់ចេញទៅស្វែងរកអាហារខាងក្រៅបាត់ទៅ ស្កាដេកហាមាត់បញ្ចេញចង្កូម ដាក់ក្បាលប៉ិប៉ុមនឹងមាត់រូង កំពុងលក់ដកដង្ហើមចេញចូលព្រួសព្រួយ ៗ យ៉ាងស្រួល ៗ តាបសដើរទៅជិតដំបូក បានឃើញស្កានោះកំពុងដេកលក់ដូច្នោះ ក៏ស្រែកសួរថា នែស្កា ! ឯងដេកធ្វើអាការដូច្នេះ ហាក់ដូចជាប្រុងស្មៀតការពារនឹងភ័យអ្វីមួយ ដែលនឹងមានមកដល់ខ្លួនឯងឬ ?– ស្កា: ខ្ញុំសព្វថ្ងៃនៅជាមួយនឹងបច្ចាមិត្ត គួរតែខ្ញុំប្រុងប្រយ័ត្នជានិច្ចគ្រប់ឥរិយាបថដូច្នេះ ទើបបាន ។– តាបស: អ្នកណាជាបច្ចាមិត្តនឹងឯង ដែលប្រុងនឹងធ្វើឲ្យឯងមានភ័យ ? – ស្កា: ពស់ជាបច្ចាមិត្តនឹងខ្ញុំ ។ តាបស: ឯងកុំភ័យព្រួយបារម្ភអ្វី យើងនឹងធ្វើមិនឲ្យពស់នោះប្រទូស្តបៀតបៀនដល់ឯងទៀតទេ កុំឲ្យឯងរង្កៀសចិត្តនឹងពស់នោះតទៅទៀត

ស្កា: ឧវាទរបស់លោកតា ខ្ញុំស្តាប់បានអស់ហើយ ប៉ុន្តែនៅមិនទាន់អស់ហើយពីក្នុងចិត្តខ្ញុំសោះ ៗ តាមសពោធិសត្វ ឋិតនៅជាសុខក្នុងឈានសមាបត្តិ លុះដល់ទីបំផុតនៃអាយុ ក៏បានទៅកើតក្នុងព្រហ្មលោកនាយទៅ ៗ ឯពស់ ទីង ស្កានោះគ្រាន់តែមិនបានឈ្លោះបៀតបៀនគ្នាក្នុងជាតិនោះ ដោយអំណាចឧវាទនៃពោធិសត្វ ប៉ុន្តែកំហឹងនិងការចងពៀរគុំគួននឹងគ្នាទៅវិញទៅមក ជាប់មានតាំងពីកាលនោះមក ៗ

(ទុកនិបាតជាតក)

ជម្មោះរវាង

# ខ្លាឃ្មុំ និង ដើមពង្រ

ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធជាបរមសាស្តានៃយើង ទ្រង់គង់នៅទៀបឆ្នេរនៃស្ទឹងរោហិណី ដើម្បីសំដែងធម៌រម្ងាប់ខ្ញាល់អធិករណ៍នៃពួកព្រះញាតិរបស់ព្រះអង្គ ក្នុងពេលនោះ ព្រះអង្គទ្រង់លើកយកធម៌និងរឿងផ្សេង ៗ ជាច្រើនមកសំដែង ដើម្បីឲ្យពួកព្រះញាតិទាំងនោះស្តាប់ហើយនឹងឲ្យលះបង់នូវការវិវាទ ដែលជាហេតុនាំឲ្យចងពៀរវេរនឹងគ្នាតទៅក្នុងអនាគតទៀត ៗ

ក្នុងទីនេះ ខ្ញុំសូមលើកយកចំពោះតែរឿងខ្លាឃ្មុំ នឹងដើមពង្រ ដែលចងពៀរនឹងគ្នា មកដំណាលជូនជាសណ្តាប់ដូចតទៅនេះ ៖

នៅខាងក្រៅទីក្រុងពារាណសី មានស្រុកមួយច្រើនតែពួកជាងឈើ

នៅកាស្រ័យ ៗ បណ្ដាពួកជាងឈើដែលនៅក្នុងស្រុកនោះ មានជាងឈើម្នាក់តែងទៅនាំយកឈើទាំងឡាយអំពីព្រៃមកធ្វើគ្រឿងរថ (រទេះ) សម្រាប់លក់ចិញ្ចឹមជីវិត ៗ កាលនោះ មានដើមពង្រមួយដើមធំ ដុះនៅក្នុងហិមវន្តប្បទេស ៗ មានខ្លាឃ្មុំមួយស្វែងរកចំណីបរិភោគ ហើយមកដេកនៅក្បែរគល់ពង្រនោះ ៗ ចួនជាក្នុងថ្ងៃនោះ មានខ្យល់បក់មកមែកពង្រស្ងួតក្រៀមមួយបាក់ធ្លាក់ចុះមកដោយកម្លាំងខ្យល់ ក៏សង្កត់លើកខ្លាឃ្មុំ ៗ ខ្លាឃ្មុំមានសេចក្ដីឈឺចាប់យ៉ាងខ្លាំង ទាំងមានសេចក្ដីភិតភ័យដោយមិនដឹងជាអ្វី ក៏ស្ទុះរត់ចេញទៅខាងក្រៅ បន្តិចត្រឡប់មករកមើលត្រង់កន្លែងនោះវិញមិនឃើញអ្វីប្លែកសោះ ឃើញតែមែកពង្រដែលបាក់ធ្លាក់មកនោះ ៗ ខ្លាឃ្មុំកើតសេចក្ដីក្រោធមិនសមហេតុផល ត្រឡប់ជាខឹងចងគំនុំនឹងដើមពង្រដោយគិតថា ឥឡូវនឹងជាមានសីហៈ ឬខ្លាធំណាមួយមកដេញព្យាបាទដល់អញក៏ទេដែរ ចំនងជាមានទេព្ដានៅនឹងដើមឈើនេះកាច់មែកពង្រទំលាក់មកលើអញ ដែលកំពុងដេកនៅទីនេះ មិនអីទេ គង់តែនឹងដឹងគ្នា ៗ ខ្លាឃ្មុំខឹងណាស់ ក៏ស្ទុះទៅប្រហារដើមពង្រនោះដោយចង្កូម ហើយគំរាមរុក្ខទេវតាថា អញគ្មានត្រូវការស៊ីស្លឹកនឹងមែកឈើរបស់អ្នកឯងទេ ម្ដេចក៏ឯងមកបៀតបៀនអញ អញមានទោសកំហុសដូចម្ដេច ? អើមិនអីទេ ចាំមើលតែពីរបីថ្ងៃទៀត អញនឹងឲ្យគេកាប់កាស់រំលើងដើមឈើព្រមទាំងឫសគល់របស់អ្នកឯង ហើយឲ្យគេ

កាត់ជាកំណាត់តូច កំណាត់ធំផងទៀតពុំខាន ៗ គ្រានោះ ជាងឈើនោះឯង បាននាំកម្មករពីរបីនាក់ បររទេះចូលទៅក្នុងព្រៃដើម្បីរកឈើធ្វើគ្រឿងរទេះ ៗ លុះដល់ព្រៃហើយ ក៏បញ្ឈប់រទេះទុកក្នុងទីមួយ នាំគ្នាកាន់កាំបិត និងពូថៅដើរចូលទៅជិតដើមពង្រនោះ ៗ ខ្លាឃ្មុំឃើញជាងឈើនោះគិតថា «អីថ្ងៃនេះ អញបានឃើញខ្នងបច្ចាមិត្តហើយ» ក៏ស្ទុះមកឈរជិតដើមពង្រ ៗ ចំណែកខាងជាងឈើ ដើរបណ្តើរ គយគន់រកមើលបណ្តើរ ក្រែងប្រទះឈើដែលខ្លួនត្រូវការ ៗ ខ្លាឃ្មុំស្រែកសួរថា នែជាងឈើ ! អ្នកឯងកាន់ដងជាប់នូវដៃ ដើរចូលមកក្នុងព្រៃប្រាថ្នារកកាប់ឈើអ្វី? ជាងឈើ: ខ្ញុំមករកកាប់ឈើណាដែលមានសាច់ជាប់ល្អយកទៅធ្វើគ្រឿងរទេះ ៗ

– ខ្លាឃ្មុំ: ខ្ញុំនៅក្នុងព្រៃនេះ ខ្ញុំស្គាល់ឈើគ្រប់ទាំងអស់ គឺឈើណាជាប់ ណាមិនជាប់ ឥតមានកំបាំងពីខ្ញុំទេ ៗ – ជាងឈើ: ទមែនហើយ អ្នកឯងនៅព្រៃស្គាល់ឈើល្អ និងឈើមិនល្អ ចុះឈើអ្វីដែលមានសាច់ជាប់មាំមួនល្អ ? – ខ្លាឃ្មុំ: កំងក្តី គគីរក្តី ផ្ចឹកក្តី សុក្រំក្តី ដើមត្រចៀកក្រើសក្តី ឈើទាំងនេះ សុទ្ធតែឈើមានខ្លឹមមែនហើយ ប៉ុន្តែមិនសូវជាប់មាំល្អប៉ុន្មានទេ បើបានឈើឈ្មោះផ្ទួន: (ពង្រ) ជាប់មាំល្អណាស់ ប្រើប្រាស់ទៅមិនងាយនឹងខូចទេ បើបែរជាយកទៅធ្វើគ្រឿងរទេះ មានខ្នងកង់ជាដើម ក៏រឹតតែជាប់មាំ ប្រសើរណាស់ទៅទៀត ៗ

ជាងឈើឮពាក្យខ្លាឃ្មុំប្រាប់ហើយ កំមានសោមនស្សរីករាយសប្បាយចិត្ត គិតថា ថ្ងៃនេះ អញមានភ័ព្វល្អណាស់តើ ចូលមកក្នុងព្រៃ មានសត្វតិរច្ឆានប្រាប់ឈើដែលគួរយកទៅធ្វើគ្រឿងរទេះ កំសួរទៅខ្លាឃ្មុំថា ចុះដើមពង្រនោះ មានភាពបែបដូចម្តេចខ្លះទៅ ព្រោះខ្ញុំមិនដែលស្គាល់?

— ខ្លាឃ្មុំ: ស្លឹកវាកងធំទ្រវែងបន្តិច មែកវាកងសាខាសំយុងចុះក្រោម ផ្លែវាកងមូលជមបន្តិច ជាចង្កោមៗ ពួកមនុស្សតែងបេះយកទៅធ្វើជាអាហារបរិភោគ ឈើនេះសំខាន់ណាស់ បើយកធ្វើជាកាំក្ដី ជាខ្នងកង់ក្ដី ជាដុំក្ដី ជាប់ហើយធន់ផងទៀត គ្មានឈើណាវិសេសជាងពង្រទៅទៀតទេ ៗ — ជាងឈើ: ចុះកន្លែងណាដែលមានដើមពង្រ? — ខ្លាឃ្មុំ: បើអ្នកឯងមិនស្គាល់ទេ ចូរមើលមកខ្ញុំ ខ្ញុំឈរជិតដើមឈើណា ដើមឈើនោះឯងហៅថា ពង្រ ៗ ខ្លាឃ្មុំ លុះបានប្រាប់ជាងឈើឲ្យស្គាល់ច្បាស់ហើយ ក៏មានចិត្តត្រេកអរណាស់ ដោយគិតថា នឹងបានសម្រេចដូចបំណងរបស់ខ្លួន ហើយថយទៅសម្ងំនៅក្នុងទីមួយលបចាំមើលក្បែរនោះដែរ ៗ ខណៈនោះ ជាងឈើក៏រៀបចំប្រារព្ធនឹងកាប់ដើមពង្រនោះ ៗ

រុក្ខទេវតា ដែលនៅនឹងដើមឈើនោះគិតថា ឱអញ គ្រោះថ្នាក់ដល់ហើយតើ! អន្តរាយនេះ ប្រាកដជាកើតមកពីខ្លាឃ្មុំនោះឯង ជាអ្នកញុះញង់បង្កហេតុ ឯមែកពង្រដែលបាក់ធ្លាក់ទៅលើវានោះ ដោយសារខ្យល់ទេ មិនមែនអញធ្វើឡើយ សូម្បីតែវត្ថុបន្តិចបន្តួច ក៏អញមិន

ផ្លែឈើធ្វើឲ្យធ្លាក់ចុះទៅលើកដែរ ឥឡូវក៏ត្រឡប់បង្គំនុំខុសទំនងមិនសម ហេតុផល ធ្វើវិមានរបស់អញឲ្យវិនាស ណ្ហើយចុះ អញបើបំណាច់នឹងវិនាស ក៏ត្រូវតែធ្វើខ្លាឃ្មុំនោះឲ្យវិនាសដូចអញដែរ ក៏ដំណែងកេចជាបុរសម្នាក់ បែបភាគជាអ្នកធ្វើការក្នុងព្រៃ ហើយដើរចូលទៅជិតជាងឈើនោះសួរថា នែជាងឈើ អ្នកឯងកាប់ឈើនេះ បម្រុងនឹងយកទៅធ្វើអ្វី?–ជាងឈើ: យកទៅធ្វើខ្នងកង់រទេះ គេថា ឈើហ្នឹងជាប់ ។–រុក្ខទេវតា: អ្នកណាប្រាប់អ្នកឯង?–ជាងឈើ: ខ្លាឃ្មុំប្រាប់ខ្ញុំ ។–រុក្ខទេវតា :បើខ្លាឃ្មុំប្រាប់ ការនោះប្រាកដមែនហើយ ប៉ុន្តែឈើនេះ បើយកទៅប្រើសុទ្ធតែកំមិនសូវជាជាប់កំណត់ប៉ុន្មានទេ បើបានស្បែកខ្លាឃ្មុំត្រង់កប្រមាណប៉ុន ៤ ធ្នាប់ទទឹង យកមកពាសព័ទ្ធមណ្ឌលខ្នងកង់ពីក្រៅឲ្យដូចគេព័ទ្ធដោយបន្ទះដែក ហើយយកខ្លាញ់ក៏មកលាបសាប់ឈើនោះខ្ទះផង ហ្នឹងរឹងរឹតតែជាប់អំណត់ណាស់ទៅទៀត ។–ជាងឈើ: ឲ្យខ្ញុំទៅរកស្បែកនិងខ្លាញ់ខ្លាឃ្មុំនោះពីណាបាន ។–រុក្ខទេវតា : អ្នកឯងកុំល្ងង់ពេក ដើមពង្រីនេះដុះនៅក្នុងព្រៃមិនរត់ទៅណាបាត់ទេ ខ្លាឃ្មុំណាដែលប្រាប់អ្នកឯងថា ឈើនឹងជាប់ អ្នកឯងចូរទៅកាន់សំណាក់ខ្លាឃ្មុំនោះ និយាយបញ្ឆោតវាថា ឈើដែលអ្នកឯងបង្ហាញខ្ញុំនោះ ឥឡូវឲ្យខ្ញុំកាប់កាត់ត្រង់កន្លែងណាខ្លះ ចូរនាំវាឲ្យមកបង្ហាញ កាលបើវាមកហើយក៏ពុងតែយកចុងមាត់បង្ហាញថា អ្នកឯងចូរកាត់ត្រង់នេះ ឬ ចូរកាត់ត្រង់នោះ អ្នកឯង

យកពូថៅធំដ៏មុតកាប់សម្លាប់ ហើយពន្លះយកស្បែកព្រមទាំងសាច់ក៏យក ទៅបរិភោគទៅ ។

ជាងឈើបានធ្វើតាមពាក្យដែលរុក្ខទេវតានោះបង្គាប់ហើយ ក៏សំឡាប់ខ្លាឃ្មុំនោះបាន ហើយការពន្លះយកស្បែក សាច់និងខ្លាញ់រួចហើយ ទើបកាប់ដើមពង្រនោះជាខាងក្រោយនាំយកទៅ ព្រោះហេតុនោះ បានជាខ្លាឃ្មុំ កាលណាបើវាប្រទះឃើញដើមពង្រ តែងតែស្ទុះទៅខាំកកេរជាធម្មតា ព្រោះមានពាំនៀរនឹងគ្នា ជាប់តាំងពីកាលនោះមក ។

(តេរសនិបាតជាតក)

---

បុគ្គលគួរបង្ហាញមេត្រី មួយអន្លើដោយសត្រូវ ដែលធ្វើឧបការៈ តែកុំធ្វើមួយអន្លើដោយមិត្រ ដែលធ្វើអបការៈ (ទោស) ឡើយ ឧបការៈនឹងអបការៈ ទាំងពីរប្រការនេះ ជាលក្ខណៈដែលបុគ្គលគប្បីកំណត់ដឹងចំពោះសត្រូវនឹងមិត្រទាំងឡាយ ។

ហិតោបទេស

# ព្រះអភិធម្មបិដក

(គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៊ូ រៀបរៀង

តមក

## រឿងអានន្ទសេដ្ឋី

មានសេដ្ឋីម្នាក់ឈ្មោះអានន្ទសេដ្ឋី ជាមនុស្សកំណាញ់ស្វជន ទានក៏មិនឲ្យ សីលក៏មិនរក្សា ដែលបានជាសេដ្ឋីក្នុងជាតិនេះ ព្រោះខ្លួនបានប្រគេនអាហារបិណ្ឌបាតទានដល់ព្រះភិក្ខុសង្ឃ ដែលមកបិណ្ឌបាតពីជាតិមុន ៗ កុសលដែលខ្លួនបានប្រគេនបិណ្ឌបាតទាននោះ នាំបដិសន្ធិក្នុងជាតិនោះ លុះរលត់បញ្ចក្ខន្ធពីជាតិជាសេដ្ឋី ទៅកើតក្នុងត្រកូលចណ្ឌាលនៅក្បែរទ្វារផ្ទះនៃខ្លួន ៗ អកុសលកម្មតាមបៀតបៀនត្រកូលនោះមិនឲ្យបានសេចក្ដីសុខសោះ តាំងពីទារកនោះមកចាប់បដិសន្ធិក្នុងផ្ទៃមាតាមក ៗ មនុស្សទាំងឡាយ ទើបប្រឹក្សាគ្នាថា កាលពីដើម យើងមិនដែលមានទុក្ខយ៉ាងនេះទេ សូម្បីគ្មានណាករកសូមទានគេមិនបាន ក៏មានតែម្នាក់ ៗ ប៉ុណ្ណោះ មិនមែនទាំងអស់គ្នាទេ មកដល់គ្រានេះ យើងជាមនុស្សឥតលាភសូមទានគេមិនបានគ្រប់គ្នា គ្មានអ្នកណារកអ្វីបានសោះ ចេះតែវិនាសទៅកាល់ពេលវេលា ៗ

ប្រការមួយទៀត កាលពីដើម បើទុកជាយើងទាល់ក្រយ៉ាងណា

យើងក៏នៅតែស្រឡាញ់រាប់អានគ្នាដែរ ចុះពេលនេះបែរជាស្អប់គ្នាទៅវិញ ប្រហែលជាមនុស្សកាឡកណ្ណីមកកើត យើងចូរបែកគ្នាជាពីរពួកចុះ សេចក្ដីចំរើននឹងកើតមានដល់ពួកយើងទាំងឡាយ បើមនុស្សកាឡកណ្ណីនៅក្នុងពួកណា ពួកនោះក៏នឹងវិនាសទ្រព្យសម្បត្តិ ស្វែងរកលាភលែងបាន បើមនុស្សកាឡកណ្ណីគ្មានក្នុងពួកណា ពួកនោះក៏នឹងរកលាភបានដូចពីមុនមក ៗ ពួកមនុស្សចណ្ឌាលប្រឹក្សាគ្នាដូច្នេះហើយ ក៏បែកគ្នាទៅជាពីរពួក ៗ ពួកណាដែលមាតាបិតាទារកនោះមិនបាននៅជាមួយទេ ពួកនោះក៏រកទ្រព្យចិញ្ចឹមជីវិតបានដោយងាយ ៗ ពួកណាដែលមាតាបិតាទារកនោះនៅជាមួយ ពួកនោះក៏ចេះតែវិនាសទៅ ៗ សូម្បីតែអាហារនឹងបរិភោគក៏គ្មាន ៗ ទ្វេ កោដ្ឋាសា ហុត្វា ជនទាំងឡាយក៏បែកខ្ញែកចេញពីគ្នាជាពីរផ្នែកទៀត លុះដល់មាតាបិតានៃទារកនោះទៅនៅជាមួយគ្នា ខាងបិតានៃទារកនោះក៏បែកចេញទៅពីភរិយា ស្វែងរកលាភបានចិញ្ចឹមខ្លួនដោយសេចក្ដីសុខសប្បាយ ឯមាតានៃទារកនោះប្រកបដោយសេចក្ដីអត់ឃ្លានវេទនាលំបាករហូតដល់សម្រាលកូន កាលសម្រាលកូនរួចហើយថ្ងៃណា ក៏នាំទារកនោះដើរទៅរកសូមទានគេ ក្នុងថ្ងៃនោះសូម្បីតែបាយមួយចំអែត ក៏រកមិនបាន បើថ្ងៃណាមាតាទៅសូមទានគេតែម្នាក់ឯង មិនយកកូនទៅផងទេ ថ្ងៃនោះទើបបានបាយគ្រាន់ចិញ្ចឹមជីវិតនឹងបុត្រ ៗ មាតាចេះតែទ្រាំរងទុក្ខវេទនាដរាបដល់កូននោះចេះដើរ

មាតាទើបបណ្ដោយបុត្រនោះឲ្យដើរបែកចេញពីខ្លួនទៅតែម្នាក់ឯង ៗ

ចំណែកទារកនោះ រឭកឃើញនូវជាតិនៃខ្លួន ហេតុតែកុសលដែលខ្លួនបានធ្វើទុកមកពីជាតិមុន គឺដើរតាមផ្លូវទៅដល់ផ្ទះដែលខ្លួនធ្លាប់នៅក្នុងកាលកើតជាធនទូរសេដ្ឋី ក៏ចាំបាន ទើបចូលទៅក្នុងភូមិរបស់ខ្លួននោះ ព្រោះគិតសំគាល់ថាផ្ទះនោះជាផ្ទះរបស់ខ្លួន ៗ បណ្ដាជនអ្នករក្សាទ្វារក៏ហាមឃាត់បណ្ដេញថា ម្នាលបណ្ឌាល ឯងកុំចូលមកឡើយ ៗ ក្មេងបណ្ឌាលនោះ ទុកជាគេហាមឃាត់យ៉ាងណាក៏មិនស្ដាប់ ស្រែកតបវិញថា ផ្ទះរបស់អញ ៗ ខំចូលទៅរកកូនប្រុសស្រីរបស់អញ ទីនេះជាលំនៅរបស់អញ អ្នកចូរកុំហាមឃាត់អញដូច្នេះឡើយ មិនសមគួរទេ ៗ ក្មេងបណ្ឌាលថាដូច្នោះហើយ ក៏ចូលទៅក្នុងភូមិ អ្នកចាំទ្វារវាយក្មេងនោះយ៉ាងដំណំ ទាល់តែដួលដេកនៅទីនោះ ៗ

ក្មេងបណ្ឌាលរងទុក្ខវេទនាដូច្នេះ អាស្រ័យឧបត្ថម្ភកកម្មខាងអកុសលទំនុកបម្រុង គឺមានសេចក្ដីទុក្ខរួចហើយធ្វើឲ្យបានទុក្ខរឹតតែច្រើនឡើងទៀត ៗ ឧបត្ថម្ភកកម្មនេះ ជាបច្ច័យគឺទំនុកបម្រុងទាំងខាងបុណ្យទាំងខាងបាបទាំងពីរប្រការ ៗ ឧបត្ថម្ភកកម្មខាងកុសលក៏ជាប់តាមទំនុកបម្រុងនូវបុគ្គលដែលមានសុខ មានទ្រព្យស្រាប់ហើយ ឲ្យរឹតតែមានច្រើនខ្លាំងឡើងទៀត ចំណែកឧបត្ថម្ភកកម្មខាងអកុសលវិញ ក៏ជាប់តាមទំនុកបម្រុងនូវបុគ្គលដែលវិនាសហើយ ឲ្យរឹតតែវិនាសកាស់ពេលទៅទៀត ៗ ឯផល

នៃបុគ្គលកម្មខាងអកុសលនេះ កើតមានដល់បុគ្គល ហេតុតែខ្លួនប្រទូស
រាយដល់អ្នកមិនបានប្រទូសរាយ នឹងជាមនុស្សគ្មានគតញ្ញូ ។ បុគ្គលប្រ
ទូសរាយដល់អ្នកមិនបានប្រទូសរាយ ក្នុងបច្ចុប្បន្នជាតិ គឺគ្មានសេចក្ដីសុខ
លុះដល់ទៅក្នុងជាតិមុខ ក៏នឹងសោយទុក្ខពប់មិនអស់ សមតាមព្រះពុទ្ធ
ភាសិតថា ៖

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិៈ បុគ្គលណាប្រទូស
រាយ ចំពោះអ្នកមិនបានប្រទូសរាយដល់ខ្លួន បុគ្គលនោះនឹងបានសោយ
នូវទុក្ខជាច្រើន គឺចិត្តនឹងអណ្ដែតអណ្ដូងរាយមាយទៅជាឆ្កួត ទ្រព្យមាន
ទៅស្រាប់ តែវិនាសខូចខាតទៅ តែស្បែងក្លាយទៅជាដុំឥដ្ឋ តែមុត្តាក្លាយ
ទៅជាថ្មដី នឹងមានគេនិយាយបង្កាច់បង្ខូច គឺខ្លួនមិនបានពោលមិនបាន
ឮមិនបានឃើញ ត្រឡប់ជាមានគេនិយាយបង្កាច់ថាខ្លួនបានពោលបានឮ
បានឃើញ ខ្លួនមិនមែនជាចោរ គេប្រជុំគ្នានិយាយថាខ្លួនជាចោរ លុះ
រលត់បញ្ចក្ខន្ធ នឹងទៅកើតក្នុងអបាយភូមិមាននរកជាដើម ។

ម្យ៉ាងទៀត បុគ្គលដែលប្រទូសរាយចំពោះអ្នកមិនប្រទូសដល់ខ្លួន
កាលនៅក្នុងមនុស្សលោកនេះ នឹងមានអគ្គីជាប្រក្រតី នឹងអគ្គីដែលកើត
ពីផ្ទះ បើភ្លើងប្រក្រតីមិនឆេះផ្ទះទេ ភ្លើងដែលកើតពីផ្ទះក៏កើតមាន
មកដុតផ្ទះឲ្យឆេះ ឲ្យមានសេចក្ដីវិនាសអន្តរាយទៅ ។

ហេតុនោះ បណ្ឌិតទាំងឡាយ បើប្រាថ្នានឹងឲ្យប្រាសចាកសេចក្ដី

វិនាស ចូរកុំមានចិត្តគិតប្រទូសរាយចំពោះអ្នកមិនប្រទុសរាយដល់ខ្លួន ក៏នឹងបានតាំងនៅកន្លងសិរីសួស្តីមង្គលក្នុងលោកនេះ នឹងលោកខាងមុខតាមក្រសែព្រះពុទ្ធដីកាដែលត្រាស់ទេសនាទុកដូច្នេះ ។

ឧបត្ថម្ភកកម្ម សង្ខេបប៉ុណ្ណោះ ។

១០- ឧបបីឡិកកម្ម

ឧបបីឡិកំ នាម អញ្ញេន កម្មុនា និព្វត្តាយ បដិសន្ធិយា តេជវនិបាកោ ឧប្បជ្ជនកំ សុខទុក្ខំ បីឡេតិ ពាធេតិ អទ្ធានំ បវត្តិតុំ ន ទេតិ ។

លំដាប់នេះ សូមវិសជ្ជនាកន្លងកម្មបច្ច័យ សំដែងនូវឧបបីឡកកម្មតទៅ ដំណើរសេចក្តីថា យំ កម្មំ បីឡេតិ កម្មឯណាដែលបៀតបៀននូវសុខនឹងទុក្ខដែលកម្មដទៃឲ្យកើត ដែលកម្មដទៃឲ្យបដិសន្ធិ ហើយកាត់ផ្តាច់នូវសុខនឹងទុក្ខដែលកម្មដទៃឲ្យកើត មិនបើកឱកាសឲ្យកម្មដទៃឲ្យផល កាត់ផ្តាច់នូវផលនៃកម្មដទៃ ហើយឲ្យផលដោយខ្លួនឯងវិញ កម្មនោះឈ្មោះថា ឧបបីឡកកម្ម ។

ឧបបីឡកកម្មនោះ ខាងកុសលក៏មាន ខាងអកុសលក៏មាន ។ ឧបបីឡកកម្មខាងកុសល បើអកុសលកម្មកំពុងតែឲ្យផល ក៏កាត់ផលនៃអកុសលកម្ម ឲ្យផលដោយខ្លួនឯងវិញ ។ ឧបបីឡកកម្មអកុសល កាលកុសលកម្មកំពុងតែឲ្យផល ក៏កាត់ផ្តាច់នូវផលនៃអកុសលកម្ម ហើយឲ្យផល

ដោយខ្លួនឯងវិញ ប្រៀបដូចដើមឈើពន្លកឈើនឹងពន្លកស្មៅ ផងឈ្ងួយស្រ វា ភិឈ្ងួយស្រវា បុគ្គលណាមួយ មិនចង់ឲ្យដើមឈើ ឬស្មៅដុះដាល ឡើងទេ គប្បីកាត់ដោយសស្ត្រាឬដំដោយដំបង ដើមឈើ ពន្លកឈើ នឹងស្មៅវល្លិនោះ មិនអាចនឹងដុះដាលឡើងដូច្នេះ កុសលំ វ បច្ចុមានំ កាលកុសលកម្មកំពុងតែឲ្យផល អកុសលកម្មក៏កាត់ផលនៃកុសលកម្ម ចេញ គឺមិនឲ្យកុសលកម្មឲ្យផលបាន ។

ម្យ៉ាងទៀត កាលអកុសលកម្មកំពុងឲ្យផល កុសលកម្មក៏កាត់ផល នៃអកុសលកម្មចេញ គឺមិនឲ្យអកុសលកម្មឲ្យផលកើត មានឧបមេយ្យ ដូច្នោះ តត្ថ សុនក្ខត្តស្ស អកុសលកម្មំ បណ្ដាបុគ្គល ទាំងឡាយនោះ អកុសលកម្មនៃសុនក្ខត្តលិច្ឆវីកាត់ផលនៃកុសលកម្មចេញ ហើយ អកុសលកម្មឲ្យផលដោយខ្លួនឯងវិញ មិនឲ្យកុសលកម្មឲ្យផល កើត មានដំណាលថា ៖

សុនក្ខត្តលិច្ឆវី ដើមដំបូងជាមនុស្សជ្រះថ្លាក្នុងព្រះបវរពុទ្ធសាសនា ទើបមកសូមបព្វជ្ជាក្នុងសំណាក់នៃសម្ដេចព្រះបរមសាស្ដាចារ្យ ព្រះអង្គក៏ ប្រទានបព្វជ្ជាឧបសម្បទ ហើយត្រាស់ប្រាប់ព្រះកម្មដ្ឋាន ឲ្យចំរើនព្រះ វិបស្សនា ។ សុនក្ខត្តលិច្ឆវីភិក្ខុនោះបាននូវអភិញ្ញា គឺទិព្វចក្ខុញ្ញាណ ហេតុព្រះពុទ្ធអង្គប្រទាននូវន័យ បានទិព្វចក្ខុញ្ញាណនោះដោយឆាប់រហ័ស លុះបានទិព្វចក្ខុញ្ញាណហើយ ក្រាបទូលសូមនូវបរិកម្មការនោ ក្នុងទិព្វ

ៗសោកតទៅទៀត ។ ព្រះពុទ្ធអង្គក៏ប្រទានឲ្យតាមពាក្យនៃព្រះសុនក្ខត្តលិច្ឆវី ។ នោះធ្វើបរិកម្មភាវនាជាយូរយារប្រមាណបានបីឆ្នាំ ព្រះមានព្រះភាគមិនបានប្រទាននូវន័យ ។ ព្រះសុនក្ខត្តលិច្ឆវីមិនបាននូវទិព្វសោតតាមសេចក្តីប្រាថ្នា ទើបត្រិះរិះថា សម្តេចព្រះមានព្រះភាគនេះប្រហែលជាទ្រង់ជ្រាបតែត្រឹមទិព្វចក្ខុប៉ុណ្ណោះទេ កាលប្រាប់ឲ្យបរិកម្មក្នុងទិព្វចក្ខុនោះ ទ្រង់ប្រទានន័យឲ្យឧបាយប្រៀបប្រាយឲ្យឱកាសដល់យើងមានប្រការផ្សេង ៗ យើងក៏បានដោយឆាប់រហ័ស លុះមកដល់ទិព្វសោត យើងបរិកម្មមកអស់ចំនួនបីឆ្នាំហើយ ព្រះពុទ្ធអង្គមិនបានត្រាស់ប្រាប់ឧបាយប្រៀបប្រាយឲ្យឱកាសសោះ បើព្រះអង្គស្គាត់ជំនាញទិព្វសោតក្នុងព្រះហឫទ័យ ក៏មុខជាប្រាប់ឧបាយឲ្យយើងដឹងមិនខាន នោះព្រះអង្គបានអភិញ្ញាត្រឹមតែទិព្វចក្ខុប៉ុណ្ណោះ កាលព្រះសុនក្ខត្តលិច្ឆវីកំណត់សំគាល់មាំក្នុងចិត្តដូច្នេះហើយ ក៏ប្រាប់លាសិក្ខានឹងប្រាប់លាព្រះរតនត្រ័យថា ខ្ញុំព្រះអង្គនឹងលះបង់នូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃ នឹងលះបង់នូវសិក្ខាហើយ ព្រះមានព្រះភាគបូរជើងចុះថា ខ្ញុំព្រះអង្គមិនបានប្រតិបត្តិក្នុងព្រះពុទ្ធសាសនាតទៅទៀតទេ នឹងសូមជាគ្រហស្ថប្រតិបត្តិខាងក្រៅព្រះពុទ្ធសាសនាវិញ ។ សុនក្ខ-ត្តលិច្ឆវីនោះលាសិក្ខាបទហើយ ក៏ទៅកាន់សំណាក់នៃគ្រូឈ្មោះថានិគ្រន្ថនាដបុត្រ ប្រតិបត្តិសិក្ខារបស់តិរ្ថិយ៍ ។ លិច្ឆវីនោះក៏ពប់បួលក្នុងពួកតិត្ថិយបក្ខៈ ហាមមិនឲ្យឧបសម្បទក្នុងព្រះពុទ្ធសាសនាទៀត ។

មានបុព្វកម្មនៃសុនក្ខត្តលិច្ឆវីនោះថា ក្នុងអតីតកាលជាមនុស្សមានផ្ទះនៅជិតព្រះវិហារ ថ្ងៃមួយ សាមណេរទៅលេងដលអោរជិះទូក បុរសនោះជ្លូតទឹកនៅមាត់កំពង់ ឃើញសាមណេរអុំទូកមកជិត ក៏កើតចិត្តខឹងទើបបាចទឹកទៅលើសាមណេរ ៗ សាមណេរខ្លាចទទឹក ខំគេចចេញពាល់តែឃ្លោងទូកលិចក្នុងទឹក ៗ សាមណេរខ្លាចស្លាប់ និយាយសំដីត្រគោះបោកបោះឲ្យបុរសនោះវាទះត្រចៀកសាមណេរពីរបីដៃ ហើយលើកសាមណេរពីទឹកយកឡើងមកលើប្រាំង ៗ ហេតុកម្មជាអកុសល ដែលខ្លួនទះត្រចៀកសាមណេរឥតទោស បានប្រទូសរាយទឹងសាមណេរអ្នកមានសីល ឲ្យបានសេចក្តីលំបាកសោយទុក្ខវេទនា ៗ

ហេតុដូច្នោះ សម្តេចព្រះបរមសាស្តាទ្រង់ពិចារណាឃើញថាសុនក្ខត្តលិច្ឆវីនោះ នឹងមិនបានទិព្វសោតញ្ញាណទេ ព្រោះកម្មដែលទះត្រចៀកសាមណេរហាមឃាត់ទិព្វសោត បានជាព្រះអង្គមិនប្រទានន័យ ៗ សុនក្ខត្តលិច្ឆវីនោះ បំរើនូវសមណធម៌ ៗ មិនអាចនឹងឲ្យផលបានឡើយ លុះអស់ជីវិតហើយទៅកើតក្នុងនរក គ្មានកំណត់ថានឹងរួចពីនរកនៅគ្រាណាទេ អកុសលកម្មកាត់ផលកុសលកម្មបាន ដ្បិតកម្មរបស់សុនក្ខត្តលិច្ឆវីនោះជាកម្មធំ ព្រោះទៅពេញចិត្តប្រតិបត្តិតាមតិរ្ថិយនិគ្រន្ថជាមនុស្សមិច្ឆាទិដ្ឋិដ៏ទៀងទាត់ ៗ អកុសលកម្មនៃសុនក្ខត្តលិច្ឆវីនោះជាឧបបីឡកកម្ម គឺបៀតបៀននូវកុសលកម្ម មិនឲ្យកុសលកម្មឲ្យផលបាន ៗ

(នៅមានត)

# វិធុរជាតក

ឥមោគតស្ស បណ្ឌុ កិសិយាសិ ទុព្វលាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ បញ្ញាបារមឹ អារព្ភ កថេសិ ។ ភោសា ធវោ បពិត្រសាធុសប្បុរសផងទាំងឡាយអើយ សត្ថា នោះ សត្ថវ- ហោ សត្ថានាយកោ វព្រះអង្គដ៏ជានាយក តែងនាំសត្វផងទាំងឡាយ គៀរប្រមូលបញ្ចូលទៅកាន់អម្រិតបូរីស្រីមហានគរនិព្វានដ៏ជាស្ថានបរមសុខប្រសើរ វិហរន្តោនោះ ចតូសុ ឥរិយាបថេសុ វិសជាមេន្តោ ក៏ព្រះអង្គសម្រេច សម្រាន្តនានូវព្រះឥរិយាបថស្រគត់ ព្រះអង្គមានបួនមិនឲ្យជួនសទ្ទិះ ចិត្តសត្វផងទាំងឡាយឡើយ ជេតវនេ ពួកពាកមនាមហៅព្រះស្រីជ័យជេតពន មហាវិហារ អារព្ភនោះ អារម្មណំ កត្វា ទើបព្រះអង្គធ្វើឲ្យអារម្មណ៍បានតិច បញ្ញាបារមី និងប្រាជ្ញាបារមីវិសេស កថេសិនោះធម្មំទេសេសិ ទើបព្រះអង្គសម្តែងនូវធម្មទេសនា ឥទំ វិធុរជាតកំ នេះនូវនិទាន និយាយដំណើរដំណាលកាលពោធិសត្វ ព្រះអង្គអន្ទោលទៅមកក្នុងវដ្តសង្សារត្រកាល យោនយកកំណើត កើតជាពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមហៅព្រះពិធូរបណ្ឌិត អាទិតោ ជាបនេន អត្តជា ឧបលក្ខិតំ ព្រះអង្គកត់សំគាល់នូវព្រះគាថានេះ ថា បណ្ឌុ កិសិយាសិ ទុព្វលាតិ នេះហោង គិតជាដើមបទកំណត់អក្សរបវរគាថា ឯនិយាយនិទានព្រះពិ

ជួរជាតកនេះ ឯកាទិវសំ ហិ ភិក្ខូ ធម្មសភាយំ កថំ សមុដ្ឋាបេសុំ ។ បពិត្រអើយ មានកាលសម័យថ្ងៃមួយ អស់ភិក្ខុសង្ឃអង្គអរហន្តា ខីណាស្រពផងទាំងឡាយ សឹងស្រេចស្រួល បបួលគ្នាទៅជុំនុំនៅធម្មសភាសាលា មានភិក្ខុមួយអង្គគង់នៅឯនោះ មានព្រះពុទ្ធដីកាទៅអស់ភិក្ខុកំឡោះផងទាំងឡាយថា អាវុសោ វត សត្ថា មហាបញ្ញោ ថាម្នាលអាវុសោភិក្ខុទាំងឡាយ នាព្រះដ៏ជាគ្រូនៃយើងនេះ ព្រះអង្គមានព្រះប្រាជ្ញានោះ ក្រៃក្រឡាមហាប្រថពី ព្រះអង្គមានប្រាជ្ញានោះធាប់ក្រៃក្រៃលែង និងកជហាស្យវិញ ព្រះអង្គមានប្រាជ្ញានោះតែងជាសំរើបសំរួលអស់ចិត្តសត្វផងទាំងឡាយ ព្រះអង្គមានប្រាជ្ញានោះស្រួចមុតថ្លាក្រៃលែង និងលំពៃងពន្លឺកវុធមាកធិកជ ព្រះអង្គមានប្រាជ្ញានោះតែងទិងទំលាយនូវ មិច្ឆាទិដ្ឋិទ្រុស្តផងទាំងឡាយ ព្រះអង្គមានប្រាជ្ញានោះជ្រៅក្រៃលែងទឹងជំពោមមហាសមុទ្រ ព្រះអង្គមានប្រាជ្ញានោះក្រាស់ក្រៃនាប់ តែងទឹងបុកបែនញីញាំមករនៀនូវ ប្រាជ្ញា អ្នកផងដទៃ មិនឲ្យទើសទាល់បានឡើយ ទោះមហាក្សត្រអ្នកប្រាជ្ញបណ្ឌិត ព្រាហ្មណ៍ព្រទ្ធ គវីបុរោហិតផងទាំងឡាយ បេះនូវអាប្រស្នាសុខុមលាក់លបកំបាំង ប៉ុន្មានៗ ក្តីមកជណ្តឹងព្រះអង្គ ។ យកប្រាជ្ញាវិសេសអាចជ្រះទំលុះទំលាយ នូវបំណងអ្នកផងនោះ មិនឲ្យមានទើសទាល់ សល់ជំពាក់នឹងអ្នកឯណាឡើយ ហើយព្រះអង្គឲ្យនាក់ទោន ដំបូន្មានប្រដៅ អស់អ្នកទាំងអម្បាលនោះអំពីសម្បត្តិ

និព្វាន ឲ្យផ្ចិតផ្ចង់ដំរង់ស្មារតី ទទួលយកនូវបញ្ចសីលទាំង ៥ ប្រពៃ នូវព្រះត្រៃសរណគមន៍ ប្រសើរ ហើយព្រះអង្គដំកល់ អស់អ្នកទាំងអម្បាលនោះក្នុងសម្បត្តិសួគ៌ សម្បត្តិនិព្វានជាស្ថានបរមសុខ ប្រសើរហោងបពិត្រអើយ កាលអស់ភិក្ខុផងទាំងឡាយបបួលគ្នាទៅ និយាយសរសើរដំណើរអំពី ប្រាជ្ញាបារមីវិសេសថ្លៃនៃព្រះដ៏មានបុណ្យ នៅនាធម្មសភា សាលានោះ មិនបាត់ស្ងាត់ឡើយ ឮជ្រួតជ្រាបដរាបទៅដល់ព្រះសោតទិព្វថ្លៃនៃព្រះដ៏មានបុណ្យ ព្រះអង្គជ្រាបអស់ភិក្ខុទាំងឡាយនិយាយសរសើរអំពីប្រាជ្ញាបារមី វិសេសដូច្នេះ ទើបព្រះអង្គទ្រង់ពិចារណាថា ភិក្ខុផងទាំងនោះ សរសើរព្រះប្រាជ្ញាបារមីអញតថាគត ថាជាអស្ចារ្យត្រកាល តែអស្ចារ្យអ្វីណា ក្នុងពេលដែលតថាគតបានត្រាស់ជាព្រះពុទ្ធនេះ ថាបើប្រាជ្ញាជាអស្ចារ្យត្រកាលក្រៃនោះ កាលអញតថាគតយោនយកកំណើតកើតជាពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមហៅ ព្រះពិធូរបណ្ឌិតនោះ ទើបហៅថាអស្ចារ្យត្រកាលក្រៃអេះ បើដូច្នេះគួរអញតថាគតនឹងលីលាទៅកាន់ជំនុំអស់ភិក្ខុផងបន្តិចអេះ ថាបើអញមិនទៅកាន់ទីជំនុំភិក្ខុផងឥឡូវនេះឡើយណា អញតថាគតយោនយកកំណើតកើតជាព្រះពិធូរបណ្ឌិតនឹងបាត់ស្ងាត់ទៅសូន្យសោះទទេហោង ។ ព្រះអង្គទ្រង់ព្រះចិន្តានូវប្រការអម្បាលនោះហើយ ទើបស្តេចលីលាទៅស្រង់នូវទឹកអប់ត្រឡប់នូវគន្ធពិដោរស្រេចហើយ ស្តេចទ្រង់នូវស្បង់មានពណ៌ស្រស់ល្អដូចផ្កាព្យាទទឹម

ហើយទើបស្តេចយកនូវព្រះកាយពន្ធមកវណ្ណព្រះអង្គ ដ៏មានពណ៌នោះដូចផ្លេកបន្ទោរ ប្រវាត់ពព្រាតនៅលើកំពូលភ្នំព្រះសុមេរុបពិតកជ ទើបព្រះអង្គទ្រង់ព្រះត្រៃចីវរឈ្មោះមហាបង្សុកូល យ៉ុំត្រលុំស្រេចហើយ ស្តេចសីហនាទគគាតចេញអំពីព្រះសុគន្ធកុដិស្រីសយនាក្រឡាព្រះបន្ទំ ទៅកាន់ជំនុំអស់ភិក្ខុផងទាំងឡាយ ស្តេចឡើងលើធម្មាសន្ន គឺអ្នកក្រាលនូវកំពលទៀមចំព្រៃព្រំសឹងជំទិញទទន់ល្ហុនប្រសើរ ហើយមានព្រះពុទ្ធដិកាជណ្តឹងអស់ភិក្ខុសង្ឃអង្គអរហន្តទាំងណាស្រពផងទាំងឡាយថា ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ ហេតុអ្វីអ្នកទាំងឡាយ កំស្រើបស្រួលបបួលគ្នាមកអង្គុយស្រដីនិយាយមិនគ្រាជាស់ឡើងចេញទៅទីដទៃ រកចំរើនមេត្តាភាវនាប្រាថ្នាឲ្យបានសម្បត្តិមគ្គផលដល់និព្វានប្រសើរៗ ទើបអស់ភិក្ខុផងទាំងឡាយ សឹងលើកនូវកំបង់អញ្ជលីដាក់លើសេរសោភាគ្នា ហើយក្រាបថ្វាយបង្គំប្រណម្យទូលថា ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ យើងខ្ញុំមកជំនុំគ្នានៅនាសភាសាលានេះ មិនស្រដីសរសើរអំពីសម្បត្តិឥទ្ធិព្រហ្មបរមចក្រពត្តិកជឡើយ យើងខ្ញុំមិនអាចស្រដីអំពីឥត្ថិភាព បុរិសភាព គឺរូបស្រីប្រុស ឲ្យខុសជាមន្ទិលក្នុង ព្រះសាសនាព្រះអង្គនោះគ្មានឡើយ យើងខ្ញុំស្រដីតែអំពីដំណើរព្រះប្រាជ្ញាបារមីវិសេសព្រះអង្គដ៏ជាមកុដកពត្រៃ នៃយើងខ្ញុំនេះឯង ទើបព្រះដ៏មានបុណ្យព្រះអង្គមានព្រះបន្ទូលថា ហៃអាវុសោភិក្ខុផងទាំងឡាយអើយ នាព្រះបារមីអញ

តថាគតនេះ មិនជាអស្ចារ្យប្រាកដអ្វីឡើយ នេះហៅថាវិស័យព្រះពុទ្ធ
ទាំងឡាយ បើបានត្រាស់ប្រាជ្ញាសព្វេជ្ញុតញ្ញាណ ជាព្រះពុទ្ធប្រាកដ
ដូចអញតថាគតហើយ ក៏សឹងមានប្រាជ្ញាបារមី តែងទឹងវាត់ទំលាយ អន្ស
គិរីយ៍ផងហើយ បន្ទោបង់នូវសន្និះកន្លា នៃទេវតាតូចធំ ឥន្ទព្រហ្មនាគរាជ
យក្ខ គន្ធព្វ អាសុរ មហាក្សត្រាធិរាជ អ្នកប្រាជ្ញផងទាំងឡាយ កិក្ខុ
អើយ ថាបើសរសើរប្រាជ្ញាបារមីអញតថាគតអស្ចារ្យត្រកាលក្រៃលែង តែ
កាលតថាគត អន្លោលទៅមក យោនយកកំណើតកើតជាពោធិសត្វមួយ
ព្រះអង្គទ្រង់ព្រះនាមហៅថា បៅពិធូរអ្នកប្រាជ្ញ អាចឲ្យដំបូន្មាន យក្ខសេ
នាបតីមួយឈ្មោះបណ្ណកយក្ស នៅនាកំពូលភ្នំកៃលាសគិរីបពិត ប្រាកដ
មានកំពស់ ៦ យោជន៍ ដោយប្រាជ្ញាអាត្មាអញ ឲ្យយក្សនោះទិកសបង់
ហើយផ្តល់ឲ្យជីវិតជាទានផងទឹងសាងសន្សំ ព្រះបារមីពោធិសម្ភារ ទឹងឲ្យ
បានត្រាស់ ប្រាជ្ញា សព្វេជ្ញុតញ្ញាណជាព្រះពុទ្ធប្រាកដ កាលនោះជា
អស្ចារ្យក្រៃ ៗ តណ្ហី អហោ សិ ព្រះអង្គបន្ទូលតែមួយព្រះឱស្ឋដូច្នោះ
ហើយ ស្តេចបញ្ឈប់ព្រះពុទ្ធដីកា គង់ស្ងៀមវិញហោង ទើបពាក្យចំណោទ
ថាអ្នក ការណ៍ហេតុអ្វីព្រះដ៏មានបុណ្យ ព្រះអង្គមានព្រះបន្ទូលតែមួយ
ព្រះឱស្ឋពីរព្រះឱស្ឋ ម៉្លោះហើយក៏បញ្ឈប់ព្រះពុទ្ធដីកាគង់ស្ងៀមវិញ ធម្មទេ
សនាអស់តែម៉្លេះឯង ឬមួយព្រះអង្គខ្ជិល ៗ ពាក្យចំឡើយថាបពិត្រ អ្នកអើយ
អ្វីក៏ព្រះអង្គនឹងមានខ្ជិលឡើយ ហើយធម្មទេសនាព្រះអង្គសោត ទាំង

៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ហើយមានព្រះបន្ទូលតែមួយព្រះឱស្ឋពីរព្រះឱស្ឋម្ដោះក្បែរថាធម្មទេសនានោះអស់ដូច្នោះ ៗ ពោលថាបើព្រះអង្គមិនខ្វល់ឡើយ ហើយធម្មទេសនាព្រះអង្គថាមិនអស់ ដ្បិតអ្វីក៏ព្រះអង្គមិនសម្ដែងថ្លែងធម្មទេសនាឲ្យឆ្ងាយទូលាយទៅហ៎: ឆ្លើយថា ទាព្រះអង្គមិនសម្ដែងឲ្យឆ្ងាយទូលាយទៅនោះ ក៏ព្រះអង្គទ្រង់រមិលមើលកំណើតសត្វផងទាំងឡាយ សត្វឯណាចូលចិត្ត សត្វឯណាពុំចូលចិត្តនឹងធម្មទេសនា ថាបើសត្វឯណាចូលចិត្តនឹងធម៌វិសេសហើយ សត្វនោះសឹងត្រេកអរសរសើរថា ឱព្រះពុទ្ធអើយ ព្រះអង្គទេសនាពិរោះអ្វី មាលព្រាយហ: សត្វឯណាបើសរសើរធម្មទេសនាដូច្នោះហើយ រីសត្វនោះស្មើបានឡើងស្ថិតលើក្រឡាទីនាំងកដរថ ទឹងអណ្ដែតត្រសែតឡើងទៅសម្បត្តិសួគ៌ សម្បត្តិទិព្វាននោះទៀងប្រាកដហោង សត្វឯណាបើបានឮធម្មទេសនាហើយ ខ្ញៃប្រកិះជៀលធម្មទេសនាហើយ រីសត្វនោះស្មើធ្លាក់ដែកដុលប៉ុនដើមត្នោតនោក ហើយទៅហែលទឹកសមុទ្រធំក្រៃ ហែលតែខ្លួនទទេម្ដេចខ្លាសៗ ដ្ឋះទិងរូបពុំរូប ចំណង់បើធ្លាក់ចាំងដែកដុលផងសោត តែងទឹងនាំសាត្ដាលិចលង់ទៅក្នុងអន្ទង់ជ្រៅ ពោលគឺភពវដ្ដសង្សារនោះប្រាកដហោង បើដូច្នោះ ហាក់ដូចព្រះអង្គទេសនានាំសត្វទៅនរកវិញ ហេតុដូច្នេះឯង ទើបព្រះអង្គមានបន្ទូលតែមួយព្រះឱស្ឋពីរព្រះឱស្ឋជាហេតុបន្តិចហើយ ព្រះអង្គបញ្ឈប់ព្រះពុទ្ធដីកាស្ងៀមនៅចាំ បើមានអ្នកឯណាមួយសូម

អារាធនា និមន្តព្រះអង្គ ទើបព្រះអង្គសម្តែងថ្លែងឲ្យធ្លាយទូលាយទៅហោង។ កាលនោះ អស់ភិក្ខុផងទាំងឡាយ សឹងលើកកំបង់អញ្ជលីដាក់លើសិរសាអាត្មាទីទៃ ៗ ហើយក្រាបថ្វាយបង្គំប្រណម្យ សូមអារាធនាធម្មទេសនាថា ករេត្ត ភគវា បពិត្រព្រះដ៏មានបុណ្យ ព្រះអង្គអាចប្រួតជ្រះទំលាយនូវចំណងវដ្តសង្សារផងទាំងឡាយហើយ នាព្រះអង្គមានបន្ទូលអម្បាញមិញថាព្រះអង្គយោនយកកំណើតកើតជាពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមហៅចៅពិធូរអ្នកប្រាជ្ញនោះ សូមព្រះអង្គយកព្រះប្រាជ្ញាញាណវិសេស ១ ឈ្មោះបុព្វេនិវាសានុស្សតិញាណនោះ ទៅឧបក្រសាប អស់ខ្ទួសន្តានធម៌ទាំងឡាយ មកសំដែងសណ្តាប់ប្រាប់អស់យើងខ្ញុំផងកាលឥឡូវនេះ ៗ ទើបព្រះដ៏មានបុណ្យ ព្រះអង្គទទួលយកនិមន្តអស់ភិក្ខុផងទាំងឡាយ ព្រះអង្គយកព្រះប្រាជ្ញាញាណវិសេសមកដំកល់ទុកក្នុងហឫទ័យ ហើយព្រះអង្គបើកព្រះឧស្ឋប្រាលន្ទាលបីដូចរត្តកម្ពល បញ្ចេញនូវព្រះសូរសៀងនោះ មូលក្រាងក្រអៅជ្រៅជ្រះផ្អែមល្ហែមពីរោះសោះសាទបមាបីដូចសូរសម្លេងព្រហ្ម ឧត្តមប្រសើរដំណើរដំណាលកាលព្រះអង្គទ្រង់ធម្មទេសនាកន្លងរំលងទៅហើយនោះ បន្ទូលថា អតីតេ ភិក្ខវេ កុរុរដ្ឋេថា ម្នាលភិក្ខុផងទាំងឡាយអើយ ភិក្ខុអើយ នាកាលភពកាន់កប្បកាលទាំងកំបាំងបាត់ស្ងាត់រំលងកន្លងយូរទៅហើយនោះ មានមហាក្សត្រាធិរាជ ១ ព្រះអង្គទ្រង់ព្រះនាមហៅព្រះបាទធនញ្ជយកោរព្យរាជ សោយរាជសម្បត្តិ

នៅនាឥន្ទបត្ថបុរីស្រីមហានគរ មានក្នុងវង់វង្សនោះឯង ហើយមហាក្សត្រ
នោះមានអាមាត្យមួយឈ្មោះពៅពិធូរអ្នកប្រាជ្ញ ក៏តែងទឹងប្រដៅអាថិ
ធម៌សេចក្តីលោកិយលោកាវោហារគិតការចេញចូលសព្វថ្ងៃមិនបីក្រទឹង
ពៅពិធូរអ្នកប្រាជ្ញនោះឡើយ ហើយពៅពិធូរអ្នកប្រាជ្ញ ក៏តែងទឹងសម្តែង
ធម្មទេសនានោះផ្អែមល្ហែម ពិរោះសោះសាមហិមាក្រពេក តែងល្អង
លោមអស់ស្តេចអំឡុងសកលទ្វីបមកនៅចាំស្តាប់ធម្មទេសនានោះ ហើយ
មហាក្សត្រទាំងអម្បាលនោះ មិនអាល័យមមៃមមាញឹករវូក ទៅកាន់រាជ-
សម្បត្តិ និវត្តព្រះនគរបវររាជសេមាទីខ្លៃ ៗ ឡើយ នាអស់មហាក្សត្រ
ទាំងអម្បាលនោះ មិនអាល័យចង់ទៅកាន់រាជសម្បត្តិនោះ តើទីងគណនា
ឧបមាដូចអ្វី ជាដូចដំរីផងទាំងឡាយ ក៏លុះចេញអំពីព្រៃហានកខ្ទង
លុះលែងអាត្មាទីខ្លៃ ៗ ហើយ ក៏មកចង់ស្តាប់សព្ទពិណព្រះបាទទៈទេទរាជ
នោះពិរោះសោះសា មិនអាល័យទៅព្រៃស្ពានកខ្ទង លុះលែងអាត្មាទីខ្លៃៗ
នាពៅពិធូរអ្នកប្រាជ្ញសម្តែងធម្មទេសនា ជាសណ្តាប់អស់មហាជនផងទាំង
ឡាយនោះ មិនយល់ជាពៅពិធូរអ្នកប្រាជ្ញនោះឡើយ យល់ហាក់ដូចដំ
ណើរព្រះពុទ្ធ ព្រះអង្គសម្តែងធម្មទេសនាជាសណ្តាប់នៃទេវតា មនុស្សសត្វ
ផងទាំងឡាយ រីពៅពិធូរនោះសោត ប្រកបទូវយសសក្តិ ចំរើនរុងរឿងនៅ
ក្នុងវង្ស ឥន្ទបត្ថបុរីស្រីមហានគរនោះហោង បពិត្រអើយ អធិប្បាយនិយាយ
នេះយើងសណ្ឋិតទុកទូវនេះស្វះស៊ិន យើងទីងសម្តែងថ្លែងនិយាយមួយ

វិញទៀត កាលនោះមានព្រាហ្មណ៍ ៤ នាក់ មានទ្រព្យសម្បត្តិនោះច្រើន ជាមិត្រសំឡាញ់និត្យនៅពាកណណាបូរីស្រីមហានគរ រីព្រាហ្មណ៍ទាំង ៤ នាក់នោះ លុះដល់ផុតចាស់ហើយ សន្ធារនោះពុំទៀងឡើយ ហើយបបួលគ្នាចេញទៅអំពីនគរនោះ ហើយដើរចូលទៅក្នុងព្រៃហេមពាន្ត បួសជាតាបសមហាឫស្យី បង្កើតនូវអភិញ្ញាសមាបត្តិ ហើយតែងនឹងស្វែងរក ផ្លែឈើ មើមឈើ មកបរិភោគសព្វថ្ងៃជាចំណីអាហារពុំដែលដាច់ឡើយ នៅជាកំឡុងទៅ រីតាបសទាំង ៤ នាក់នោះ មានចិត្តចង់រកបិណ្ឌបាតបាយគេឆាន់ហោង លុះព្រឹកឡើងហើយ តាបសទាំង ៤ អង្គនោះនាំគ្នាដើរចេញអំពីព្រះពន្លឺឡាន ចូលទៅកាន់ចំបាកនគរ ប្រយោជន៍ដើម្បីនឹងស្វែងរកបិណ្ឌបាតបាយគេ រីក្នុងនគរនោះ មានកុដុម្ពិក ៤ នាក់ជាមិត្តសំឡាញ់ផងគ្នា កាលបើបានយល់តាបសទាំង ៤ អង្គ សឹងដីប្រកបនូវសិរីយាបថស្រគត់ស្រគំដើរយចូលទៅផ្លូវច្រះហើយ រីកុដុម្ពិកទាំង ៤ នាក់សឹងដីមានចិត្តត្រេកអរជ្រះថ្លាសទ្ធាចុះអំពីផ្ទះអាត្មាទីទៃ ១ ទៅថ្វាយបង្គំសូមទទួលភាជន៍បាយអំពីដៃតាបសទាំង ៤ នោះ ហើយនាំយកមួយទៅកាន់ផ្ទះអាត្មាទីទៃ ១ ហោង កាលបើបានទៅដល់ផ្ទះអាត្មាហើយសឹងដីប្រប្រដាប់ចង្ហាន់ ប្រគេនឲ្យឆាន់ស្រេចទៅហើយ មកស្រដីផ្តាំផ្ញើពាក្យថា បពិត្រព្រះតាបសទាំង ៤ ព្រះអង្គអើយ តាំងដើមអំពីថ្ងៃនេះទៅសូមអាកាធនានិមន្តមកផ្ទះយើងខ្ញុំសព្វថ្ងៃ ១ ហោង ៗ រីតាបសទាំង ៤ អង្គ

នោះ សឹងទទួលពាក្យប្រដៅពីកុដុម្ពិកទាំង ៤ នាក់នោះ ហើយលាទៅនៅនាព្រៃឧទ្យាន ចំរើនមេត្តាភាវនា ហើយតែងមកកាន់ផ្ទះកុដុម្ពិកទាំង ៤ នោះ ពុំដែលដាច់ឡើយ តាបសទាំង ៤ អង្គនោះតាបស ១ អង្គ ទៅធ្វើសំណឹងថ្ងៃនៅឰដ៏ពិភពត្រៃត្រឹង្ស រីតាបស ១ អង្គ ទៅធ្វើសំណឹងថ្ងៃនៅឰដ៏ពិភពនាគនាយ រីតាបសមួយអង្គទៅធ្វើសំណឹងថ្ងៃនៅឰដ៏ពិភពសុបណ្ណគ្រុឌរាជ រីតាបស ១ អង្គ ធ្វើសំណឹងថ្ងៃនៅឰដ៏ពិភពមិគាជិនឧទ្យានជាឋានព្រះបាទធនញ្ជយកោរព្យរាជ ឯតាបសទាំង ៤ នោះមិញសឹងដ៏រមិលមើលយល់ សម្បត្តិសំបូរណ៍ឥស្សូរស្គាដ៏ឧឡារិកអធិកក្រៃនៃព្រះមហាក្សត្រាធិរាជទាំង ៤ នោះ ហើយមកស្រដីសរសើរដំណើរដំណាលកាលអាត្មាបានយល់នោះប្រាប់ទៅឧបាសក តែងបម្រើឧបដ្ឋាក អាត្មាទីទៃ ៗ ទាំង ៤ នោះហោង រីកុដុម្ពិកទាំង៤ នាក់នោះ សឹងដ៏មានចិត្តត្រេកអរជ្រះថ្លាសទ្ធា សង្វាតធ្វើបុណ្យឲ្យទានប្រាថ្នាឲ្យបានទៅកើតជាមហាក្សត្រសោយរាជសម្បត្តិស្ថិតនៅស្ថានពិមាននៃ ដីតុនអាត្មាមកប្រាប់នោះហោង រីកុដុម្ពិកទាំង ៤ អ្នកនោះ កាលបើលែងជាតិអំពីមនុស្ស សឹងបានទៅកើតនៅនាឋានដូចបំណងប្រាថ្នាអ្នកនោះ អាត្មាទីទៃ ៗ ម្នាក់ទៅកើតជាសម្ដេចឥន្ទ្រាធិរាជ ម្នាក់ទៅកើតជាព្រះបាទវិរុណនាគរាជម្នាក់ទៅកើតជាព្រះបាទសុបណ្ណគ្រុឌរាជ ម្នាក់ទៅចាប់បដិសន្ធិនៅក្នុងឧទរបវរព្រះអគ្គមហេសីនៃព្រះបាទធនញ្ជយកោរព្យរាជ នាងទ្រង់គភ៌លុះខែ ១០ គ្រប់បរិបូណ៌ពុំ

យូរឡើយ នាងប្រសូតព្រះរាជបុត្រប្រុស ឲ្យឈ្មោះចៅធនញ្ជយកុមារ កាលនោះហោង ឯព្រះតាបសទាំង ៤ អង្គនោះសោតហោង កាលណាបើលែងជាតិអំពីមនុស្សលោកនេះ សឹងបានទៅកើតនាព្រហ្មលោកនាយហោង រីចៅធនញ្ជយកុមារ កាលណាបើចំរើនធំឡើងហើយ សម្តេចព្រះវរបីតាព្រះអង្គសុគតទៅ ទើបអស់មុខមន្ត្រី សេនាបតីផងអភិសេកព្រះរាជបុត្រនោះឲ្យសោយរាជ្យគ្រងស្នងសម្តេចព្រះវរបីតាជាមហាក្សត្រ ព្រះអង្គទ្រង់ព្រះនាមហៅព្រះបាទធនញ្ជយកោរព្យរាជ សោយរាជសម្បត្តិដោយទូវធម៌ ចិញ្ចឹមអស់អាណាប្រជានុរាស្ត្រផងទាំងឡាយដោយប្រពៃ រីមហាក្សត្រនោះសោត ព្រះអង្គជាប់ក្រសាលនូវល្បែងស្កា ឥតមហាក្សត្រណាមួយ នឹងឈ្នះព្រះអង្គបានឡើយ ហើយព្រះអង្គតែងធ្វើបុណ្យឲ្យទានរក្សាសីល ព្យាយាមចំរើនមេត្តាភាវនាពុំដែលដាច់ឡើយ ហេតុព្រះអង្គស្ថិតដោយនូវជំបូន្មាននៃចៅពិធូរអ្នកប្រាជ្ញនោះហោង ៗ មានកាលមួយថ្ងៃ ព្រះបាទធនញ្ជយ កោរព្យរាជ ព្រះអង្គអាចស្នាតានតាំងសីល៤ឧបោសថហើយបើដូច្នេះអញទៅតាំងសីលនាស្ថានស្ងាត់បន្តិចបានអេះ ស្តេចគិតអម្បាលនោះហើយ ស្តេចលីលាទៅកាន់ព្រៃឧទ្យានស្ថានស្ងាត់គាប់ចិត្តសាងសីលប្រសើរហោង ៗ រីសម្តេចឥន្ទ្រាធិរាជសោត ស្នាតានតាំងសីលបរិសុទ្ធហើយ បន្ទូលថាអញតាំងសីលស្ថានទេវលោកនេះ រាកន្លងអំពល់ពេកបើដូច្នេះអញនឹងទៅតាំងសីលឯមនុស្សលោកនាយ សម្តេចឥន្ទ្រាធិរាជគិត

អម្បាលនោះហើយ  ក៏ហោះទៅកាន់ព្រៃឧទ្យានគង់ស្ថានស្ងាត់គាប់ចិត្ត សាងសីលបរិសុទ្ធហោង  រីព្រះបាទនាគរាជស្មាទានចាំសីលឧបោសថ គិតថា បើអញចាំសីលនៅនេះហើយ  នឹងកើតកង្វល់ពលិពោធនៅនា ពិភពនាគនោះ បើដូច្នេះអញទៅចាំសីលព្រៃឧទ្យាន ស្ដេចគិតអំបាលនោះ ហើយ ឡើងមកអំពីពិភពនាគ មកកាន់ព្រៃឧទ្យាន ស្ដេចគង់សាងសីល ប្រសើរហោង  រីឯព្រះបាទសុបណ្ណគ្រុឌរាជស្មាទានចាំសីលឧបោសថ ហើយ ក្រែងមានកង្វល់ ពលិពោធនាព្រៃរកា ស្រេចហើយ មកកាន់ព្រៃ ឧទ្យានគង់នាស្ថានស្ងាត់  ហើយសាងសីលសមណធម៌ប្រសើរហោង ៗ លុះសម័យថ្ងៃរសៀលហើយ  មហាក្សត្រាធិរាជទាំង ៤ ព្រះអង្គនោះ សឹង ចេញមកអំពីស្ថាន  អាត្មាទៃៗ មកប្រជុំគ្នានាស្រះថ្នល់មង្គលបោក្ខរណី ៗ រីមហាក្សត្រទាំង ៤ ព្រះអង្គរមិលមើលទៅយល់គ្នាទៅមកហើយ  ហេតុ តែជាមិត្រសំឡាញ់គ្នាអំពីមុនមិញ  កាលបើបានយល់គ្នាហើយ  មាន ចិត្តមេត្រីត្រេកអរសោទរព្រមគ្នាផង ធ្វើពាក្យផ្អែមល្ហែមពីរោះ  សួរទទួល គ្នាទៅវិញទៅមកហើយ  ហេតុតែជាមិត្តកាលនោះហោង ៗ  ឯសម្ដេច ឥន្ទ្រាធិរាជ  ព្រះអង្គគង់លើក្រឡាកម្ពលសិលា  រីមហាក្សត្រទាំង ៣ អង្គ នោះ សឹងគង់អាស្នាសំគួរនឹងអាត្មា គង់ដោយលំនៅអាត្មាទៃៗហោង ៗ លំ ដាប់នោះឥន្ទ្រាធិរាជ  បន្ទូលទៅនឹងមហាក្សត្រទាំង ៣ ថា  ព្រះអង្គអើយ នាយើងទាំង ៤ នេះ  សឹងតែមហាក្សត្រសោយរាជសម្បត្តិឋិតនៅនគរទី

ខែ ៗ ហោង ក៏មកចាំសីល នាស្ថានស្ងាត់នេះជាមួយនឹងគ្នា ជាសីលអ្នកឯណាប្រសើរលើស ៗ លំដាប់នោះព្រះបាទពិរុណនាគរាជ ឆ្លើយថាមហារាជ សីលខ្ញុំឯងប្រសើរលើសមហារាជទាំង៣ព្រះអង្គ ព្រះអង្គ ហេតុអ្វីខ្ញុំថាសីលខ្ញុំក៏ប្រសើរនោះ ដ្បិតព្រះបាទសុបណ្ណគ្រុឌរាជនេះ គាត់ជាសត្រូវនឹងខ្ញុំ មិនប៉ុន្តែកាលឥឡូវនេះឡើយ ជាសត្រូវនឹងខ្ញុំប្រចាំកាល វៀងភពជាតមកដល់ឥឡូវនេះ ហើយខ្ញុំបាទយល់ សត្រូវនឹងធ្វើឲ្យខ្ញុំក្ស័យជីវិតហើយ ខ្ញុំមិនខឹងនឹងសត្រូវឡើយ ព្រះបាទពិរុណនាគរាជមិនបន្ទូលទទេឡើយ សូត្រជាបទគាថា ជាប្រឋមដើមបទថា យោ កោបនេយ្យ ករោតិ កោបំ ៗ ថាបពិត្រមហារាជ នាបច្ឆាប់ព្រះគាថាលោកថា នរអ្នកឯណាមួយនោះ ក្សត្រក្តី ក្រស្តក្តី ដ៏មានចិត្តអំណត់អត់មិនខឹងនឹងអ្នកជាសត្រូវនឹងអាត្មា គួរនឹងខឹងនោះ ក៏អ្នកនោះហោង មានធម៌សប្បុរសមិនខឹងដល់ម្តងឡើយ ទោះយោបខឹងក្តីក៏ទុកតែក្នុងចិត្តឯងមិនឲ្យដឹងជាក់ច្បាស់ឡើយ ក៏ហេតុនោះហោង អ្នកប្រាជ្ញលោកសិងសរសើរអ្នកនោះឯងជាស្រមណ៍ឧត្តមថ្លៃព្ជលោកនោះហោង ៗ រីព្រះបាទសុបណ្ណគ្រុឌរាជស្តាប់ហើយឆ្លើយថា មហារាជ សីលខ្ញុំប្រសើរលើសមហារាជទាំង ៣ វិញ ដ្បិតអ្វីខ្ញុំថាសីលខ្ញុំប្រសើរលើស ព្រោះព្រះបាទពិរុណនាគរាជនេះ គាត់ជាចំណីអាហារគ្រកាលខ្ញុំផងនោះ គាត់នៅកណ្តាលប្រវាលភពមហាសមុទ្រ ម្តេចអញខ្ញុំទៅចាប់ឆក់ឆ្លួលយួរយកមក

ជាចំណីអាហារ នេះម្តងបានយល់នូវមុខជាក់ហើយ គួរតែនឹងចាប់ស៊ីជា ចំណីអាហារខ្ញុំ ៗ អត់នូវសំរេកគំលាន ខ្ញុំមិនចាប់ស៊ីឡើយ ខ្ញុំខ្លាចដាច់ សីលខ្ញុំ ហេតុនោះហោង ខ្ញុំថាសីលខ្ញុំប្រសើរហោក់លើស ៗ ព្រះបាទ សុបណ្ណគ្រុឌរាជ បន្ទូលឡោះហើយ សូត្រជាបទគាថាថា : ឱ ជោ ឆាតេ យោ សមាគេ ជីយន្តិ ៗ ថាបពិត្រមហារាជ នរូ អ្នកឯណាមួយមានផ្ទៃ ជិតដល់ឆ្អឹងខ្នង ហើយអាចអត់នូវសំរេកគំលាន ទូន្មានឥន្ទ្រិយមិនមានចិត្តមិច្ឆាទិដ្ឋិ រីអ្នកប្រាជ្ញលោកសឹងសរសើរអ្នកនោះ ជាស្រមណ៍ឧត្តមក្រៃ ក្នុងលោកនេះហោង ៗ លំដាប់នោះ សម្តេច ឥន្ទ្រាធិរាជបន្ទូលថា មហារាជ សីលអញប្រសើរលើស ដ្បិតអញលះបង់ នូវរាជសម្បត្តិ សួគ៌ទេវលោកនាយដ៏ជាបរមសុខ មានប្រការផ្សេងៗ មកចាំសីលក្នុងមនុស្សលោកនេះ ហេតុនោះហោងអញថា សីលអញ ប្រសើរលើសនឹងសីលមហារាជទាំង ៣ វិញហោង សម្តេចឥន្ទ្រាធិរាជ បន្ទូលឡោះហើយសូត្រជាបទព្រះគាថាថា : ខិឌ្ឌំ រតឹ វិប្បជហិត្វា សត្វំ ៗ ថាមហារាជ នរអ្នកឯណាមួយ អាចលះបង់នូវចំណង បញ្ចកាមគុណទាំងពួងនឹងខ្លួន នឹងពាក្យ នឹងចិត្ត មិនស្រដីពាក្យកុហកដល់ តិចឡើយ ហើយវៀរអំពើស្អាងអាត្មាដោយប្រដាប់ប្រដា វៀរអំពើ ហាក់សេព មេថុនធម្ម រីអ្នកប្រាជ្ញផង សឹងតែសរសើរអ្នកនោះ ថា ស្រមណ៍ឧត្តមក្រៃ ក្នុងលោកនេះហោង ៗ ឯព្រះបាទធនញ្ជយកោរព្យ

រាជស្តាប់ហើយ ឆ្លើយថាមហារាជ ខ្ញុំប្រាសលះបង់ព្រះរាជមន្ទីរនូវស្រីព្រះស្នំមួយម៉ឺនប្រាំពាន់ច្រើនណាស់ក្រៃ ឥឡូវនេះខ្ញុំមកកាន់ព្រៃព្រះហេម-ពាន្ត ឲ្យបានសាងសន្សំធម៌ ចាំសីលប្រសើរ នោះយល់ថាសីលខ្ញុំប្រសើរលើស ៗ ព្រះបាទធនញ្ជយកោរព្យរាជ បន្ទូលម្ល៉ោះហើយសូត្រជាបទគាថា ថា: មរិក្តុហំ លោកជម្មញ្ញា សព្វំ ៗ ថាបពិត្រមហារាជ នរអ្នកឯណាមួយដឹងដោយប្រាជ្ញបីប្រការ ហើយព្រមលះបង់នូវសម្បត្តិសម្បូរណ៍ឥស្សូរទ្រព្យរបស់យសសក្តិ ហើយចេះទូន្មានអាត្មាប្រពៃ មិនអាល័យមមៃមមាញឹករលឹកទៅកូនប្រពន្ធ អ្នកប្រាជ្ញផងទាំងឡាយលោកសឹងសរសើរអ្នកនោះថា ជាស្រមណឧត្តមក្រៃពេញលោកនេះហោង ៗ

(នៅមានត)

---

នរជនណា យកធម៌ជាក់ពីមុខ មិនរវល់គិតថា ម្ចាស់ស្រឡាញ់ ឬមិនស្រឡាញ់ ហើយអាចហ៊ានតុះតាវពោលពាក្យមិនជាទីគាប់ចិត្តចំពោះម្ចាស់ផង នរជននោះទុកជាមិត្រព្រះរាជាពិត ៗ

ហិតោបទេស

---

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ ពោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប. ៣.

# គួរតែប្រឡេះភារៈខ្លះចោល

( វិចារណកថា )

លោក ជេង-ជ្រិវ និពន្ធ

មនុស្សពីរនាក់រត់ប្រណាំងគ្នា ម្នាក់ចេះតែឈ្នះ ៗ អ្នកផងចេះតែបន្ទោសអ្នកចាញ់ថាហេតុអ្វីក៏ខ្ជិល មិនហាត់រត់ មិនខំរត់ឲ្យលឿនទាន់គេ បណ្ដោយឲ្យតែចាញ់គេរាល់គ្រា មិនដឹងពេលណានឹងបានជោគជ័យម្ដង ព្រោះខ្លួនក៏អាយុប្រហែលនឹងគេ សុខភាពក៏មានបរិបូណ៌ដូចគេ តើប្រការម្ដេចក៏យ៉ាងនេះ ?

មុនដំបូង អ្នកចាញ់ចេះតែឆ្ងល់នឹងខ្លួនឯងថា មិនគួរបើដូច្នេះសោះ ឬមួយមកពីពូជខ្លួន ឬមួយប្រហែលមកពីខ្លួនគ្មានសំណាងខាងរត់ទេដឹង បានជាខំណាស់ដែរ នៅតែរត់មិនទាន់គេ ៗ លុះដញ្ញឹងនឹងពិចារណារកហេតុផលទៅ ស្រាប់តែលេចពន្លឺចេញមក គឺមកពីខ្លួនស្លៀកពាក់ខោអាវច្រើនស្រទាប់ពេក ប្រាកដជាខោអាវនេះហើយដែលធ្វើឲ្យខ្លួនរត់មិនសូវលឿន ព្រោះណា ខោទើសទែង ណាធ្ងន់ ទាំងនេះហើយជាប្រភពដែលនាំឲ្យ

ខ្លួនជួបប្រទះតែនឹងបរាជ័យ ។

ឥឡូវយើងពិចារណាមើលការវិនិច្ឆ័យនៃអ្នកចាញ់ ដោយសំអាងថាមកតែពីសំលៀកបំពាក់ច្រើនស្រទាប់ ក្នុងឱកាសនៃការរត់ប្រណាំង តើមានសភាពសមហេតុផលឬទេ?

ការវិនិច្ឆ័យនេះ គឺពិតជាត្រូវប្រាកដ មិនបាច់ចាំធ្វើការសង្កេតយូរឡើយ ព្រោះម្នាក់ ខ្លួនស្រាលព្រមទាំងមិនមានវត្ថុអ្វីជាគ្រឿងធ្វើឲ្យរំខានដល់ចលនារបស់ខ្លួន អ្នកនេះត្រូវតែរត់ឈ្នះអ្នកម្នាក់ផ្សេងទៀតដែលមានខ្លួនព័ទ្ធដោយគ្រឿងរំខានជាដរាប ។ ចំពោះរឿងនេះ មិនគួរបន្ទោសអ្នកចាញ់ឲ្យសោះ បើតាមត្រូវ គួរសរសើរទៅវិញ ដ្បិតគ្នាមានសុឆន្ទៈ បានខំបំពេញមុខងារឥតធ្វេសប្រហែស ឯបរាជ័យ មិនមែនមកពីខ្លួនខ្ជិលទេ គឺមានកត្តាក្រៅចូលមករំខានទេតើ ។

សេចក្ដីពណ៌នាខាងលើនេះ ជាឧប្រៀបធៀបនៃសេចក្ដីពិចារណាដោះស្រាយ ស្ដីពីការសិក្សាទូទៅនៅប្រទេសយើង ដើម្បីឲ្យងាយយល់ នឹងឆាប់ចូលចិត្តស្ដាប់បាន ។

ចូរយើងក្រឡេកមើលទៅប្រទេសនានា ក្នុងសាកលលោក ជាពិសេស គឺប្រទេសណាដែលមានវឌ្ឍនភាពបរិបូណ៌ខាងការសិក្សា សំគាល់មើលថាតើប្រទេសនោះៗ តម្រូវការសិក្សាដល់យុវជនរបស់គេ មានប៉ុន្មានបែប ប៉ុន្មានយ៉ាង? តាមខ្ញុំបានដឹង ហើយប្រហែលជាការណ៍ពិតផង វៀរលែងតែប្រទេសឋិតនៅក្នុងអាណាព្យាបាលចេញ យុវជន

ក្នុងប្រទេសណា ក៏មានការតព្វកិច្ចសិក្សាតែភាសាជាតិរបស់ខ្លួនប៉ុណ្ណោះ ។ ចូរក្រឡេកមើលថយក្រោយមុន ក្នុងសម័យដែលបារាំងមិនទាន់ចូលមកក្នុងប្រទេសកម្ពុជា កូនខ្មែរទៅរៀនអក្សរនៅតាមវត្តអារាមនៃព្រះសង្ឃ ក្នុងរយៈពេលតែមួយឆ្នាំ យ៉ាងយូរណាស់ត្រឹមពីរឆ្នាំ ក្មេងនោះចេះអានអក្សរខ្មែរសព្វគ្រប់ គឺថាចេះអានគ្មានទាក់ ឈ្មោះថាអក្សរខ្មែរ ទោះមានជម្រៅសេចក្តីដូចម្តេច ក៏អាចអានបានទាំងអស់ ។ សេចក្តីនេះបញ្ជាក់ឲ្យឃើញថា ការសិក្សាភាសាតែមួយ ចំពោះរូបជនតែម្នាក់ រមែងមានរបឿនយ៉ាងនេះ ។

នៅបច្ចុប្បន្នសម័យ ការចេះអានស្ទាត់នូវភាសាជាតិ មានរយៈពេលយូរបន្តិច ( ៤ឬ៥ ឆ្នាំ ) ការយឺតយូរនេះ បណ្តាលមកពីអ្វី ? ដូចបានពោលមកហើយ គឺបណ្តាលមកពីការសិក្សាវិជ្ជាច្រើនមុខ ហួសកម្លាំងនៃយុវជន ជាពិសេស គឺភាសាបរទេស ជាភាសាដែលយុវជនយើងមិនធ្លាប់ឮ មិនធ្លាប់ស្តាប់ តាំងពីកុមារភាពមក ។ ខ្ញុំយល់ថា គ្រប់សាសន៍ទាំងអស់ក្នុងលោក វៀរលែងតែមនុស្សព្រៃចេញ មិនមានសាសន៍ណាមួយ ប្រសើរជាងសាសន៍ណាមួយឡើយ កុំឲ្យតែសាសន៍នោះមានគេសង្កត់សង្កិន ទប់ខ្សែបង្ហៀរ និយាយនេះគឺចំពោះការសិក្សាវិជ្ជា ។ ភ្ល យ៉ាង យុវជនខ្មែរ កាលក្នុងសម័យអាណាព្យាបាលបារាំង ភាគតិចណាស់ដែលមានវិជ្ជាជាន់ខ្ពស់ ។ តាមដែលខ្ញុំដឹង ក្នុងបណ្តាប្រជាពលរដ្ឋខ្មែរ

ចំនួន៥ លាននាក់ អ្នកដែលមានសញ្ញាប័ត្រមធ្យមសិក្សាប្រហែលមិនដល់ ទាំង១០នាក់ផង អ្នកដែលមានសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ យ៉ាងច្រើន ប្រហែល ១០០ នាក់ ក្នុងរយៈពេល ១ សតវត្ស ។ ទើបមានកើតជាបញ្ហាពាក់ទៀងថា ហេតុដូចម្ដេចក៏ក្នុងសម័យអាណាព្យាបាលបារាំង ជនជាតិខ្មែរមានសញ្ញាប័ត្រមធ្យមសិក្សាតិចម៉្លេះ (សូម្បីចំពោះសញ្ញាប័ត្រ ឧត្ដមសិក្សា) ។ បើតាមការពិសោធន៍ និងការសង្កេត គឺរឿងនេះមក តែពីគេមិនត្រូវការឲ្យយើងរៀន ។

សួរថាបើគេមិនត្រូវការចង់ឲ្យយើងរៀន ហេតុម្ដេចក៏គេបង្កើតសាលារៀន ហើយជួយទំនុកបំរុង មានទាំងឲ្យអាហារូបករណ៍ផង ?

ចំពោះសំនួរនេះ គឺមិនពិបាកនឹងឆ្លើយទេ កិច្ចការទាំងប៉ុន្មានដូចពោលខាងលើ គេធ្វើឡើងដើម្បីតែបំណងតែម្យ៉ាង ។ ឯគំបំណងនោះ នៅត្រង់រកមនុស្សឲ្យជួយគេតែប៉ុណ្ណោះ ដែលនឹងថាចង់ឲ្យយើងក្លាយទៅជាអ្នករៀនត្រឹមត្រូវពិតប្រាកដ ដើម្បីបំរើជាតិ ដើម្បីកសាងជាតិ ដូចព្រះករុណាព្រះបាទសម្ដេចឪយើងនោះ គតអង្គីមានឡើយ ។ ឧបមាដូចអ្នកស្រែចំការបង្ហាត់ប្អូនគោក្របី ឲ្យចេះស្ដាប់ឆ្វេង-ស្ដាំ ឲ្យដឹងថាទៅ-ឈប់ ។ល។ គេធ្វើដូច្នេះ ដើម្បីប្រយោជន៍អ្វី ? ដើម្បីឲ្យគោក្របី មានចិត្តគំនិតជាបែបមនុស្សឬ ? អ្នកណាដែលយល់យ៉ាងនេះ ឈ្មោះថាមានការគាប់ប្រឡំពិត ។ គេបង្ហាត់ប្អូនគោក្របី ដើម្បីគ្រាន់តែ

ឲ្យជួយធ្វើការ ដើម្បីបន្តកម្លាំងគេទៅទៀត ។ សេចក្តីនេះមានឧបមាយ៉ាងណា អាណាព្យាបាលបារាំង ដែលបានបង្ហាត់បង្រៀនយើងក្នុងជាន់នោះ ក៏មានឧបមាមេយ្យដូច្នោះ បានជាគេបង្កើតមុខវិជ្ជាយ៉ាងច្រើន ហើយពិបាកផង ដែលជាហេតុកកាំងគំនិតប្រាជ្ញានៃយុវជនយើង ។

ចុះសម័យឥឡូវនេះ ប្រទេសកម្ពុជាយើង មានឯករាជ្យឬក៏ឋិតនៅក្នុងអាណាព្យាបាល? ខ្មែរណាក៏ដឹងដែរថា កម្ពុជា ជាប្រទេសឯករាជ្យតាំងពីឆ្នាំ ១៩៥៣ ម៉្លេះ ។ ពាក្យថាឯករាជ្យ តើមានប៉ុន្មានប្រការ? ប្រការទី ១ គឺឯករាជ្យខាងនយោបាយ ប្រការទី២ ឯករាជ្យខាងតុលាការ ប្រការទី៣ឯករាជ្យខាងសេដ្ឋកិច្ច ប្រការទី ៤ ឯករាជ្យខាងវប្បធម៌ ។ ចាប់ពីឆ្នាំ ១៩៦៤តទៅ ឯករាជ្យខាងសេដ្ឋកិច្ចខ្មែរមានហើយ ចំណែកឯករាជ្យខាងអក្សរសាស្ត្រវិញ មានសភាពជាក់ច្បាស់ឬទេ ! បើតាមរដ្ឋធម្មនុញ្ញយើង គឺមានចែងត្រង់មាត្រា ៣ ថាអក្សរជាផ្លូវការ គឺអក្សរខ្មែរ ។ តាមសេចក្តីនេះ ឯករាជ្យខាងអក្សរសាស្ត្រមានហើយដែរ ។ ប៉ុន្តែ តាមការសង្កេតគ្រប់មជ្ឈដ្ឋានក្នុងប្រទេស មានសាលារៀនជាដើម ឃើញថាការប្រើអក្សរជាតិ ដូចជាមិនទាន់ពេញលេញ ។ ចំពោះសាលារៀន ចាប់ពីថ្នាក់មធ្យមដ្ឋានឡើងទៅ ភាសាបរទេសចូលមកជ្រៀតជ្រែកជាដរាប ហើយជាការចាំបាច់ផង ។ សព្វថ្ងៃភាសាជាតិក្នុងសាលារៀន មានឥទ្ធិពលតែពីថ្នាក់កុមារដ្ឋានដល់អាទិកដ្ឋានប៉ុណ្ណោះ ។ តពីនេះទៅ ឥទ្ធិពលខ្លួនត្រូវតែប្រដែងនឹងភាសាបរទេស

ហើយថយចុះបន្តិចម្តងៗ ដល់ទីអវសាននៃការសិក្សា នៃយុវជនខ្មែរ ។ ត្រង់នេះជាចំណុចសំខាន់នៃបទពិចារណា ។ គួរសរសើរអ្នកឈ្នះ ព្រោះតែអ្នកនោះមានខួរដែលគ្មានអ្វីមកធ្វើឲ្យរំខានឬ? គួរបង្អាប់បន្តុះអ្នកបរាជ័យ ព្រោះតែអ្នកនោះមានអាត្មាបរិតដោយគ្រឿងរំខានឬ ? តាមយោបល់ខ្ញុំ មិនគួរអ្នកផងពោលសរសើរអ្នកទី ១ ហើយបង្អាប់បន្តុះអ្នកទី ២ ឡើយ ព្រោះគូប្រជែងមានការៈមិនស្មើគ្នា ។ ចូរយើងសង្កេតមើលអ្នកប្រដាល់ក្តី សេះរត់ប្រណាំងក្តី មុននឹងគេយកគូប្រជែងបញ្ចូលក្នុងសង្វៀនប្រឡងរិទ្ធិ គេនិយមថ្លឹងទម្ងន់មើលជាដំបូង លុះតែគូប្រជែងមានទម្ងន់ស្មើគ្នា ទើបគេអនុញ្ញាតឲ្យចូលប្រឡងរិទ្ធិគ្នា ការធ្វើយ៉ាងនេះឈ្មោះថាប្រកបដោយគតិយុត្តិធម៌ ។

តើយើងគួរដោះស្រាយដូចម្តេច ចំពោះការសិក្សាក្នុងកម្ពុជាឯករាជ្យដែលកំពុងត្រូវការអ្នកបច្ចេកទេសច្រើន ឲ្យសមល្មមទៅតាមការកែទម្រង់សេដ្ឋកិច្ចនៃសម្តេចឪ ជាការកែទម្រង់ដ៏ប្រពៃអស្ចារ្យ ។ ឬយើងនៅតែពេញចិត្តចំពោះត្រង់ឲ្យមានពន្ទុកច្រើន តែឥតប្រយោជន៍ ឬក៏ឲ្យមានពន្ទុកមួយ តែបានការ? ខ្ញុំយល់ថា ដើម្បីឆ្លើយតបឲ្យត្រឹមត្រូវល្អនឹងការកែទម្រង់ខាងសេដ្ឋកិច្ចនៃសម្តេចឪ គួរគប្បីតែកែកម្មវិធីសិក្សាជាថ្មី បើមិនដូចនោះទេ មិនងាយនឹងរកអ្នកបច្ចេកទេសឲ្យគ្រប់គ្រាន់ ដើម្បីជួយផែនការសម្តេចព្រះបិតាសេដ្ឋកិច្ចជាតិបានឡើយ ។ យើងឃើញស្រាប់ហើយ

ប្រទេសកម្ពុជា ខ្វះអ្នកបច្ចេកទេសសម្បើមណាស់ ។ តាមការសង្កេត អ្នកបច្ចេកទេសខ្មែរម្នាក់ ត្រូវគ្រប់គ្រងមុខការច្រើនកន្លែង ដែលជាហេតុនាំឲ្យមានការត្រួតពិនិត្យមិនសូវដិតដល់ យូរៗ ឃើញមានគ្រោះថ្នាក់ខាងហិរញ្ញវត្ថុជាតិត្រង់នេះម្តង ត្រង់នោះម្តង ។ល។ គួរឲ្យស្តាយពន់ពេក ដែលយើងនាំគ្នាខំសន្សំតាំងពី ១ សេន ១ កាក់ឡើង ដើម្បីពូនផ្តុំជាសម្បត្តិជាតិ ហើយពេលណាគ្រោះថ្នាក់ខាងហិរញ្ញវត្ថុជាតិកើតមានម្តងគឺកប់រយលាន ដែលអ្នកតូចតាចបានឮហើយ មានសេចក្តីព្រឺទឹងតក់ស្លុតពន់ប្រមាណ ។ ឯគ្រោះថ្នាក់ខាងហិរញ្ញវត្ថុជាតិនេះ បណ្តាលមកតែពីយើងមានអ្នកបច្ចេកទេសមិនគ្រប់គ្រាន់ ។ ការខ្វះអ្នកបច្ចេកទេស បណ្តាលមកតែពីអ្នកសិក្សាជាតិមិនមានកម្លាំងជួនល្មម នឹងបន្តវិជ្ជាឲ្យបានដល់ទីដៅ ។

សួរថា ហេតុអ្វីក៏មិនខំប្រឹងឲ្យទៅដល់ទីដៅ ?

ឆ្លើយថា បានជាទៅមិនដល់ទីដៅ ព្រោះត្រូវអស់ធុងអាគុយ ដោយហេតុមកពីខំប្រឹងក្នុងពេលមុនជ្រុលពេក បើមិនខំប្រឹង រត់មិនទាន់គេដែលជាហេតុបណ្តាលឲ្យមានពាក្យនិន្ទាថាខ្ជូលខ្ជិល ម្ល៉ោះហើយធុងអាគុយត្រូវតែអស់យ៉ាងនេះ នឹងបន្តដំណើរតទៅទៀតពុំបានឆ្ងាយ ។

ដើម្បីកុំឲ្យធុងអាគុយអស់ ត្រូវតែសំចៃ ត្រូវតែកុំផ្ទុកឲ្យធ្ងន់ពេក នេះហើយជាបញ្ហា ដែលត្រូវដោះស្រាយជាបន្ទាន់ទន្ទឹមគ្នានឹងការកែទម្រង់សេដ្ឋកិច្ចជាតិ ។

ចំពោះរឿងនេះ តាមយោបល់ខ្ញុំ គួរគប្បីកែកែប្រែកម្មវិធីសិក្សាទូទៅ ដូចជាសម្តេចឪបានមានព្រះបន្ទូលម្តងរួចហើយ ក្នុងពេលសមាជៈទី១ ទ្រង់ថ្លៃថា ភាសាបរទេស គួរឲ្យសិស្សសិក្សានៅថ្នាក់លើបានហើយ ទី២ ទ្រង់ថ្លែងថា ការសិក្សាភូមិសាស្ត្រ នឹងប្រវត្តិសាស្ត្របរទេសវែងៗពេក មិនជាបានផលអ្វីដល់ជាតិប៉ុន្មានឡើយ ។ ព្រះយោបល់ដ៏ប្រសើរថ្លៃថ្លានេះ តាមមតិខ្ញុំ គឺយោលទៅរកហេតុដូចតទៅៈ ភាសាបរទេស គួរទុកឲ្យសិក្សាដោយឡែក គឺជាបង្កើតវិជ្ជាស្ថានផ្សេង សម្រាប់តែអ្នកស្ម័គ្រក្នុងការសិក្សាភាសា តាំងនេះ មិនគប្បីយកមកបញ្ចូលលាយឡំក្នុងកម្មវិធីសិក្សាទូទៅរបស់ជាតិឡើយ ធ្វើដូច្នេះ ជាតិនឹងអាចមានរបៀបក្នុងការសិក្សាដូចប្រទេសដទៃក្នុងលោកបាន ហើយអ្នកបច្ចេកទេសជាតិ នឹងមានចំនួនគ្រប់គ្រាន់ដល់សេចក្តីត្រូវការនៃកិច្ចការជាតិទាំងឡាយ ជាពិតប្រាកដ ។

សួរថា បើឲ្យសិក្សាតែភាសាជាតិ រហូតដល់ឧត្តមវិជ្ជា តើនឹងយកអ្នកចេះតែភាសាជាតិមកធ្វើជាអ្នកបច្ចេកទេសដូចម្តេចកើត ព្រោះអ្នកបច្ចេកទេស ត្រូវមានវិជ្ជាតែមួយយ៉ាងជាក់ច្បាស់ តាមមែកធាងរបស់វា ដូចជាអ្នកបច្ចេកទេសខាងកសិកម្ម អ្នកបច្ចេកទេសខាងពេទ្យ អ្នកបច្ចេកទេសខាងពាណិជ្ជកម្ម ។ល។ ហើយវិជ្ជាខាងបច្ចេកទេសតាំងនេះសោត សុទ្ធតែឋិតនៅតែក្នុងផ្ទៃនៃភាសាបរទេស ? ។

ឆ្លើយថា រឿងនេះជាការងាយទេ ៗ សព្វថ្ងៃ យើងមានអ្នកបច្ចេកទេសជាតិ ដែលចេះភាសាបរទេសយ៉ាងច្បាស់ ច្រើនស្ទើរគ្រប់វិស័យហើយ ដែរគួរគប្បីតាំងអ្នកទាំងនេះ ជាគណកម្មការខាងប្រែភាសាភ្លាម ហើយប្រែវិជ្ជាបច្ចេកទេសគ្រប់មែកធាងទាំងនេះមកជាភាសាជាតិទៅទុកជាការស្រេច បើមានសុទ្ធនុះហើយ មិនមានអ្វីអាចមកកាំងដំណើរបានឡើយ ៗ កូនខ្មែររៀនភាសាខ្មែរ ទន្ទេញមេលេខជាភាសាខ្មែរ រៀនវិជ្ជាបច្ចេកទេសជាភាសាខ្លួន តាមយោបល់ខ្ញុំ ជាទីឯមានសន្ទុះលឿន ដូចប្រទេសដទៃមិនខាន មិនយូរប៉ុន្មាន អ្នកបច្ចេកទេសជាតិ នឹងមានចំនួនគ្រប់គ្រាន់ដល់ការប្រើប្រាស ដែលជាហេតុបន្ថយយ៉ាងច្រើនជាអតិបរមា នូវថវិកាជាតិ ក្នុងការជួលបរទេសឲ្យមកជួយ ៗ មិនតែប៉ុណ្ណោះសោត គឺធូរដល់ការចំណាយខាងសម្ភារៈថែមទៀត មានក្រដាសជាដើម ៗ ដោយអាស្រ័យការពឹងផ្អែកទៅលើអ្នកបច្ចេកទេសបរទេសច្រើន យើងត្រូវតែប្រើក្រដាសទ្វេ ១ ជាពីរ បើមិនធ្វើយ៉ាងនេះ ជនបរទេសមិនយល់ការណ៍អ្វី ក្នុងកិច្ចកសាងជាតិរបស់ខ្មែរ ៗ

ម្យ៉ាងទៀត តាមការសង្កេតរបស់ខ្ញុំ ភាសាក្នុងកិច្ចការរាជការ ថ្វីត្បិតតែមានចែងក្នុងរដ្ឋធម្មនុញ្ញថា «អក្សរប្រើជាផ្លូវការគឺអក្សរខ្មែរ» ក៏ឋិតនៅដោយភាគច្រើន ជាភាសាបរទេស ៗ សូម្បីក្នុងក្រដាសដែលបោះពុម្ពជាអក្សរជាតិហើយ ក៏អ្នករាជការយើងភាគច្រើន និយមចុះបំពេញតែជា

អក្សរបរទេស ។ ការណ៍នេះសឲ្យឃើញនូវការពេញចិត្តជាអតិបរមា ចំពោះអក្សរបរទេស នៃអ្នកកជការខ្មែរទាំងឡាយជាពិសេស គឺចៅក្រសួងនា ៗ ។ ត្រង់នេះ សូមបើកវង់ក្រចកបន្តិច : បើមានពាក្យអ្វីសរសេរជាអក្សរជាតិ ឯកឧត្តមយើង មិនពេញចិត្តក្រឡេកមើលទេ ត្រូវវាយកណ្តឹងហៅស្មៀនឬលេខហារីមកមើលឲ្យស្តាប់ ឬសង្ខេបជាភាសាបរទេសឲ្យ ផុយទៅវិញ បើពាក្យនោះជាអក្សរបរទេសវិញ អានហើយអានទៀត ពិរោះណាស់ ពិរោះណាស់ បើមានពាក្យថ្មីមួយដែលអាត្មាមិនចេះ ស្ទុះក្រែកបើកវចនានុក្រមភ្លាម ហើយខះក្បាលខ្លួនឯងថាមិនគួរអញមិនចេះសោះពាក្យនេះ ជួនកាលពេញចិត្តពេក កត់ទុកក្នុងកូនសៀវភៅមួយក៏មាន ។ ហើយបើភាសាជាតិវិញ គ្រាន់តែគេបង្កើតពាក្យថ្មីខ្លះ ដើម្បីបង្គ្រប់ក្នុងការប្រើប្រាស ឯកឧត្តមយើង ពោលចាក់ដោតថាយកពាក្យ «បាលីឬសំស្ក្រឹត» មកប្រើ ខាំឡៃតែទើសទែង ។ ហេតុអ្វីក៏ដូច្នេះ ថាមកពីឯកឧត្តមយើង មិនធ្លាប់អានភាសាជាតិតាំងពីកុមារមក ។

ប្រសិនបើមិនកែប្រែកម្មវិធីសិក្សាសាធារណៈ ឲ្យទាន់ពេលវេលាទេ រឿងនិយមភាសានៃអ្នកកជការខ្មែរ នឹងក្លាយទៅជាការប្រកាន់វណ្ណៈដូចនៅសហរដ្ឋអាមេរិកមិនខាន ។ ចូរសង្កេតពិនិត្យឲ្យច្បាស់ចុះ សព្វថ្ងៃកូនអ្នកទ្រើសភាគច្រើន មិនទៅសិក្សាឯសាលារៀនជាតិ លាយឡំជាមួយ

កុមារទូទៅឡើយ គេនិយមទៅសិក្សាឯសាលារៀនបារាំងេស (Descartes) មានខ្លះទៅរៀនឯប្រទេសក្រៅតែម្តង ៗ ចំពោះរឿងនេះ តើគេយល់ថា ភាសាជាតិនឹងភាសាបារាំងេសមានតម្លៃផ្សេងគ្នាយ៉ាងណា ? ខ្ញុំសូមឆ្លើយ ក្លាយថា គឺគេទុកភាសាបារាំងេស ជាភាសាត្រូត ជាភាសានាយក ឯ ភាសាជាតិ ជាទាសភាសា អ្នករៀនចេះភាសានេះ ទោះបីមានជម្រៅ យ៉ាងណា ក៏នៅតែមិនដល់ភាសាបារាំងេសដែលគេចេះតែបន្តិចបន្តួច គឺ ថាអ្នកចេះភាសាជាតិ ត្រូវតែនៅក្រោមបង្គាប់គេជាដរាប ៗ

សួរថា ប្រសិនបើឲ្យអ្នកចេះតែភាសាជាតិ ដឹកនាំកិច្ចការរដ្ឋ ហើយ អ្នកចេះភាសាបារាំងេសត្រូវនៅក្រោមបង្គាប់វិញ តើទៅរួចឬទេ ?

ឆ្លើយថា ក្នុងបច្ចុប្បន្ននេះ ក្លាយៗ បើតាមយោបល់ខ្ញុំ គឺទៅមិនរួច ទាល់តែសោះ ត្បិតវិជ្ជាបច្ចេកទេសផ្សេង ៗ បិតនៅតែក្នុងផ្ទៃភាសា បារាំងេស លុះណាតែរះបារកកាយទម្លាក់នូវវិជ្ជាបច្ចេកទេសទាំងនោះ ចេញមក ហើយបកប្រែបញ្ចូលទៅក្នុងផ្ទៃភាសាជាតិ នោះអ្នកចេះតែភា សាជាតិ ទើបអាចត្រួតពិនិត្យនឹងដឹកនាំកិច្ចការរដ្ឋបាន ៗ ចូរយើងក្រ ឡេកមើល ហើយគួរឲ្យភ្ញាក់សួរថាទេ ប្រទេសឯករាជ្យទាំងឡាយក្នុងសាកល លោក វៀរលែងតែប្រទេសឥណ្ឌៀចេញ ព្រោះប្រទេសនេះមានភាសា ភាសាច្រើនពេក (២២០ភាសា) និយមនិយាយនឹងសរសេរជាផ្លូវការនូវ ភាសាជាតិរបស់គេ គឺថាគេស្រឡាញ់នឹងគោរពកេរ្តិ៍កេរតំណែលបុព្វបុរស

គេ ៗ គួរឲ្យស្ញើចសរសើរណាស់ នូវប្រទេសចិន ដែលមានតួអក្សរច្រើន និងផ្សេង ៗ ដាច់សន្តានពីគ្នា ហើយបើចង់ចេះអានសារពត៌មានចិនត្រូវឲ្យចេះ ២៥០០ ពាក្យ បើចង់ឲ្យទៅជាអ្នកចេះ ត្រូវឲ្យចេះ ៤០០០ ពាក្យ ទោះបីយ៉ាងនេះ ក៏គេចេះនិយាយ ប្រើប្រាស់ភាសាគេសព្វគ្រប់ គ្មានពឹងផ្អែកទៅលើអក្សរបរទេស ក្នុងកិច្ចកសាងជាតិ ទាំងនេះសឲ្យឃើញថា គេស្រឡាញ់ភាសាជាតិគេពន់ពេក គេធ្វើឲ្យអក្សរនិងភាសាគេ មានឯករាជ្យដូចវិស័យដទៃផង ៗ

សរុបសេចក្ដី ប្រទេសកម្ពុជា ដែលខ្វះអ្នកបច្ចេកទេសជាតិ មកពីយុវជនសិក្សាភាសាច្រើន មុខវិជ្ជាក៏ច្រើន ដែលជាហេតុធ្វើឲ្យគ្នាអស់កម្លាំង មុនបានដល់ទីដៅ ដូចដែលខ្ញុំបានពណ៌នារួចហើយ ៗ តាមយោបល់ខ្ញុំ គឺថាហើយជាទៀត គួរគប្បីកែកែប្រែកម្មវិធីសិក្សា ទន្ទឹមគ្នានឹងការកែទម្រង់សេដ្ឋកិច្ចជាតិនៃសម្តេចឪ ដើម្បី ទី ១ ឲ្យមានអ្នកបច្ចេកទេសជាតិគ្រប់គ្រាន់ដល់សេចក្តីត្រូវការនៃជាតិ ព្រោះកាលសម័យកសាងនគរវត្ត ដែលសព្វថ្ងៃគ្មានអ្នកបច្ចេកទេសបរទេសណា អាចធ្វើដូចបាន សម័យនោះគឺគាត់តែងស្ថាបនាឡើងតែដោយស្នាដៃនៃអ្នកបច្ចេកទេសជាតិ ឥតពឹងផ្អែកបរទេសមកជួយឡើយ ទី ២ កុំឲ្យមានគំនិតប្រកាន់វណ្ណៈ ដែលជាហេតុនឹងធ្វើឲ្យមានការក្តៅក្រហាយទៅអនាគត ទី ៣ ឲ្យអក្សរសាស្ត្រនិងភាសាជាតិរីកចំរើននឹងមានពន្លឺស្មើដូចអារ្យប្រទេសឯករាជ្យនានា ទី ៤ ឲ្យមានការធូរស្រាលដល់ថវិការជាតិ ដែលជាហេតុញ៉ាំងជីវភាពប្រជារាស្ត្រឲ្យរឹងរឹតតែប្រសើរតទៅ ៗ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង-ទាត់ រៀបរៀង*

(តមក)

---

អធីឞ្ដ ន បុំ. ការសុំឱវាទពីសំណាក់គ្រូ ។

អធុនា កិ. ឥឡូវនេះ ។

អធុនាតន–នី គុ. ដែលពីឥឡូវនេះទៅ ។

អធុរ ស្ត្រី. ស្ថានការណ៍ដែលមិនមែនជាធុរៈនៃអ្នកនាំ ។

អធូមក គុ. ដែលមានផ្សែងមិនខាន ។

អធ្ឫតិ ស្ត្រី. កិរិយាមិននឹងធឹង ; កិរិយាមិនរឹងប៉ឹង ។

អធ្ឫឞ្ដ គុ. ដែលរឹងមិនមាន ដែលសុភាព ដែលរាបសា ។

អធ្ឫឞ្យ គុ. ដែលឈ្នះមិនបាន ដែលមិនឈ្នះ ដែលកួលមិនចុះ ។

អធៃយ៌ ន បុំ. កិរិយាមិននឹងនួន កិរិយាមិនម៉ឹងម៉ាត់ កំសោយ ។

អធោ មើល អធសិ ។

អធៅត គុ. ដែលមិនលាង ដែលមិនស្អាត ក្រខ្វក់ ។

អធ្យក្ស បុំ. អធិការ អនុរក្ស មេ នាយ ។

អធ្យក្សរម៑ ក្រិ. វិ. តាមព្យាង្គ ។

អធ្យគ្និ ក្រិ. វិ. លើភ្លើង ។

អធ្យធីន គុ. ដែលចុះចូល ដែលភក្តិ ។

អធ្យធ្វមិ ក្រិ. វិ. តាមផ្លូវ ។

អធ្យយន ន បុំ. កិរិយាសិក្សា (ខាងគម្ពីរវេទ) ។

អធធិ៍ គុ. ដែលប្រៃលែងដោយពាក់កណ្ដាល ដែលលើសពាក់កណ្ដាល ។

– គុណ គុ ដែលមានគុណប្រៃលែងដោយពាក់កណ្ដាល ។ – នត គុ. ដែលមាននយប្រៃលែងដោយពាក់កណ្ដាល (១៥០)

អធ្យហិណីយ គុ. ដែលគួរដល់កិរិយាទូទៅដោយប្រៃលែង ។

អធ្យវសា ក្រិ. គិតកើត កាន់កាប់ ត្រិះរិះ ។ អធ្យវសិត គុ. ដែលសម្រេចហើយ ដែលកាន់កាប់ហើយ ដែលល្បីហើយ ។

អធ្យវសាយ បុំ. កិរិយាប្ដេជ្ញាដ៏ប្រៃលែង សេចក្ដីព្យាយាម អធ្យវសា-យិនិ គុ. ដែលប្ដេជ្ញាជា ដែលសម្រេចជា ។

អធ្យាកាគម ក្រិ. វិ. ឮដអាកាស ។

អធ្យាក្រមិ ក្រិ. ដើរទៅប្រៃលែង លោត ប្រាយ ជាក់ ជ្រើសរើស។

អធ្យាគមិ ទៅប្រៃលែង ភ្ជាក់ ទួល ជួប ។

អធ្យាចរិ ក្រិ. ប្រព្រឹត្តទៅប្រៃលែង ប្រើប្រាស ។

# រឿង អាប៊ូលហ្វាអ៊ិរិស៍ (ត)

លោក វ៉ាយ ល្អុត តំណាងក្រសួង ប្រែរៀបរៀង

បន្ទាប់ពីសេវិកានាងកាតាំងនេះ នាងកនហ្វាឌុក៏ចាប់ច្រៀងដោយខ្លួនឯង សំឡេងស្រួយដូចតាវើ ស្ទើរសព្ទពិរោះអណ្ដែតអណ្ដូងលើសមហោស្រពយ៉ាងល្បី នៅទេវលោក ដូចចាស់ព្រឹទ្ធាចារ្យតែងដំណាលនោះទៅទៀត ។ បាយរួចហើយ មានគេយកកាដន៍មាសតូចមួយ មកដាក់នៅក្បែរក្នុងទីនោះ មានសំបកសម្បុរល្វែង ដែលមានខ្ទឹងក្រអូបល្អពិសេសជាងគេ កុងកោះ សេរេនឌីប ។ យើងទាំងពីរនាក់លាងដៃនឹងទឹកអប់ក្រអូបអស្ចារ្យនោះ ស្រេចហើយក៏អង្គុយ ដោយមានចិត្តចាប់អារម្មណ៍ខ្លាំង ទៅលើចំរៀង នឹងរបាំទាំងឡាយ រហូតដល់យប់យន់សម័យ ។ នាកាលខ្ញុំក្រោកឈរឡើងចង់គោរពលា នាងកនហ្វាឌុក៏ស្រែកថា ៖ ចុះអ្នកប្រុសសំឡាញ់ មានសេចក្តីថាំងថាក់អ្វីបានជាគិតអញ្ជើញចោលខ្ញុំឲ្យនៅតែម្នាក់ឯង ?

( អា. ) – ខ្ញុំឥតមានសេចក្តីថាំងថាក់អ្វីបន្តិចបន្តួចសោះឡើយ សូមលោកស្រីអភ័យទោស ចំពោះការឆ្កាំឆ្គងនេះឲ្យខាន ។ ហេតុបានជាខ្ញុំចង់សុំលា ព្រោះខ្ញុំយល់ថា លោកមហាសេដ្ឋី ហាប៊ីប ប្រាកដជាលោកមានព្រួយបារម្ភ ដោយមិនឃើញខ្ញុំទៅជួបនឹងលោក ហើយលោកនឹង

មានទុក្ខព្រួយកាន់តែខ្លាំងទៅទៀត ប្រសិនបើលោកពុំឃើញខ្ញុំ ទៅទទួលទានដំណេក នៅផ្ទះលោកទេ ។ សេចក្តីខ្វល់រសាប់រសល់របស់ខ្ញុំ នាំឲ្យនាងកនហ្សាឌ យល់អធ្យាស្រ័យបានភ្លាម តែនាងពុំព្រមឲ្យខ្ញុំទៅជំរាបលោកមហាសេដ្ឋី ដោយខ្លួនឯងទេ នាងទទួលសុំឲ្យខ្ញុំសរសេរសំបុត្រ ហើយនាងខ្វល់ខ្វាយជួយរៀបរៀងសេចក្តីផង សេចក្តីថា៖ «ខ្ញុំមានការមមាញឹកយ៉ាងសំខាន់ជាចាំបាច់ តម្រូវបង្ខំឲ្យខ្ញុំពន្យារដំណើរខ្ញុំ ទៅពីរបីថ្ងៃខាងមុខទៀត ហើយសូមលោកមហាសេដ្ឋី កុំមានព្រួយថប់បារម្ភអ្វីនឹងខ្ញុំឲ្យសោះ» ។ ដល់បានសេចក្តីអះអាងជាទីកក់ក្តៅដូច្នេះស្រេចហើយ នាងកនហ្សាឌ ដឹកដៃខ្ញុំ ចូលទៅក្នុងបន្ទប់មួយយ៉ាងធំទូលាយ ដែលនាងបានរៀបចំជាស្រេចទុកឲ្យខ្ញុំ ។ បន្ទប់នេះ ជាបន្ទប់មានលំអបាញ់បន្ទប់ដទៃ ក្នុងប្រាសាទលោកស្រី នោះឥតអង្គីមានឡើយ ។ នាងស្រ្តីទុកខ្ញុំឲ្យនៅក្នុងបន្ទប់នេះ បន្ទាប់ពីនាងចេញផុតភ្លាមពីបន្ទប់ទៅ មានខ្ញុំបំរើជាច្រើនរូប នាំយកទៅជូនខ្ញុំ ដោយគោរព នូវប្រដាប់ប្រដាគ្រប់បែបគ្រប់យ៉ាង សម្រាប់ផ្លាស់សំលៀកបំពាក់ ហើយខ្ញុំក៏ដេរទាំងនេះអញ្ជើញខ្ញុំ ដោយលំអុតលំទុនកាយ សូមឲ្យខ្ញុំសម្រាកសម្រាន្តជាសុខសាន្តតទៅ ។

ក្នុងពេលស្ងាត់តែម្នាក់ឯង ចិត្ត (អា.) មមៃគិតថា៖ រឿងនេះតើនឹងទៅជាយ៉ាងណាហ្ន៎? អញមានសំណាងល្អឬអ្វី? ប្រាសាទនេះសម្បូណ៌

សប្បាយអ្វីម្ល៉េះ ? អញត្រូវសង្ឃឹមបានបុះទេថា បន្តិចទៀត អញនឹងបាន
ជាប្តីលោកស្រី កញ្ញាកបកល្យាណី ឥតបីមានគូប្រៀបនេះ..ទេ! ទេ!
ឯងកុំនៅលង់ខ្លួនក្នុងផ្លូវខុសដូច្នេះ នេះគឺជាអន្ទាក់ដាក់ឯងទេតើ!...ឯង
មិនត្រូវស្រវឹងវង្វេងចង់បានទ្រព្យសម្បត្តិទាំងនេះ កោតទ្រព្យប៉ុណ្ណោះ មិន
យូរប៉ុន្មាន ដូចផ្កាកុលាប ត្រូវស្វិតស្រពោនជ្រុះរលាយអស់ទៅ ដូច
យល់សប្តិ ក៏មានឧបម័យដូច្នោះដែរ..ទេ! ទេ! ចុះនាងកនហាឌ
នាងមានប្រយោជន៍អ្វី នឹងមកបោកបញ្ឆោតអញ ? អញត្រូវទុកចិត្ត
ដោយស្មោះចំពោះលើសីលធម៌របស់នាង ..ឬការសណ្តាប់ធ្នាប់របស់
តាសា តាសីទាំងឡាយ ឃើញមិនផ្គងនឹងជីងមធ្យ័តត្រឹមត្រូវល្អ ហើយ
ជាប្រក្រតីធម្មតារបស់គេ ...ក្នុងវង់ភ្នែកនាងស្រីទៀត ខ្ញុំឃើញខ្សែទឹក
ស្នេហាដោយក្តីពិត ៗ ចេញជាប់មកលើរូបអញ ៗ ដូច្នេះ ទ្ហើយចុះ!
អញត្រូវមានសេចក្តីកែកយសប្បាយ ទំនុកទុកចិត្ត ទៅលើនាង. .ទេ!
ត្រូវអញគិតឲ្យស្រួល ...ម៉្លោះហើយ ជួនកាលខ្ញុំសប្បាយ ជួនកាល
ខ្ញុំមានសេចក្តីព្រួយសោបសេល់ បីដូចសំពៅមួយសោត់អណ្តែតកណ្តាល
មហាសាគរ មានខ្យល់វិលវល់បក់បោកមកពីគ្រប់ទិសទី ...ខ្ញុំដេកមិន
លក់សោះ ទៅទល់នឹងភ្លឺថ្ងៃតែម្តង ៗ

នៅពេលព្រះអាទិត្យរះ កាំរស្មីពន្លឺចូលក្នុងបន្ទប់ខ្ញុំ នាំឲ្យតុទូគ្រឿង
សម្ភារៈ ចាំងព្រោងព្រាត ខ្ញុំក្រោកពីដំណេក ៗ នាកាលព្រួស្សូរខ្ញុំដើរ

ខ្ញុំបរើទាំងប៉ុន្មានដែលថ្នាក់ថ្នមខ្ញុំពីល្ងាច នាំគ្នាចូលមកក្នុងបន្ទប់ខ្ញុំ នៅវែងរៀងរាល់ខ្លួន មានកាន់អាវវែងល្អ ៗ អស្ចារ្យ ខ្ញុំក៏ជ្រើសរើសយកមួយគឺអាវសូត្រពណ៌ខៀវប៉ាក់មាស រំលេចក្បាច់ដែលខ្ញុំពេញចិត្តរកទីបំផុតគ្មាន ... ស្ទើរតែពាក់អាវពុំទាន់រួចផង ស្រាប់តែនាងគនហក្រុង អញ្ជើញមកដល់ ហើយសួរខ្ញុំថា៖

(ក.) – ចាស ! សួស្តីអ្នកប្រុស ! តើអ្នកសម្រាន្តបានសុខសាន្តឬទេ?

(ខ.) – បាទ ចាន ! សូមអភ័យទោស លោកស្រី ! ខ្ញុំទទួលទានដំណេកមិនលក់សោះ ទល់និងភ្លឺ ។ ចំពោះចម្ងល់នេះ នាងស្រីស្មានថា ខ្ញុំសប្បាយចិត្តយ៉ាងក្រៃលែង នាងក៏ងាកវិលខ្លួនត្រឡប់ទៅវិញ ញញឹមៗ ដោយពុំបានគិតអ្វីឲ្យបានពេញលេញទេ អំពីសំដីសុបិនតែស្មោះត្រង់របស់ខ្ញុំ ខ្ញុំត្រូវបិតនៅ ក្នុងស្ថានភាពដដែលនេះ អស់រយៈពេល ៨ ថ្ងៃ ក្នុងប្រាសាទនាងកញ្ញា គនហក្រុង ។ បុគ្គលិកទាំងអស់យកចិត្តទុកដាក់គោរពថ្នាក់ថ្នមថ្នាក់ថ្នមខ្ញុំ ដូចជាស្តេចមួយព្រះអង្គ លោកស្រីទៀតក៏លោកបញ្ចេញចំពោះខ្ញុំ នូវឫកពាប្រិមប្រិយស្រស់ប៉ប្រៃ ព្រមទាំងសេចក្តីថ្នាក់ថ្នមបបោសអង្អែលផ្គាប់ចិត្តខ្ញុំ ដោយពពាផ្អែមល្ហែម ដើមក្អេកក្អួយក្អេកច្រើនបែបច្រើនយ៉ាង ជាសក្ខីភាពនៃសេចក្តីស្នេហាដ៏ស្មោះស្ម័គ្រពិត ៗ ។

មានមួយថ្ងៃ យើងទាំងពីរនាំគ្នាដើរកំសាន្ត ក្នុងសួនផ្កា ។

(ក.) – បើអ្នកប្រុសសន្មតទុក មេត្តាដល់រូបខ្ញុំដោយសុទ្ធចិត្ត ខ្ញុំនឹងសុំស្នើយោបល់មួយ យោបល់នេះ ប្រហែលជានឹងនាំឲ្យអ្នកប្រុសជួនចិត្តខ្ញុំ សប្បាយរីករាយជាពុំខាន ចាស! ។

(អា.) – ម្ចាស់ចិត្តខ្ញុំអើយ! ប្រសាសន៍ស្រីអូន «ប្រហែល» ពាក្យមួយមាត់នេះ ដូចជាវល្លិ៍តែងមកសើកសៀតក្នុងទ្រូងខ្ញុំដូច្នោះ ។

(ក.) – ចាស: បើដូច្នោះ អ្នកប្រុសជាទីគោរពខ្ញុំអើយ សូមអ្នកសន្យា សូមអ្នកស្បថនឹងខ្ញុំថា អ្នកជាមហាបុរសមានចិត្តទៀងទាត់ស្មោះត្រង់ចំពោះរូបខ្ញុំ ។ ខ្ញុំសូមប្រកាសស្វាមីភក្តិ ចំពោះអ្នកតែមួយ សូមអ្នកទុកខ្លួនខ្ញុំជាដៃម្ខាងរបស់អ្នក សូមអ្នកប្រុសយកដៃនេះ ទៅថ្នមថ្នាក់ដាក់ក្នុងដួងចិត្តអ្នកចុះ ។ យើងទាំងពីរ យើងត្រូវវេញបញ្ចូលគ្នាជាធ្លុងមួយ ដោយកិច្ចពិសិដ្ឋ ពោលគឺអាពាហពិពាហ៍ជាពុំខាន ចាស! ។

(អា.) – សមនឹងលោកស្រី ជាអ្នកមានជាតិកំណើត ហើយរស់នៅក្នុងបណ្ដាអ្នកកាន់លទ្ធិសាសនាហៅថា គុអែប្រ៊ី គោរពបូជាព្រះអគ្គិនិងព្រះអាទិត្យ រីឯខ្លួនខ្ញុំជាអ្នកម៉ាហូម៉ិត សំដីនាងស្រី នាំឲ្យខ្ញុំឡប់ស្មារតីមមិងមមាំង មុខស្លេកស្លាំង ខ្ញុំខ្មាស់អៀន ក្នុកខ្ញុំស៊ាំយ៉ុងចុះ ៖ តុស្ទ សេចក្ដីត្រេកអរសប្បាយពាយលើមុខខ្ញុំ ប្រែក្លាយស្រទំក្លាម ទៅជារសេះរសោះគិតអ្វីមិនឃើញ ... ។

លោកស្រីកនហ្សាឌ ទាំងមុខស្រឡប់ ទាំងក្នុកបញ្ឈរ ស្រែក

ឡើងថា៖ ខ្ញុំឥតស្មានឃើញសោះថា សេចក្ដីស្នេហ៍នេះ ជាគ្រឿងចំណាស់ចិត្ត អ្នកដ៏ធំដល់ម្ល៉េះ ! អំពីសេចក្ដីស្នេហ៍អំបាញ់មិញ ខ្ញុំស្មានថា យើងទាំងពីរប្រាកដជារីករាយសប្បាយរកអ្វីប្រៀបគ្មាន នេះមិនដូច្នោះ សេចក្ដីស្រឡាញ់ស្រឡាត់របស់អ្នក ត្រូវបានឈ្មោះថា អ្នកជេរប្រទេចដាក់បណ្ដាសាខ្ញុំយ៉ាងធ្ងន់ ៗ ចុះយ៉ាងមេច ម៉េ ! តើអ្នកគិតថាយកខ្ញុំធ្វើប្រពន្ធ វាអាប់កិត្តិយសអ្នកណាស់ យ៉ាងនេះ ឬអី ?

(អា.)– ឱព្រះដ៏មានបុណ្យអើយ ! មេចក៏លោកស្រីដាក់ឧបសគ្គធំ ផុតវិស័យខ្ញុំនឹងពុះពារបានដូច្នេះ ? ទាំងដៃប្រណម្យទៅលើមេឃ ទាំងលុតជង្គង់ ... ។

(ក.)– ឧបសគ្គ ពុំអាចពានពារបាន ?.,. ម៉េ ! ចុះឧបសគ្គអី ?

(អា.)– សាសនារបស់ខ្ញុំ ! ខ្ញុំកន្លងរំលងមិនបានសោះឡើយ នូវមូលធម៌ ដែលលោកបានហាមហើយជាស្រេច ក្នុងរឿងអាពាហ៍ពិពាហ៍ ... ។

(ក.)– អ្នកប្រុសអើយ ! សូមអ្នកកុំមានសេចក្ដីសង្ស័យអ្វី ខ្ញុំជាមនុស្សអ្នកបេះគិតល្អិតល្អន់ ដូចអ្នកដែរ ៗ ក្នុងរឿងសាសនានេះ បើទុកជាគេយកអធិរាជមួយព្រះអង្គមកឲ្យខ្ញុំផង ក៏ខ្ញុំពុំព្រមយកអ្នក ម៉ាហូម៉ិត ធ្វើជាប្ដីដែរ ៗ តែក្នុងរឿងនេះ មុននឹងយើងរួមរស់សមាគ្នា អ្នកប្រុសត្រូវស្បថអះអាងថា អ្នកមានចិត្តស្មោះត្រង់ មកឱបក្រសោបបីត្រកង ចិត្ត

ស្មោះត្រង់របស់ខ្ញុំសិន . . . ត្រង់ខនេះ អ្នកត្រូវក្បាល មិនព្រមបន្ទន់ខ្លួន ពាក្យស័ត្យនេះ ដូច្នេះអ្នកជាមនុស្សអកតញ្ញូពាលសាមាន្យយង់ឃ្នងធំបំផុត កន្លងពិភពលោក . . . ។

(គ ) - សំដីទាំងប៉ុន្មាននេះ ដោយនាងកនហ្វ្រាឌ បញ្ចេញសំឡេង ខ្ទឹ ៗ ខ្លាំង ៗ ញាប់ ៗ នាំឲ្យខ្ញុំស្ទុតទន់ដៃទន់ជើងភ័យខ្លាំងញ័រចំប្រប់ទាំង ខ្លួន ហាមាត់ឆ្លើយទៅវិញមិនរួច . . . ម្ល៉ោះហើយលោកស្រីកាន់តែមុាំង រមៅកប្រមោកដោយឥតមេត្តាមកលើខ្ញុំ ស្តីបន្ទោសហើយបន្ទោសទៀត ទាំងទឹកភ្នែកហូរស្រក់សស្រាក់ . . . . . . នាងទៅជាស្រីមួយកាចសំបើម អស្ចារ្យ . . . ទុក្ខខ្វោចផ្សារបស់នាងយ៉ាងណា ខ្ញុំក៏ដូច្នោះដែរ ៗ យ៉ាងម្តេចក៏ដោយ ! . . . ខ្ញុំនៅតែតាំងស្មារតីរឹងប៉ឹង . . . ដល់នៅតែឃើញ ខ្ញុំទឹងស្មារតីដូច្នេះ នាងកាន់តែឆ្ងល់ខ្លាំង ហើយមានទុក្ខខ្វោចផ្សា កាន់តែ ពិយោគាតទៅទៀត ក្រោកឈរទន្ទ្រំដីទាំមាត់ ព្រោះនាងពុំព្រម ជឿបានថា ការប្រកែករបស់ខ្ញុំ ជាសេចក្តីវិនិច្ឆ័យដាច់អហង្ការស្ថាពរ... ចុងក្រោយបំផុត នាងក៏និយាយថា៖ ណ្ហើយចុះ ! ខ្ញុំជូនពេល ៨ ថ្ងៃ ឲ្យ អ្នកប្រុសពិចារណាគិត . . . ។

(គ.) - ដល់ ៨ ថ្ងៃទី ១ សេចក្តីសម្រេចរបស់ខ្ញុំ នៅទឹងថ្កល់ ដដែលឥតប្រែប្រួល . . . នាងពន្យារពេល ៨ ថ្ងៃថ្មីទៀត ដោយកំញើញគំ រាមខ្ញុំថាទឹងត្រូវទុក្ខទោសយ៉ាងការុណធ្ងន់បំផុត ប៉ុន្តែខ្ញុំនៅតែប្រកែកតទៅ

ទៀត ៗ ទុំះដល់ចាញ់ចេះ ពុំដឹងធ្វើម្ដេចឲ្យខ្ញុំយល់ព្រមកើត រឺឯថ្ងៃ ចេះតែកន្ទួងទៅ ៗ នាងស្រីក៏មានបង្គាប់ ឲ្យគេនាំខ្ញុំ ទៅក្នុងមហាគេហដ្ឋានមួយយ៉ាងល្អ ដែលឋិតនៅក្នុងបរិវេណប្រាសាទនាង ៗ នៅទីនោះ កណ្ដាលចំណោមស្រីជាច្រើន នាងអង្គុយផ្ទាំងខ្ញុំ លើអាសនៈមួយ មានសណ្ឋានដូចកដបល្ល័ង្គខ្សែពីរថ្មបីកាំជណ្ដើរ ៗ នាងមានទឹកមុខ មិនមែនដូចជាចៅក្រមគឹងរឹងដូចមុនទេ ៗ នាងមានចុកពាសូភាពរាបទាបស្លូត ជាគូសង្សារយ៉ាងល្អកល្អិនទីងខ្ញុំ ៗ តាំងមុខមាំប្រាកដប្រជា តាំងខ្លួនញ័រ ៗ ចប្រប់ ខ្ញុំដើរទៅជិតនាង ៗ

(នៅមានត)

## បំណោទ ទី ២

ខ្ញុំជារបស់មួយ បើនៅតាំងខ្លួន តាំងជើង
មនុស្សក្នុងលោកនិយម ស្រឡាញ់ចូលចិត្ត
គ្រប់គ្នា តែបើគេកាត់ជើងខ្ញុំចោល ខ្ញុំក្លាយ
ជាកម្ទេចសម្រាប់តែគេចំអកសើចលេង
តើខ្ញុំជាអ្វី ?

# រឿងល្បើកឡាហ្វុងតែន

ប្រែពីភាសាបារាំងដោយ លោក ជេង - ជ្រីវ

(ត)

## ៩០) មាន់ស្ទាវ ឆ្មា និងកូនកណ្ដុរ

កូនកណ្ដុរមួយនៅក្មេង មិនធ្លាប់ដែលបានឃើញអ្វី ហិះតែនឹងទទួលគ្រោះថ្នាក់ដោយមិនដឹងខ្លួន ។

រឿងដូចតទៅ ជាសេចក្ដីដែលវាពោលរៀបរាប់ប្រាប់មេវា ៖

ខ្ញុំគ្រាន់តែចូលកាត់ភ្នំទាំងឡាយដែលឃាំងទីនេះ ហើយកំពុងតែរត់ទៅមកលេងកំសាន្តសប្បាយតាមអំពើចិត្ត ស្រាប់តែខ្ញុំឃើញសត្វពីរ ៖ អាមួយស្លូតស្អាតគួរឲ្យស្រឡាញ់ អាមួយសំដីច្រើន ហើយឥតដែលនៅស្ងៀមម្ដង សំឡេងវារឹងរូស នៅលើក្បាល មានសាច់មួយដុំក្រហមរងាល មានដូចជាដៃដែលទទះខ្យល់ ដើម្បីចង់ហើរ កន្ទុយលាក្រញាំងដូចជាផ្លិត ។

គឺជាមាន់ស្ទាវហើយ ដែលកូនកណ្ដុរបានពោលរៀបរាប់ប្រាប់ម្ដាយវានេះ ហាក់ដូចជាសត្វមកពីប្រទេសអាមេរិក ។

កូនកណ្ដុរនិយាយទៀតថា ៖ សត្វនេះយកដៃទាំងពីរទះធ្មឹងចំទីរសងខាង បញ្ចេញសូរសព្ទយ៉ាងអាក្រក់ ទាល់តែខ្ញុំដែលជាអ្នកមានសេចក្ដីក្លាហានផងទ្រាំមិនបាន ត្រូវតែភ័យរត់រួចជេរប្រទេចវាយ៉ាងខ្លាំងឥតសំចៃ ។

ប្រសិនបើគ្មានវា ខ្ញុំប្រហែលនឹងមានការទាក់ទងជាមួយអាមួយនោះ ដែលមានទំនងដូចជាស្លូតពន់ពេក គឺថាវាមានកោមទន់ល្មើយដូចយើង ពណ៌ផុដ ៗ កន្ទុយវែង អាការគួរសម ទឹកមុខសុភាព តែប៉ុន្តែភ្លេតភ្លាំង ខ្ញុំជឿជាក់ថាវាហ្នឹងជាសត្វគួរតែកប់រកយកជាគ្នា ជាមួយអស់លោកណាទាំងឡាយ ព្រោះវាមានត្រចៀកប្រហែលនឹងត្រចៀកយើង ៗ ខ្ញុំរៀបនឹងចូលទៅទាក់ទងជាមួយវា ស្រាប់តែអាមួយនោះស្រែកខ្លាំងពេក ខ្ញុំកក៏ភ័យរត់មក ។

មេកណ្ដុរនិយាយថា ៖ ម្នាលកូនសម្លាញ់ ! អាមួយដែលថាមានទំនងស្លូតបូតនោះគឺជាឆ្មា ៗ នេះមានទឹកមុខលាក់ពុត ប្រកបដោយកលល្បិចដែលនាំឲ្យឯងមានការគាន់ប្រឡំដោយអាការខាងក្រៅរបស់វា អាមួយនោះផ្ទុយទៅវិញ ជាសត្វមានសភាពឥតស្រដៀងនឹងយើងសោះ ប្រហែលមានថ្ងៃណាមួយនឹងបានជាចំណីអាហាររបស់យើងទៅវិញទេ ៗ ចំណែកឆ្មាមិនដូច្នោះទេ វារមែងតែចាប់យើងធ្វើជាអាហាររបស់វា ៗ ដរាបណាកូនឯង មានជីវិតរស់នៅ ដរាបនោះចូរប្រយ័ត្នកុំវិនិច្ឆ័យមនុស្សតាមទឹកមុខឡើយសោះ ៗ

## ៩១) សត្វកើតជម្ងឺពិស

មានវិបត្តិភាព បានសាបព្រោះខ្ញីគេរកម្ពាសពេញ ជាវិបត្តិភាពដែលទេព្ដាបានបង្កើតឡើង ដើម្បីធ្វើទោសដល់អ្នកប្រព្រឹត្តបទ-

ទក្រិដ្ឋនៅលើផែនដី បានជាទេវតាឲ្យជម្ងឺពិសមកសម្លាប់សត្វនានា ព្រោះពិសអាចសម្លាប់ក្នុងមួយថ្ងៃបានច្រើន ។

សត្វមិនមែនស្លាប់ទាំងអស់ទេ តែសត្វឈឺទាំងអស់ គេមិនឃើញសត្វត្រាច់ស្វះស្វែងរកអាហារចិញ្ចឹមជីវិតសោះ ព្រោះមិនមានអាហារចំណីណាធ្វើឲ្យសត្វមានចិត្តចង់សោះ ចចកក្តី កញ្ជ្រោងក្តី ឈប់ត្រូវការទឹងរំពាដ៏ឆ្ងាញ់ពិសារ ។ សត្វលលកស្ទុះហើរតែកៀសខ្លួន ឈប់មានសេចក្តីស្នេហា ឈប់មានការសប្បាយរីករាយ ។

ឃើញហេតុដូច្នោះ សិង្ហប្រជុំអស់ពួកសត្វ ហើយពោលថា៖ «ម្នាលមិត្រភក្តិជាទីស្នេហាទាំងឡាយ ខ្ញុំជឿថាទេវតាបានធ្វើឲ្យមានសេចក្តីទុក្ខវេទនានេះដល់ពួកយើងណាដែលមានកំហុសហើយ បណ្តាយើងទាំងអស់ អ្នកដែលមានទោសធ្ងន់ គួរគប្បីធ្វើពលីកម្ម ដើម្បីរំងាប់កំហឹងទេវតា ធ្វើដូច្នេះប្រហែលជានឹងមានការសះស្បើយខ្លះទៅ ។ ប្រវត្តិសាស្ត្រប្រាប់យើងថា បើមានឧប្បត្តិហេតុយ៉ាងនេះ គេនិយមធ្វើពលិ-កម្មដូច្នេះឯង ។ យើងមិនត្រូវបណ្តែតបណ្តោយឲ្យសោះ ត្រូវពិនិត្យដោយឥតយោគយល់ ឬបន្ធូរបន្ថយ នូវសតិសម្បជញ្ញៈរបស់យើង ។ ចំណែកខ្ញុំ ដើម្បីបំពេញចម្ងាញ់ ខ្ញុំបានចាប់ហែកស៊ីនូវចៀមជាច្រើន តើចៀមទាំងនោះបានធ្វើអ្វីដល់ខ្ញុំ ? គឺមិនមានការប្រមាថមើលងាយអ្វីសោះ ជួនកាលខ្ញុំស៊ីទាំងអ្នកង្វាលផងថែមទៀត ។ ដូច្នេះខ្ញុំនឹងធ្វើពលិ-

កម្មផល ប្រសិនបើជាត្រូវធ្វើ ក៏ប៉ុន្តែខ្ញុំយល់ថាម្នាក់ ៗ គប្បីទទួលស្គាល់ទោសរបស់ខ្លួនដូចខ្ញុំ ព្រោះតាមច្បាប់យុត្តិធម៌ គេត្រូវតែពេញចិត្តឲ្យអ្នកដែលមានទោសធ្ងន់ជាងគេស្លាប់ ។

កញ្ជ្រោងពោលឡើងថា : «ព្រះករុណាថ្លៃវិសេស ! ព្រះអង្គជាព្រះមហាក្សត្រ ប្រកបដោយសេចក្តីមេត្តាករុណាពន់ពេក សេចក្តីព្រួយបារម្ភនៃព្រះអង្គនេះ ពេញហៅមានសារៈសំខាន់ក្រៃលែង ។ ចំណែកដែលព្រះអង្គទ្រង់សោយចៀមជាសត្វថោកទាបនោះ នឹងទុកថាព្រះអង្គជាអ្នកមានកំហុសឬ ? សូមទ្រង់ព្រះមេត្តាប្រោស ! គឺឥតមានកំហុសពាល់តែសោះ ឯការដែលព្រះអង្គសោយវានេះ មានតែទ្រង់ប្រទានកិត្តិយសដ៏ច្រើនដល់វាវិញទេតើ សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។ ចំណែកអ្នកគង្វាលវិញ គេអាចចាត់ទុកថាជាមនុស្សដែលគួរតែទទួលសេចក្តីទុក្ខគ្រប់យ៉ាង ព្រោះមនុស្សទាំងនេះហើយបានប្រព្រឹត្តអំពើឃោរឃៅមកលើសត្វទាំងឡាយ » ។ កញ្ជ្រោងនិយាយប្រាប់សិង្ហដូច្នេះ ឯពួកអ្នកបញ្ចោរក៏នាំគ្នាទះដៃប្រាវឡើង ។

ចំពោះរឿងនេះ គេមិនហ៊ានលូកឲ្យជ្រុលហួសដល់ការប្រមាថបន្តិចបន្តួចដែលអាចអត់ទោសឲ្យបាន នៃសត្វខ្លា សត្វខ្លាឃ្មុំ និងសត្វមានពិសដទៃឡើយ ។ បើតាមសំដីដែលគេនិយាយ គឺត្រូវទុកសត្វកំណាចទាំងនោះរហូតដល់ថ្កើសាមញ្ញ ជាតួព្រះគួច ១ ។

សត្វលាដើរទន ៗ ចូលមក ហើយពោលថា: ទូលព្រះបង្គំចាំបានថាមានពេល ១ ទូលព្រះបង្គំជាខ្ញុំដើរចូលទៅក្នុងកលស្មៅរបស់លោកសង្ឃ (moines) ទទួលឃ្លាន ហើយមានស្មៅខ្ចីនៅទីនោះស្រាប់ មិនដឹងជាមានខ្មោចអ្វីមកជម្រុលឲ្យទូលព្រះបង្គំបោចស្មៅនោះ ស៊ីអស់បន្តិច ទូលព្រះបង្គំសូមក្រាបបង្គំទូលថ្វាយត្រង់ស្មោះ ថាទូលព្រះបង្គំមិនមានសិទ្ធិអ្វីទាល់តែសោះ ទៅលើស្មៅនោះ ។ សេចក្តីប៉ុណ្ណេះ សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

គ្រាន់តែបានឮលាពោលដូច្នោះ គេស្រែកសុំឲ្យវិនិច្ឆ័យសត្វលា ។ ចចកមួយផ្ទាត់និយាយថា ត្រូវតែឲ្យសត្វចង្រៃនេះធ្វើពលិកម្ម ព្រោះវិបត្តិភាពទាំងអស់ បណ្តាលមកពីវា ។ ម៉្លោះហើយគេវិនិច្ឆ័យកាត់ទោសដ៏ស្រាលនេះ ថាត្រូវយកលាទៅចងកព្យួរ ។

គ្រាន់តែស៊ីស្មៅគេ! ទោសអ្វីក៏ធ្ងន់សម្បើមម៉្លេះ! មានតែសេចក្តីស្លាប់ទើបអាចលប់លាងបទឧក្រិដ្ឋរបស់លាបាន គេក៏នាំគ្នាសម្រេចកិច្ចទៅ ។

សេចក្តីវិនិច្ឆ័យនៃតុលាការ នឹងសម្រេចឲ្យអ្នកទៅជាស ឬខ្មៅ អនុលោមទៅតាមអ្នកជាមនុស្សមានអានុភាព ឬជាមនុស្សទន់ខ្សោយ ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ង្វ-គាង ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកភិងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឃួរ-អ៊ុន

ស៊ុនគួនស្តាប់យល់ឃើញត្រូវ ក៏ចាត់ចែងទាហានតាមពាក្យឡោ-សុកនិយាយ ។ នាំគេកថា លោកកុំអាលមាក់ងាយប្រមាទ ព្រោះគួនអ៊ូនោះមានថ្វីដៃពូកែជាទាហានខ្លា បើមិនសមនឹងសេចក្តីគិតឧបាយនោះដោយប្រការឯណា ក៏នឹងត្រឡប់អន្តរាយដល់យើងវិញ ស៊ុនគួនឮដូច្នោះក៏ខឹងណាស់ថា ចាំកាលណាទើបយកស្រុកកេងជីវឲ្យបាន ហើយបង្គាប់ឲ្យឡោសុកធ្វើតាមគំនិតដែលគិតទុកនោះឲ្យសម្រេច ។ ឡោសុកទទួលបង្គាប់ហើយក៏លាចេញទៅចាត់រៀបចំទូកចម្បាំង លុះបានព្រមចាំងទាហានយោធាហើយ ក៏ចេញទៅបោះយុថ្កានៅមាត់ពាមឡុកខៅហើយឡើងទៅតាំងបន្ទាយលើគោក រួចចាត់ឲ្យកាំឡេង ១ លីបង ១ លើកទាហានទៅពួនបង្កប់គ្រប់រយៈដែលគិតទុកនោះ ហើយឲ្យរៀបតុលៀងអាហារស្រេចកាលណា ក៏ធ្វើសំបុត្រចាត់បំរើឲ្យទៅអញ្ជើញគួនអ៊ូមក

បរិភោគ ឯបំរើដែលកាន់សំបុត្រនោះ រើសមនុស្សដែលចេះសំដី លុះទៅដល់ស្រុកកេនជីវ៉ហើយ ក៏និយាយឲ្យគួនប៉េនយល់តាមសំបុត្រឡោសុក ។

គួនប៉េនក៏នាំអ្នកកាន់សំបុត្រនោះ ចូលទៅគំនាប់គួនអ៊ូ ហើយជូនសំបុត្រនោះទៅគួនអ៊ូ ។ មើលឃើញសេចក្ដីថា ឡោសុកសុំអញ្ជើញទៅពិសាលៀនឯបន្ទាយមាត់ពាមឡុកទៅ គួអ៊ូក៏ប្រាប់អ្នកកាន់សំបុត្រនោះថា ឲ្យស្រូតទៅប្រាប់ឡោសុកចុះ ចាំព្រឹកស្អែកយើងនឹងទៅ។ បំរើនោះក៏លាគួនអ៊ូត្រឡប់ទៅវិញ ។ គួនប៉េនជំពបគួនអ៊ូថា ដែលឡោសុកឲ្យមកអញ្ជើញបិតាទៅពីសាលៀននោះ ខ្ញុំបាទឃើញថា នឹងជាកលឧបាយទេ ហេតុម្ដេចក៏បិតាទទួលថាទៅ ។

គួនអ៊ូឮហើយក៏អស់សំណើចហើយតបថា ហេតុទាំងនេះ ព្រោះជូកាត់គិតទៅប្រាប់ស៊ុនគួន បានជាឡោសុកគិតកលឧបាយឲ្យអញ្ជើញយើងទៅស៊ីលៀន ហើយនឹងបានទារយកស្រុកកេនជីវិញ ដើម្បីឲ្យបានជាកម្មសិទ្ធិរបស់ស៊ុនគួន បើយើងនិងមិនទៅវេលានេះ ពួកស្រុកកាំងតាំងនឹងមើលងាយថាយើងខ្លាច ព្រឹកស្អែកឡើងយើងនឹងនាំទាហានតែ ២០ នាក់ ចុះទូករហ័សទៅស៊ីលៀន ដើម្បីនឹងមើលកលការឡោសុកនឹងខ្លាចញញើតលំពែងដែលយើងកាន់ទៅនេះដែរឬទេ ? ។ គួនប៉េនថា ខ្លួនបិតាជូចជាមាសនពគុណដែលនឹងគន្ធងចូលទៅក្នុងពួកចោរនោះ

មិនគួរ ខ្ញុំបាទក្រែងស្រុកកេងជីវនេះនឹងកើតអន្តរាយ ទៀតពីទីសំគាល់ទោសថា បិតាធ្វេសប្រហែស ។

គួនអ៊ីតបថា ពៅកុំវិតក្កឡើយ ឯបិតានេះក៏មានថ្វីដៃល្បីល្បាញទូទៅ សូម្បីទាហានចួចកប់សែនច្រើនហួសប្រមាណ បិតាមានតែសេះមួយ អាចការពារមិនឲ្យព្រួញអាវុធជិតដល់ខ្លួនបាន អាចបរសេះរុកកន បំពានចូលទៅ-ចេញមកច្រើនគ្រាច្រើនត្រឡប់ ។ បមាបីដូចជាគេចូលក្នុងគុម្ពឫស្សីនឹងចេញមកវិញបានដោយងាយ នឹងខ្លាចអ្វីថ្វីដៃទាហានស្រុកកាំងតាំងប៉ុណ្ណេះ បីដូចជាហ្វូងជ្រូកនឹងរកស្លាហាប់គ្មានសោះ បិតាបានចេញវាចាថាទៅហើយនឹងឲ្យខូចសំដីថ្វី ។ ម៉ាលៀងឆ្លើយថា បើលោកនឹងអញ្ជើញទៅ ក៏ត្រូវប្រុងប្រយ័ត្នគិតរាំងមុខក្រោយកុំឲ្យប៉ះការ ។

គួនអ៊ីថា ដែលអស់អ្នកមករំលឹកគ្រានេះក៏គួរហើយ ខ្លួនយើងនឹងគួនប៉េងនឹងនាំទាហានចេញទៅ ៤-៥រយ ហើយបង្គាប់គួនប៉េងឲ្យត្រួតត្រាទាហានទាំង ៥០០ ចុះទូកចម្បាំង ១០ ប្រចាំត្រួតមើលការ បើឃើញយើងបោកទង់ចុះវេលាណា ត្រូវបរពលចូលទៅជួយឲ្យរួសរាន់ គួនប៉េងទទួលបង្គាប់ហើយ ក៏ចេញទៅចាត់ចែងទូកព្រម តាមគួនអ៊ីបង្គាប់ ។

លុះបំរើនាំសំបុត្រនោះវិលទៅដល់បន្ទាយ ក៏និយាយប្រាប់ឡោសុកថា គួនអ៊ីត្រេកអរទទួលថា នឹងមកព្រឹកស្អែក ឡោសុកត្រេកអរណាស់ ទើបប្រឹក្សានឹងលីបេងថា ឯគួនអ៊ីនោះ មានថ្វីដៃខ្លាំងពូកែណាស់ នឹងមក

ស្អែកនេះហើយ យើងនឹងគិតប្រការដូចម្តេច ៗ លីបង់ថា កាំឡេងនឹង ខ្ញុំបាទ ក៏បានតាត់តែងទាហានបង្កប់នៅខាងក្រៅជាពីរកង បើឃើញគួនអ៊ូគ្មានពួកទាហានមកជាមួយជាច្រើនទេ យើងនឹងបញ្ចេញទាហានដែលបង្កប់នោះ ឲ្យចេញមកតែត្រឹម៤០ នាក់ បើបានការហើយ នឹងព្រួតគ្នាចាប់គួនអ៊ូសំឡាប់ចេញ បើគួនអ៊ូមានទាហានមកផង ខ្ញុំបាទនឹងកាំឡេងចាំស្តាប់សំឡេងផាវ បើឮកាលណានឹងឃុំទាហានវាយប្រសព្វខ្ទប់ចាប់ខ្លួនគួនអ៊ូឲ្យបាន ៗ

ឡោសុកយល់ឃើញត្រូវផង លុះដល់ពេលព្រឹកក៏តាត់តែងតាមគំនិតដែលគិតទុក ហើយឲ្យទាហានទៅចាំមើលគួនអ៊ូជាមានទាហានមកជាមួយឬទេ បំរើនោះ ក៏ត្រឡប់មកប្រាប់ឡោសុកវិញថា ឃើញគួនអ៊ូជិះទូកហេសតូច ១ មក មានពួកដើងថែវប្រហែល ២០ នាក់ នឹងទង់ក្រហមសម្រាប់គួនអ៊ូ ឯគួនអ៊ូនោះតែងខ្លួនហ៊ីហាពាក់អាវព្រែពណ៌ស្វាយ ជួតក្បាលព្រែពណ៌ខៀវ មិនបានពាក់គ្រោះ ឃើញដាវធងលីលំពែងអង្គុយអមគួនអ៊ូ ឯទាហានដែលមកជាមួយនោះ សុទ្ធតែមានថ្វីដៃខ្លាំងពូកែប្រហែល ៧.៨ នាក់ ៗ ឡោសុកឮហើយ ក៏ចេញទៅទទួលឃើញគួនអ៊ូតែងខ្លួនហ៊ីហា មានទាហានមកជាច្រើនគ្នា ឡោសុកនឹកញាញើតក្រែងធ្វើការនោះពុំសម្រេច លុះនាំគួនអ៊ូចូលទៅដល់ក្នុងបន្ទាយក៏តាំងគំនាប់គ្នា ហើយឡោសុកក៏អញ្ជើញគួនអ៊ូបរិភោគអាហារ ៗ

ខណៈកាលកំពុងសេពសុរានោះ ឡោសុកក៏ញាប់ញ័រអស់ទាំងខ្លួន មិនហ៊ានទាំងងើបមុខមើលគួនអ៊ូផង ឲ្យតែមនុស្សបំរើចាក់ស្រាឲ្យគួនអ៊ូផឹក គួនអ៊ូផឹកស្រាក្លាម ក៏មិនបានកោតញញើត តាំងតែនិយាយពីរឿងចម្បាំង ហើយក៏សើចកេះកយសប្បាយ ឡោសុកក៏សម្ងំចុងភ្នែកមើលគួនអ៊ូ ឃើញកាន់តែស្រវឹងខ្លាំងក៏តាំងនិយាយថា យើងមានសេចក្ដីមួយ១ នឹងសុំប្រារព្ធបរតានឹងលោក ៗ គួនអ៊ូសួរថា អ្នកនិយាយការអ៊ី ៗ ឡោសុកឆ្លើយថា ពីដើម ស៊ុនគួនឲ្យយើងមកទារយកស្រុកកេងជីវ ២.៣ ដង ហើយឡៅពីបេះតែបណ្ដោះបណ្ដៃថា សុំស្រុកកេងជីវទុកជាទីអាស្រ័យសិន បើកាលណាកយបានស្រុកសៃឈួនហើយ នឹងបង្វិលស្រុកកេងជីវឲ្យវិញ សេចក្ដីនេះយើងបានកប់ងនឹងស៊ុនគួនម៉ាំមួនណាស់ ឥឡូវឡៅពីកយបានស្រុកសៃឈួនហើយ ដែលនឹងហួងហែងស្រុកកេងជីវទុកនោះក៏មិនគួរសោះឡើយ ៗ គួនអ៊ូតបថា អ្នកមានសំបុត្រឲ្យបំរើនាំទៅឲ្យខ្ញុំ ដើម្បីនឹងឲ្យមកបរិភោគអាហារតែម្យ៉ាងជាការសប្បាយ ឥឡូវត្រូវការអ៊ីបានជាមកប្រារព្ធរឿងស្រុកទេសទៅវិញដូច្នេះ មិនគួរសោះ ត្រូវតែស្ងៀមទៅសិនចុះ ៗ

ឡោសុកថា ចៅហ្វាយនាយយើងជាធំក្នុងស្រុកកាំងតាំង ក៏គិតនឹងផ្សាយផែនដីឲ្យធំទូលាយទៅទៀត តែនៅមានចិត្តអាណិតលោកនឹងឡៅពីដែលរត់ពីចូចូមក បានជាឲ្យស្រុកកេងជីវនៅជាបណ្ដោះអាសន្ន

ឥឡូវត្រូវឲ្យឡោះឡៅពីគិតដល់ផ្លូវមេត្រីរបស់នាយយើង បានជាឲ្យមានសំបុត្រ អញ្ជើញលោកមក ដើម្បីទឹងទារយកស្រុក ៣ ដំបន់ ដែលឡៅពីព្រម ឲ្យនាយយើងជាមុនមកហើយនោះ ដែលលោកមកទាំងខា ទុកនោះមិន គួរសោះ ។

គួនអ៊ីថា កាលគ្រាបច្ចុប្បន្នលើកទ័ពមកពយយកស្រុកទាំងតាំងនោះឡៅ ពីកំបាត់គេណាទាហាន ទៅស្លាក់ច្បាំងទីងទ័ពច្បូជាច្រើនដំបន់ ទាហាន ទាំងពួងក៏បានស៊ូទឹងព្រួញធ្នូទឹងអាវុធផ្សេង ១ បានសេចក្ដីលំបាកវេទនា គ្រប់គ្នា ប្រាជ្ញាដែលធ្វើការបានជ័យជំនះច្បូគ្រានោះ មិនពីព្រោះឡៅពី ប្រើខុងបេងទៅជួយទេ្ហ ហើយឡៅពីក៏បានបង់ខាតស្បៀងអាហារជា ច្រើន តែត្រឹមស្រុកគេងដីវប៉ុណ្ណោះ មិនសមគួរជាបំណាច់ឡៅពី ទីង ទាហានដែលបានធ្វើការនឿយហត់នោះទេ្ហ ហេតុម្ដេចបានជាអ្នកមក បង្ខំតឹងទារស្រុកគេងដីវដដែល ១ ដូច្នេះ ។

ឡោសុកថា កាលឡៅពីទីងលោកបែកទ័ពមកពីពលទៀងប៉ាន់ប៉ោ នាយយើងគិតអាណិតអាសូរ បានជាឲ្យស្រុកគេងដីវទៅជាបណ្ដោះអាសន្ន គ្រាតែតាំងខ្លួនបានដល់ប៉ុណ្ណោះ ហើយឡៅពីនោះក៏ជាមនុស្សមានសេចក្ដី ស័ត្យបានចេញមាត់ថាពីការអ៊ី ១ ក៏មិនដែលឲ្យខូចពាក្យសោះ ដែលខ្លួន លោកមកនិយាយដូច្នេះ មនុស្សទាំងពួងទីងកន្ទងមើលងាយបាន ។ គួនអ៊ី ថា ការទាំងពួងនេះ មិនមែនជាសិទ្ធិដាច់ខាតលើខ្លួនយើងទេ គឺបំពោះ

លើឡៅពីជានាយចៅហ្វាយសម្រេចសេចក្តី តាមតែអ្នកនឹងនិយាយគ្នា ចុះ ៗ ឡោសុកថា យើងដឹងថា ខ្លួនលោកនឹងឡៅពីបានប្តេជ្ញាស្បថស្បាន់គ្នា ទុកជាបងប្អូនរួមទ្រជាមួយគ្នា បើនឹងមានការអ្វីមកជារបស់ឡៅពី ក៏ប៉ដូចជារបស់លោកដែរ ធុរៈអ្វីជារបស់លោកក៏ដូចជាធុរៈរបស់ឡៅពី ហេតុម្តេចលោកមកធ្វើព្រងើយកន្តើយដូច្នេះ គួនអ៊ូក៏មិនឆ្លើយតបថាអ្វី ៗ ជីវឆេងចាហានគួនអ៊ូស្រែកថា អាណាខេត្តទាំងអស់នេះសុទ្ធតែរបស់ព្រះចៅហៀនគេទាំងមូល ហេតុអ្វីឡោសុកមកថាស្រុកគេជីវជារបស់ស៊ុនគួនវិញ ៗ

គួនអ៊ូឮជីវឆេងស្រែកដូច្នេះ ក៏ធ្វើជាខឹង ក្រោកចេញមក ឲ្យន័យជីវឆេងដឹងហេតុហើយ ក៏ដណ្តើមយកលំពែងមកកាន់ហើយស្រែកថា យើងនឹងឡោសុកកំពុងនិយាយគ្នាពីការស្រុកទេស ហេតុម្តេចខ្លួនគ្រាន់តែជាចាហានសម្រាប់លីលំពែងតាមមក អាចហ៊ានចូលមកនិយាយផងដូច្នេះ ជាការមិនសមគួរសោះ ខ្លួនត្រូវចេញពីទីនេះ ទៅក្រៅបន្ទាយទៅ ៗ ជីវឆេងដឹងន័យគួនអ៊ូដូច្នោះ ក៏ដោះខ្លួនចេញទៅនៅខាងក្រៅ ហើយយកទង់ក្រហមបោកឡើងជាសំគាល់ ៗ

គួនប៉េងឃើញទង់សំគាល់ដូច្នោះ ក៏បង្គំចាហានឲ្យចៅទូកចម្បាំងទាំង៩០ ចូលទៅដល់មុខបន្ទាយ ឯគួនអ៊ូក៏ធ្វើជាស្រវឹង ត្រវែងលំពែងដៃម្ខាង ដៃម្ខាងកាន់ដៃឡោសុកហើយថា អ្នកហៅមកបរិភោគអាហារ

ពេលនេះ ខ្ញុំគឺអរគុណណាស់ហើយ តែហេតុម្តេចក៏បានជាយកការស្រុកកេងជ័រមកប្រាប់ឲ្យវេវិទនមិនបានឲ្យសប្បាយទៅវិញដូច្នេះ ឥឡូវយើងក៏ស្រវឹងជ្រុលបន្តិចទៅហើយ បើមិនគិតដល់ការដែលធ្លាប់កប់គានស្រឡាញ់គ្នាមកពីដើម ក៏នឹងបណ្តាលឲ្យកើតជារឿងទាស់ទែងគ្នាជាធំ ខ្ញុំក៏រម្ងាប់កំហឹងច្រើនណាស់ ពេលនេះសុំលាអ្នកត្រឡប់ទៅវិញសិន ចាំថ្ងៃក្រោយខ្ញុំនឹងសុំអញ្ជើញអ្នក ទៅពិសាល្បៀងខាង ខ្ញុំឯស្រុកកេងជ័រម្តងវិញ ហើយក៏ដឹកដៃឡោសុកចេញទៅដល់ក្រៅបន្ទាយ ។

ឯកាំឡេងនិងលីបងដែលឃុំទាហានទៅពួនបង្កប់នៅក្បែរនោះ លុះក្រឡេកឃើញគួនអ៊ូកាន់លំពែងម្ខាង ដឹកដៃឡោសុកម្ខាងចេញមក លុះនឹងស្ទុះចេញទៅធ្វើអន្តរាយគួនអ៊ូតាមសញ្ញា ក៏ឆែកខ្លាចថា គួនអ៊ូនឹងប្រហារជីវិតឡោសុកជាប្រាកដ ឯគួនអ៊ូសោតក៏ដឹកដៃឡោសុកទៅដល់មាត់ច្រាំងតាំងតែនិយាយថា យើងអរគុណអ្នកច្រើនណាស់ សុំឲ្យអ្នកនៅជាសុខសប្បាយចុះ ថាហើយក៏គំនាប់លាឡោសុកចុះទៅក្នុងទូក ឲ្យទាហានបើកក្តោងចេញទៅដល់ស្រុកកេងជ័រ ឯឡោសុកក៏ត្រឡប់ចូលក្នុងបន្ទាយវិញ ហើយឲ្យគេហៅកាំឡេង នឹងលីបងចូលទៅប្រឹក្សាថា យើងគិតធ្វើប្រទូសរ៉ាយគួនអ៊ូគ្រានេះ ក៏មិនសមសេចក្តីគិតសោះ បើដូច្នេះយើងនឹងគិតធ្វើម្តេចតទៅទៀត ។ លីបងឆ្លើយថា លោកត្រូវធ្វើសំបុត្រមួយទៅដល់ស៊ុនគួនថា ការដែលគិតធ្វើអន្តរាយគួនអ៊ូនោះ មិនបានដូចប្រាថ្នា

ទេ សុំឲ្យរៀបចាត់ចែងលើកទាហានជាច្បាប់ទ័ព ទៅវាយយកស្រុកគេឯងដីវ៉ៃតម្កងទៅចុះ ឯការខាងមាត់កំពង់នេះ ត្រូវឲ្យលោកនៅគ្រប់គ្រងរក្សាកុំឲ្យកើតអន្តរាយ ៗ ឡេាសុកយល់ឃើញត្រូវ ក៏តែងសំបុត្រតាមពាក្យលិបង ហើយប្រើបំរើសេះឲ្យកាន់ចូលទៅឲ្យស៊ុនគួនឯស្រុកកាំងតាំង ៗ

ស៊ុនគួនទទួលសំបុត្រមើល ដឹងសេចក្ដីហើយ ក៏ទំនុកខ្លាំងណាស់ ទើបឲ្យគេណូ ទាហានអស់ពីក្នុងដែនស្រុកកាំងតាំងត្រៀមទុកស្រេច ដើម្បីនឹងលើកទៅវាយយកស្រុកគេឯងដីវ គ្រប់ទទួលមានបំរើសេះពីទិសខាងជើងចូលមកច្បាំងកាដការថា ឥឡូវចូចូគេណូទាហានបានប្រមាណ ៣ម៉ឺន ខឹងលើកចុះមកវាយយកស្រុកកាំងតាំងហើយ ស៊ុនគួនឮដូច្នោះ ក៏តក់ស្លុតស្មារតី ទើបឲ្យតែងសំបុត្រប្រាប់ខាកដការខាងទិសឯជើងទៅដល់ឡេាសុកថា យើងត្រូវលើកទ័ពទៅតាំងទទួលកងទ័ពចូចូនៅដំបន់ហាប់ហ៊ុយឲ្យឡេាសុកនៅរក្សាមាត់កំពង់យើងឲ្យមាំមួន ហើយស៊ុនគួនក៏ឲ្យទាហានលើកទៅតាំងទល់ទ័ពនៅដំបន់យីស៊ូ តួស៊ុនគួនឯងក៏លើកពលទៅតាំងនៅដំបន់ហាប់ហ៊ុយ ប្រាថ្នានឹងទទួលទ័ពចូចូ ៗ

ឯចូចូក៏ត្រៀមពលយោធា ព្រមព្រៀងស្រេចកាលណានឹងលើកចេញពីស្រុកគ្រង ទទួលប៉ោហានកាន់សំបុត្រ ១ ច្បាប់យកទៅជូនចូចូទទួលយកទៅមើលឃើញសេចក្ដីថា ខ្ញុំបាទប៉ោហានសូមគំនាប់មហាទបកដទ័រយកុងសូមជ្រាប ព្រោះពាក្យបូកណពោលទុកថា បណ្ដា

ទាហានសេនាដែលជាទ័ពមកនោះ បើទឹងលើកពលទៅធ្វើសង្គ្រាម នៅទីណាដំបន់ណា ត្រូវឲ្យបំរុងសេនាទាហានទឹងគ្រឿងសាស្ត្រាវុធឲ្យព្រមជាតេជៈពលី ហើយសឹមលើកព្យូហៈចេញទៅជាធម្មតា ចំណែកខាងភ្នាក់ងាររដ្ឋបាលសោត ក៏ត្រូវឲ្យប្រកបចិត្តគិតអធ្យាស្រ័យប្រណីទូទៅដល់អាណាប្រជានុរាស្ត្រឲ្យនៅជាសុខ ហើយត្រូវទំនុកបំរុងស្រុកទេសទុកជាទីពលីតេជៈ សេចក្តីទាំង ២ ប្រការនេះ បើអ្នកណាធ្វើបាន ទើបទឹងតាំងខ្លួនធ្វើជាធំបានតទៅ ឯអាណាខេត្តទាំងអស់នេះ សុទ្ធតែកើតចលាចលរាល់ថ្ងៃ-ខែ ពុំទាន់ស្ងប់រាបទាប លោកបានចេញទៅបង្ក្រាបបាន ៩ ភាគហើយ នៅសល់តែ ១ ភាគ គឺស្រុកកាំងតាំងនិងស្រុកសែឈួន ដូចជាស្រុកកាំងតាំងនោះ ផ្លូវក៏ជាច់ស្រយាលឆ្ងាយ ព្រោះជាជាយមាត់ឆ្នេរសមុទ្រផុតស្រុកទាំងពួង ឯស្រុកសែឈួនសោត ក៏ជាផ្លូវទៅមកលំបាកណាស់ ព្រោះជាច្រកជ្រោះជ្រលងដងលង្អកភ្នំច្រើនអន្លើ បើលោកទឹងលើកទ័ពទៅរាយយកស្រុកកាំងតាំងគ្រានេះ មុខជាពលទាហានបានសេចក្តីលំបាកណាស់ សុំឲ្យលោកបង្អង់ឈប់បំរុងសេនាទាហាន ឲ្យមានកម្លាំងសិនសឹមលើកទៅ គង់ទឹងមានជ័យជំនះដោយងាយ ។

ចូឆ្ងូមើលយល់សេចក្តីសំបុត្រដូច្នោះហើយ ក៏ឲ្យបញ្ឈប់កងទ័ពទុកមួយអន្លើ ហើយតាំងរិះគិតធ្វើតាមឧបាយនៃសំបុត្រប៉ោហាន់នោះ ទោះមាននរណាខ្លាំងពូកែក្លាហាន ក៏ឲ្យយកខ្លួនមកចូលធ្វើការរាជការព្យា-

បាលរក្សាទុក ក្នុងខណៈនោះ មានឈ្មោះអងសាន គោស៊ុប អ៊ីខែ ខុចាប់ ៤ នាក់នេះប្រឹក្សាឃើញព្រមគ្នា ក៏ចូលទៅដំរាបប្ដឹងចូឆូថាព្រះតេជព្រះគុណជាមនុស្សមានសតិបញ្ញា បានទំនុកបំរុងស្រុកទេសផែនដីឲ្យបានសេចក្ដីសុខក្សេមក្សាន្ត បានប្រាបប្រាមសឹកសត្រូវក៏រាបទាបអស់ហើយ គួរនឹងលើកទីជាម្ចាស់វ៉ុយអង គឺស្ដេចតាងក្រុមបាន ចូឆូបានស្ដាប់ក៏មិនទាន់តបប្រការម្ដេច ស៊ុនហ៊ុវឮមន្ត្រីទាំង ៤ នាក់ស្នើសេចក្ដីដូច្នោះ ក៏ឆ្លើយទាស់ថា សព្វថ្ងៃនេះ លោកក៏បានជាទីវ៉ុយកុងហើយគឺជាធំលើសមន្ត្រីខ្ញុំរាជការទាំងពួង ដែលអ្នក ៤ នាក់ សុំឲ្យលោកឡើងទីជាវ៉ុយអងនោះ លើសនិស្ស័យណាស់ ។

ចូឆូឮដូច្នោះ ក៏ខឹងប្រឡោតថា អ្នកឯងមកស្រដីមើលងាយយ៉ាងនេះនឹងចង់ឲ្យដូចស៊ុនហុកទៅឬ ។ ស៊ុនហ៊ុវឃើញចូឆូខឹងដូច្នោះ ក៏មិនហ៊ានតបថាអ្វីទៀត ទើបលាត្រឡប់ថយចេញមក លុះទៅដល់ផ្ទះអាត្មាក៏ឲ្យឈឺផ្សាទោមនស្សតូចចិត្តណាស់ ចេះតែក្រំចិត្តទាល់តែក្ស័យជីវិតទៅ ចូឆូដឹងជាស៊ុនហ៊ុវអនិច្ចកម្ម ក៏អាណិតស្ដាយណាស់ ឲ្យយករបស់មាសប្រាក់ទៅរៀបធ្វើការសពតាមទម្លាប់ប្រពៃណី ហើយឲ្យហែទៅបញ្ចុះតាមទំនៀម ឯការដែលប្រុងនឹងឡើងទីជាវ៉ុយអងនោះ ចូឆូក៏បង្អង់ទៅវិញ ។

លុះអំណោះមកថ្ងៃមួយនោះ ចូឆូក៏កាន់ក្របីចូលទៅទីខាងក្នុងព្រះបរមរាជវាំង ព្រះចៅហៀនតេ នឹងព្រះនាងហុកហៅ ជាព្រះអគ្គមហេសី

ក្រឡេកឃើញកំសួតព្រះទ័យ បួចក៏ទូលន័យថា ឥឡូវស៊ិនគួនទៅវាយស្រុកកាំងតាំង នឹងឡៅពីទៅវាយស្រុកសែឈួនទាំង២មណ្ឌលនេះវឹងខឹង ខាំងពូកែមិនបានមកចំណុះចុះចូលស្តាប់បង្គាប់ក្រោមព្រះបាទតាមចូកណកជប្រពៃណីជាយូរមកហើយ ។ ព្រះចៅហៀនតេទ្រង់តម្រាស់ត្រាស់តបថា ការទាំងនេះ នឹងមកប្រាប់យើងធ្វើអ្វី នឹងត្រូវការអ្វីក៏ស្រេចតែវុយកុងចុះ ។ បួចពុព្រះវាចាដូច្នោះ ក៏ខឹងណាស់ ឆ្លើយតបថា ព្រះអង្គទ្រង់មានព្រះបន្ទូលដូច្នោះ ដូចជានាំឲ្យមនុស្សទាំងពួងមានសេចក្តីតរហោទិន្នាដល់ទូលព្រះបង្គំ ។ ព្រះចៅហៀនតេត្រាស់ថា ការស្រុកទេសទាំងប៉ុន្មាន បើលោកមិនជួយទំនុកបំរុងទេ ក៏មិនបានសេចក្តីសុខក្សេមក្សាន្ត ព្រោះផែនដីទាំងនេះ ពិតជារបស់យើងមែន តែស្រេចនៅលោកតាតែឯងទាំងអស់ហើយ បើលោកនឹងគិតធ្វើការអ្វីៗយើងនឹងខឹងលោកបាន ។

បួចពុដូច្នោះ ក៏រឹតតែខឹងខាំងណាស់ មិនបានគំនាប់លាតាមទំនៀមក៏វិលត្រឡប់ទៅកាន់ទីលំនៅវិញ ខន្ទីទាំងពួង កាលបើឃើញបួចវិលផុតទៅហើយ ក៏នាំគ្នាចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេថា ទូលព្រះបង្គំជាខ្ញុំបានពុកិត្តិសព្ទថា បួចនោះគិតនឹងឡើងទៅជាស្តេចតាំងក្រុម យូរទៅទូលព្រះបង្គំជាខ្ញុំយល់ឃើញថា មុខជាក្បត់ជំណើមយកកជសម្បត្តិជាប្រាកដពុំខាន ព្រះចៅហៀនតេនឹងព្រះនាងហុកហៅអគ្គមហេសីទ្រង់

ព្រះសណ្ដាប់ដូច្នោះ ក៏ទ្រង់កន្សែងពិលាប ហើយស្ដេចយាងចូលទៅក្នុងព្រះបន្ទំទាំង ២ ព្រះអង្គ ។ ព្រះនាងហុកហៅក្រាបទូលថា ហុកអ៊ួនបិតាខ្ញុំម្ចាស់ ឃើញបួធូធ្វើការរំលោភអាក្រក់ ក៏មានចិត្តក្តាញ់ក្តៅពន់ប្រមាណណាស់ គិតតែនឹងសម្លាប់បួធូចេញឲ្យបាន ខ្ញុំម្ចាស់នឹងធ្វើសំបុត្រផ្ញើទៅបិតាខ្ញុំម្ចាស់ ឲ្យទ័រគិតកំចាត់វាចេញឲ្យបានឆាប់ ។

ព្រះចៅហៀនតេត្រាស់ថា ដែលចៅនឹងឲ្យសំបុត្រទៅដល់បិតានោះ យើងខ្លាចក្រែងដូច កាលយើងសរសេរអក្សរនឹងលោហិតទៅដល់ តាំងស៊ិនធ្វើការមិនកំបាំង បួធូចាប់បាន ក៏សម្លាប់អស់ទាំងពួកក្រុមជាច្រើននាក់ គ្រានេះបើចៅនឹងធ្វើការក្រែងមិនជិត យើងនឹងនាំគ្នាក្ស័យជីវិតទេដឹងឬ ? ។ ព្រះនាងហុកហៅទូលថា ព្រះអង្គនឹងខ្ញុំម្ចាស់មានជីវិតរស់នៅសព្វថ្ងៃនេះ ទុកមាបីដូចត្រឡាចនៅក្នុងបន្ទា មិនមានពេលណាឲ្យសប្បាយនោះគ្មាន បើតេជៈបារមីរបស់ព្រះអង្គនឹងខ្ញុំម្ចាស់មានមកក៏គង់គិតធ្វើការនេះបានហើយទៅ បើគ្មានបុណ្យវាសនាមកទេ ស្លាប់ជីវិតទៅ ប្រសើរជាងរស់នៅ ខ្ញុំម្ចាស់ឃើញបកស៊ុនខន្ទីនោះមានចិត្តស្មោះតទៀងត្រង់ ល្មមនឹងប្រើការបាន នឹងឲ្យកាន់សំបុត្រចេញទៅឲ្យបិតាខ្ញុំម្ចាស់ ។

ព្រះចៅហៀនតេយល់ឃើញត្រូវ ក៏ត្រាស់ឲ្យហៅបកស៊ុនខន្ទីចូលទៅគាល់ ហើយទ្រង់ព្រះកន្សែងត្រាស់ប្រាប់ពីរឿងដែលជាទុក្ខនោះ

ឲ្យស្តាប់ហើយត្រាស់ថា ចូចូធ្វើការអាក្រក់លាមក ទាល់តែបានឡើងយសសក្តិជាទីវុយកុង ហើយនៅមានចិត្តគិតប្រុងនឹងលើកខ្លួនជាទីវុយអងទៀត ប្រាថ្នានឹងជ្រៀតជ្រែកដណ្តើមយករាជសម្បត្តិរបស់យើង ខ្លួនយើងនឹងអគ្គមហេសីបានសេចក្តីទុក្ខក្តៅ ដូចដេកនៅក្នុងគំនរភ្លើងជានិច្ចនិរន្តរ៍ នឹងគយគន់មើលក៏មិនឃើញមានអ្នកឯណានឹងជួយឲ្យរួចពីសេចក្តីក្តៅនេះបាន ឃើញតែអ្នកមួយដែលនឹងជួយឲ្យបានសេចក្តីសុខជាស្ងាត់ កាន់សំបុត្រទៅដល់ហុកអ៊ួនដែលជាបិតាព្រះអគ្គមហេសីនៃយើង ដើម្បីនឹងឲ្យជួយកំចាត់ចូចូចេញ ។

បកស៊ុនបានឮព្រះបន្ទូលដូច្នោះ ក៏យំខ្សឹកខ្សួលអួលទក ក្រាបទូលស្នងព្រះរាជឱង្ការថា ទូលព្រះបង្គំជាខ្ញុំបាននៅជាសុខក្រោមម្លប់ព្រះបរមពោធិសម្ភារព្រះអង្គមកយូរហើយ វេលានេះនឹងសុំយកជីវិតគិតធ្វើថ្វាយព្រះតេជព្រះគុណកាន់សំបុត្រចេញទៅឲ្យបាន សូមឲ្យទ្រង់ព្រះអក្សរចុះ ព្រះនាងហុកហៅក៏សរសេរសំបុត្រតាមរឿងរ៉ាវ ដែលមានសេចក្តីទុក្ខក្តៅគ្រប់ប្រការ ហើយប្រកស្រោមបិទយ៉ាងជិតប្រគល់ឲ្យបកស៊ុន ។ ទទួលយកសំបុត្រនោះទៅលាក់ក្នុងកន្ទុងសក់ ហើយក៏ថ្វាយបង្គំលាចេញទៅ ពីក្នុងព្រះមរមកដាក់ជិះតម្រង់ទៅផ្ទះហុកអ៊ួន លុះទៅដល់ហើយក៏ហុចសំបុត្រឲ្យទៅហុកអ៊ួន ហើយនិយាយប្រាប់សេចក្តីគ្រប់ប្រការ ។

ហុកអ៊ួនទទួលសំបុត្រទៅមើលដឹងថា លាយលក្ខអក្សរដៃព្រះនាងហុក

ហើផ្ញើជាបុត្រប្រាប់សេចក្ដីទុក្ខក្ដៅគ្រប់ប្រការថា ការនេះឃើញតែបិតានឹងជួយរិះគិតការកំបាំង ដើម្បីនឹងកំចាត់ប្អូនចេញ ទើបផែនដីនឹងបានសេចក្ដីសុខតទៅ ហុកអ៊ួនដឹងក្នុងសេចក្ដីសំបុត្រដូច្នោះក៏និយាយថា សព្វថ្ងៃនេះប្អូនកំរើបចិត្តគិតធ្វើការជាធំពន្ទឹកពេកណាស់ ទាំងត្រៀកនឹងក្នុកក៏មានជ្រួតជ្រាបដឹងទូទៅគ្រប់ច្រកល្ហកមិនសូវកំបាំង ដែលយើងនឹងធ្វើការអ្វីជាសេចក្ដីស្រាលគំនិតគិតឲ្យជ្រៅល្អិតទេ ក៏គង់មិនសម្រេច គេចត្រឡប់វណ្ណពន្ធលើខ្លួនវិញមិនខាន បើដូច្នោះគួរតែឲ្យសំបុត្រសម្ងាត់ទៅដល់ឡៅពីនឹងស៊ិនគួន ឲ្យលើកកងទ័ពមកធ្វើការខាងក្រៅ ប្អូនក៏គង់ចេញទៅធ្វើការតទល់ ហើយយើងចាត់មនុស្សដែលមានចិត្តសុចរិតត្រង់នឹងផែនដីទៅធ្វើការជាកលសឹកខាងក្នុងគង់នឹងបានសម្រេចតាមប្រាថ្នា បកស៊ិនស្ដាប់យល់ឃើញត្រូវ ហុកអ៊ួនក៏តែងសំបុត្រ ២ ច្បាប់បញ្ជូនឲ្យទៅឡៅពីនឹងស៊ិនគួន ហើយសរសេរសំបុត្រប្រាប់រឿងរ៉ាវដែលគិតនោះ ផ្ញើទៅព្រះនាងហុកហើឲ្យក្រាបបង្គំទូលព្រះចៅហៀនកេ ១ ច្បាប់ រួចបិទត្រាមប្រគល់ឲ្យបកស៊ិន ។

បកស៊ិនទទួលសំបុត្រនោះមកសឹកលាក់ក្នុងក្ដងសក់ ហើយលាត្រឡប់ចូលទៅក្នុងព្រះបរមរាជវាំង ខណៈនោះមានស្រីដែលស៊ើបការណ៍របស់ប្អូននៅក្នុងព្រះបរមរាជវាំង បានដឹងសេចក្ដីច្បាស់ក៏ទៅប្រាប់ប្អូន ។ បានដឹងការណ៍ក៏នាំទាហានស្រួតទៅស្ទាក់ចាំបកស៊ិន នៅមាត់ទ្វារព្រះរាជ

វាំង លុះឃើញបកស៊ិនដើរចូលមក ចូចូសួរថា អ្នកឯងនេះទើបមកពីណា ? បកស៊ិនឆ្លើយថា ព្រះនាងហុកហៅទ្រង់ប្រឈួន ឲ្យខ្ញុំបាទចេញទៅរកពេទ្យហ្ន ចូចូថា ឯណាមិនឃើញពេទ្យនោះ បកស៊ិនឆ្លើយថែថា ពេទ្យមកតាមក្រោយ ចូចូថា ខ្លួនមានពិរុទ្ធហើយ ទើបឲ្យគាហានដោះអាវបកស៊ិនពិនិត្យមើល គីមិនឃើញមានអ្វីជាសំគាល់ គីឲ្យបើកលែងបកស៊ិនដើរចេញទៅ បកស៊ិនដើរចេញទៅបានប្រហែល ១០ ព្យាម ទទួលខ្យល់ផាត់ធ្លាក់មួកពីលើក្បាល ចូចូឃើញដូច្នោះក៏មានសេចក្ដីសង្ស័យ ទើបឲ្យហៅបកស៊ិនត្រឡប់មកពិនិត្យមើលម្ដងទៀត គឺមិនឃើញមានពិរុទ្ធអ្វី ចូចូឲ្យបើកលែងទៅ បកស៊ិនភ័យតក់ស្លុតលាចូចូដើរចេញទៅក៏មួកលើក្បាលរបើកធ្លាក់ទៅវិញ ព្រោះភ័យតក្កមាខ្លាំងណាស់ ប្រឹងដើរហ័សទៅឲ្យឆុត ចូចូឃើញប្លែកគិតថា បកស៊ិនប្រហែលមានហេតុអ្វីក្នុងខ្លួនបានជាតក់ស្លុតដូច្នេះ គីឲ្យហៅត្រឡប់មកពិនិត្យមើលទៀត លុះសង្កេតមើលសព្វទៅ ក៏ឃើញសំបុត្រនូវក្នុងក្នួងសក់បកស៊ិន ចូចូឲ្យគាហានឃុំខ្លួនទុក ហើយយកសំបុត្រនោះមកហែកស្រោមមើលឃើញសេចក្ដីថា ខ្ញុំហុកអ្នកដែលគិតនឹងកំចាត់ចូចូចេញនោះ ចាំគិតផ្ញើសំបុត្រទៅបញ្ចុះបញ្ចូលឡៅពីនឹងស៊ិនគួនឲ្យលើកកងទ័ពមកសិន ទើបនឹងគិតការនោះបានហូត ។

ចូចូឃើញសេចក្ដីសំបុត្រដូច្នោះក៏ខឹងណាស់ ឲ្យគាហានទាំ

បកស៊ុនទៅឯផ្ទះ ហើយក៏ឃុំខ្លួនបកស៊ុនទុក នាំទាហាន ៣ ពាន់ទៅព័ទ្ធផ្ទះហ៊ុកអួន ចាប់ខ្លួនហ៊ុកអួនទាំងគ្រប់ស្រីគ្រប់ក្រពួកទាំងអស់ យកទៅដាក់គុកទុក ហើយរឹបយកទ្រព្យរបស់អស់ពីក្នុងផ្ទះក្រៅផ្ទះ ពួកទាហានក៏រើឃើញសំបុត្រព្រះនាងហ៊ុកហៅនៅលើផ្ទះហ៊ុកអួនយកទៅជូន ចូឆូទទួលយកទៅមើលឃើញសេចក្ដីខឹងណាស់ ប្រើទាហានឲ្យទៅព័ទ្ធចាប់បណ្ដាវង្សត្រកូលញាតិបងប្អូនព្រះនាងហ៊ុកហៅ យកទៅដាក់គុកទាំងអស់ លុះវេលាព្រឹក ចូឆូប្រើអេកលីឲ្យលើកទាហាន ៣០០ នាក់ កាន់គ្រឿងសាស្ត្រាវុធគ្រប់ដៃ ហើយចូលទៅប្រុងទីវាំងយកត្រាសម្រាប់ព្រះអគ្គ-មហេសី ខណៈនោះព្រះចៅហៀនតេ ទ្រង់ស្ដេចយាងចេញមកកាន់ទីប្រជុំ ខុនម៉ឺនមន្ត្រី ទតព្រះនេត្រឃើញអេកលីលើកទាហានចូលមកសន្ធឹកសន្ធាប់ដូច្នោះ ក៏ទ្រង់ត្រាស់សួរថា អ្នកឯងចូលមកនេះដោយមានការអ្វី អេកលីទូលថា វុយកុងប្រើឲ្យទូលបង្គំចូលមកយកត្រាសម្រាប់ទីព្រះអគ្គមហេសី ។

ព្រះចៅហៀនតេ ទ្រង់ព្រះសណ្ដាប់ស្លុតព្រះទ័យ ទ្រង់ព្រះដំរិះថា ការដែលគិតនោះប្រហែលជាដឹងដល់ចូឆូហើយឬ បានជាកើតហេតុដូច្នេះ ទ្រង់មានព្រះបរិវិតក្កទុក្ខទោមនស្សពន់ប្រមាណណាស់ មិនបានត្រាស់ថាប្រការដូចម្ដេចសោះ អេកលីក៏នាំទាហានចូលទៅដល់ល្វែងក្នុង ហើយស្រែកប្រកាសថា ស្រីបំរើឯណាដែលបានរក្សាត្រាសម្រាប់ទីព្រះ

អគ្គមហេសីនោះ ចូរយកត្រានោះមកប្រគល់ឲ្យយើងជាប្រញាប់ តាមបង្គាប់ឪយកុង ស្រីបំរើដែលសម្រាប់រក្សាត្រាបានឮដូច្នោះភ័យតក់ស្លុតក្នុងចិត្ត ទើបយកត្រានោះប្រគល់ឲ្យអេកលី ។ បានត្រាហើយ ក៏នាំទៅប្រគល់ឲ្យចូច្ចូ ។

ខណៈនោះ ព្រះនាងហុកហៅឃើញទាហានចូច្ចូទៅស្រែកកំហែងទារយកត្រាសម្រាប់ទីព្រះអគ្គមហេសីដូច្នោះ ក៏ភ័យខ្លាំងណាស់ ទើបគិតថា សេចក្ដីដែលគិតឲ្យសំឡុតដល់បិតានោះ ប្រហែលចូច្ចូដឹងប្រាកដហើយ ទើបបង្កើតហេតុដូច្នេះ វេលានេះជីវិតរបស់យើងមុខជាស្លាប់អន្តរាយជាប្រាកដហើយ ។ ព្រះនាងក៏ចូលទៅពួនក្នុងព្រះដំណាក់មួយអន្ទើ ហើយបង្គាប់ឲ្យទាក់សោពីក្នុងទីងក្រៅ ប្រាថ្នាមិនឲ្យអ្នកឯណាចូលទៅធ្វើអន្តរាយបាន ។

ចូច្ចូ ក៏ប្រើហ៊ុយហ៊ីមឲ្យនាំទាហាន ៥០០ ចូលទៅចាប់ព្រះនាងហុកហៅ ហួហ៊ុមកាលចូលទៅដល់ល្វែងក្នុង ក៏សួរស្រីបំរើទាំងពួងថា ព្រះនាងហុកហៅនៅឯណា បណ្ដាស្រីខាងក្នុង បានឮដូច្នោះ ភ័យខ្លាំងណាស់ឆ្លើយថា ព្រះនាងហុកហៅតែទៅពួនឯណាមិនដឹងទេ ហួហ៊ុមនាំទាហានចូលទៅរើរកមើលគ្រប់ទីកន្លែងក៏មិនប្រទះឃើញឡើយ លុះក្រឡេកឃើញដំណាក់មួយខ្ទង់បិទទ្វារជិតប្លែកណាស់ ក៏ឲ្យទាហានបុកទំលាយចូលទៅ ហួហ៊ុមចូលទៅតាមឃើញព្រះនាងហុកហៅនៅពួនក្នុង

ដំណាក់នោះ  ក៏ចូលទៅចាប់សក់ដឹកកន្ត្រាក់អូសចេញមកពីក្នុងដំណាក់ព្រះនាងហុកហើរភ័យខ្លាំងណាស់  ក៏ស្រែកយំខ្លួញអង្វរថា  លោកចូរអាណិតកុំឲ្យខ្ញុំដល់នូវសេចក្ដីស្លាប់ឡើយ ហ្លួហ៊ុមថា យើងជាបំរើគេ ធ្វើតែតាមបង្គាប់នាយទៅហ្វាយ  សូមនាងហុកហើរទៅអង្វរវ៉ុយគុងចុះ ហើយក៏ដឹកសក់អូសកន្ត្រាក់  ព្រះនាងចេញមកពីក្នុងព្រះដំណាក់  ទៅដល់មុខព្រះលាន ។

ព្រះចៅហៀនតេឃើញដូច្នោះ  ស្លុតព្រះទ័យខ្លាំងណាស់  ហើយស្ដេចចេញទៅឱបព្រះអគ្គមហេសីទ្រង់ព្រះកន្សែងសោកាពិលាប  ព្រះនាងហុកហើរក៏ទ្រង់ព្រះកន្សែងទូលតបថា  ជីវិតខ្ញុំម្ចាស់  វេលានេះមុខជាមិនរួចឡើយ  ព្រះចៅហៀនតេត្រាស់ប្រលោមថា  ពេលវេលានេះជាកម្មវេររបស់យើង  តាមមកតាន់ហើយ  កុំថាឡើយតែជីវិតទៅដែលត្រូវស្លាប់នោះ  ពោះជីវិតយើងនេះក៏មិនដឹងថានឹងមានសេចក្ដីអន្តរាយនោះទង់មកដល់ពេលណា  ហ្លួហ៊ុមឃើញដូច្នោះក៏ស្រែកកំហែកថា  វ៉ុយគុងឲ្យមកយកខ្លួនព្រះអគ្គមហេសីចេញទៅជាប្រញាប់  ហេតុម្ដេចព្រះអង្គមកទ្រង់ព្រះកន្សែងឲ្យយឺតការណ៍ដូច្នេះ  ទោសនោះមិនធ្លាក់ទៅលើមនុស្សបំរើទេឬ? ថាហើយក៏ឲ្យទាហានអូសទាញកន្ត្រាក់នាំព្រះនាងចេញ ។

ព្រះចៅហៀនតេទតឃើញ  ក៏រឹតតែទ្រង់ព្រះកន្សែងពន់ពេកណាស់មុខគួរឲ្យអាសូរព្រះមហាក្សត្រ  ដែលរាជសម្បត្តិមកកើតវិបត្តិដូច្នេះ  លុះ

ទ្រង់ក្រឡេកទៅឃើញអេកលី ដែលចូចប្រើឲ្យយកត្រាសម្រាប់ទីព្រះអគ្គមហេសីនោះត្រឡប់ចូលមកគាល់ក៏ត្រាស់សួរអេកលីថា ស្រុកទេសយើងពីដើមមកមានកើតហេតុដូច្នេះទេ ? អ្នកឯងដែលឃើញខុះឬទេ អេកលីក៏មិនបានទូលតបថា ប្រការម្ដេច ព្រះចៅហៀនគេក៏ទ្រង់ព្រះកន្សែងតាលតែដួលសន្ធប់នៅទីនោះ អេកលីឃើញដូច្នោះ ក៏ប្រើខន្ទីឲ្យចូលទៅត្រាហ៍ព្រះអង្គ បានដឹងព្រះស្មារតីឡើងវិញ ហើយអញ្ជើញស្ដេចឲ្យទៅខាងក្នុង ៗ

ខណៈនោះហូហ៊ុម ក៏នាំព្រះនាងហុកហៅទៅជូនចូច ៗ ក៏សួរថា ខ្លួនអញទសព្រហ៍រះគិតបំបាត់សឹកសត្រូវចម្រូងចម្រះក្នុងព្រះនគរ ឲ្យរាបទាបហេតុអ្វីខ្លួនឯងដែលបានតែសេចក្ដីសុខក៏នៅមិនគាប់ចិត្តទៀត ឯងជាមនុស្សមិនដឹងគុណ គិតទ្រយសទ្រស្តគុណអញ គប់គិតគ្នានឹងអាពុកបងធ្វើទុកឲ្យអញវិនាសវិញដូច្នេះ បើអញនឹងទុកឲ្យឯងនៅតទៅទៀតគង់នឹងប្រទុសកាយអញពុំខាន ថាហើយក៏ឲ្យទាហានយកដំបងសំពងកាយដំតាលតែព្រះនាងហុកហៅទទួលអនិច្ចកម្មក្នុងខណៈនោះ ហើយឲ្យទាហានទៅចាប់ព្រះកជបុត្រព្រះនាងហុកហៅទាំងពីរព្រះអង្គ ដែលកើតពីព្រះចៅហៀនគេនោះ នាំទៅប្រហារជីវិតបង់ លុះវេលាកណ្ដាលយប់ ចូចក៏ឲ្យនាំយកខ្លួនហុកអួន និងបកស៊ុន នៅបណ្ដាគ្រប់បក្សពួកទាំងប៉ុន្មាន ហើយនឹងបងប្អូនសាច់សន្ដានព្រះនាងហុកហៅទៅប្រហារជីវិតទាំងអស់ ៗ

ខណៈនោះ ព្រះចៅហៀតេ តាំងពីបានទៅគង់នៅក្រុងហ៊ូតេចំនួន ១៩ ឆ្នាំ (ពុទ្ធសករាជ ៧៤៧) វេលានោះព្រះអង្គទ្រង់សោកាល័យព្រះអគ្គមហេសី នូវព្រះរាជបុត្រ ទាំងពីរព្រះអង្គគ្រប់វេលា មិនបានស្រង់មិនបានសោយព្រះក្រយាហារជាយូរថ្ងៃ ចុច្ចឹងដូច្នោះ ក៏ចូលទៅគាល់ហើយទូលថា ព្រះអង្គកំទ្រង់ព្រះវិតក្កសោះឡើយ ដូចជាខ្ញុំទូលបង្គំនេះ ពីដើមរៀងមកក៏បានទូលទុកថា នឹងជួយទំនុកបំរុងផែនដីតទៅ បើនរណាប្រព្រឹត្តខុសត្រូវក៏ត្រូវធ្វើតាមគុណនឹងទោស ទូលព្រះបង្គំមិនបានគិតជាចិត្តពីរសោះ តាំងចិត្តស្មោះថានឹងជួយទំនុកបំរុងព្រះអង្គដោយសុចរិតប្រាកដ ឥឡូវនេះទូលព្រះបង្គំក៏នៅមានបុត្រីម្នាក់ មានប្រាជ្ញាឆ្លៀវឆ្លាតប្រកបដោយអធ្យាស្រ័យទៀងត្រង់ល្អ ទូលព្រះបង្គំនឹងថ្វាយព្រះអង្គ ព្រះចៅហៀនតេទ្រង់ព្រះសណ្ដាប់ក៏មិនអាចនឹងទទឹងទាស់អធ្យាស្រ័យ ព្រមទទួលតាមពាក្យចុច្ចទូលនោះគ្រប់ប្រការ ។

ខណៈនោះ ព្រះចៅហៀតេគង់ក្នុងក្រុងហ៊ូតេ ២០ ឆ្នាំ (ពុទ្ធសករាជ ៧៤៨) ជាទេសកាលខែមាឃចូលឆ្នាំចិន ចុច្ចក៏រៀបតុបតែងស្រ្តីនាំចូលទៅថ្វាយព្រះចៅហៀនតេ ហើយតាំងបុត្រនោះពេញទីជាអគ្គមហេសី បណ្ដានាម៉ឺនសព្វមុខមន្ត្រីព្រះចៅហៀនតេ ក៏កោតខ្លាចអំណាចចុច្ចទាំងអស់ នឹងរកអ្នកឯណា ១ អាចពិតទូលពោលទទឹងទាស់ដោយប្រការម្ដេចៗ ក៏គ្មាន ចុច្ចក៏រឹតតែកំរើបចិត្តគិតធ្វើអាក្រក់ផ្សេងៗ តាមអំពើចិត្តឥតកោត

ញះញើតព្រះចេស្តា ។

ថ្ងៃមួយ ចូចូឲ្យហៅនាម៉ឺនមុខមន្ត្រីចូលទៅប្រជុំប្រឹក្សាថា យើងបានបង្រុំសេនាទាហានក៏មានកម្លាំងបរិបូណ៌ហើយ ឥឡូវយើងចង់លើកទ័ពទៅវាយយកស្រុកសៃឈួន និងស្រុកកាំងតាំង អ្នកទាំងអស់គ្នាទាំងយល់ឃើញដូចម្ដេច កាសៀងឆ្លើយថា សុំលោកឲ្យហៅខ្លួនតោយ៉ីន ទឹងហៃហ្វូទុនឲ្យចូលមកប្រឹក្សាការរាជការសិន បើឃើញបានការហើយ សឹមលោកលើកកងទ័ពទៅចុះ ចូចូយល់ឃើញត្រូវផង ក៏ប្រើបរើឲ្យស្រូតរួតទៅហៅខ្លួនតោយ៉ិន ទឹងហៃហ្វូទុន ដែលនៅស្រុកស៊ីងយ៉ុងឲ្យចូលមក ។

ឯតោយ៉ិនទឹងហៃហ្វូទុនដឹងការក៏ស្រូតរូតចូលទៅដល់ក្រុងហ្វូតោ តែតោយ៉ីនចូលទៅដល់មុន ខណៈនោះចូចូសេពសុរាស្រវឹងក៏ចូលទៅដេកខាងក្នុង ទទួលតោយ៉ិនឡើងទៅទីងចូលទៅគំនាប់ចូចូ ខៅជូកាន់លំពែងយាមនៅខាងក្រៅ កាលឃើញតោយ៉ិនចូលទៅដល់ ក៏ឃាត់ហាមថា អ្នកកុំអាលចូលទៅ តោយ៉ិនឮដូច្នោះ ខឹងណាស់ថា ខ្លួនអញជាកូនក្មួយសាលោហិតរបស់មហាឧបរាជ ខ្លួនគ្រាន់តែជានាយទាហានទេ ហេតុម្ដេចអាចហ៊ានមកហាមឃាត់អញដូច្នេះ ខៅជូតបថាអ្នកឯងជាកូនក្មួយវុយកុងក៏មែន តែវុយកុងចាត់ប្រើឲ្យខ្លួនចេញទៅឈរខែត្រក្រៅទៅហើយ ខ្លួនយើងជានាយទាហាននៅរក្សាអង្គខាងក្នុង អ្នកឯងមកពីស្រុកឆ្ងាយ យើងនឹងបណ្ដោយឲ្យចូលទៅតែម្ដងម្ដេចបាន តោយ៉ិនត្រឡប់គិតឃើញ

ត្រូវ ក៏ថយចេញទៅនៅខាងក្រៅវិញ ។

គន់ខណៈ ដែលចៅយិ៉ន ទីងទៅចូប្រកែកគ្នានោះ ចូចូនៅមិនទាន់ដេកលក់ទេ បានឮសំដីទៅចូនិយាយដូច្នោះ ឃើញត្រូវតាមទម្លាប់ទំនៀម ក៏សរសើរទៅចូថា មានតម្រិះប្រាជ្ញាជាមនុស្សទៀងត្រង់ លុះវៃហ៊ូទុនមកដល់ទៀត ចៅយិ៉នទីងវៃហ៊ូទុន ក៏ចូលទៅគំនាប់ចូចូ ។ មានសេចក្ដីត្រេកអរណាស់ ទើបប្រឹក្សាចៅយិ៉នទីងវៃហ៊ូទុនថា យើងគិតនឹងលើកកងទ័ពទៅវាយស្រុកកាំងតាំង ហើយនឹងស្រុកសៃឈួន អ្នកទាំងពីរនឹងយល់ឃើញយ៉ាងម្ដេច ? ។

វៃហ៊ូទុនឆ្លើយថា ស្រុកកាំងតាំងនោះ សុំឲ្យលោកបង្អង់ទុកសិនចុះ ព្រោះស្រុកហាន់តុងបីដូចជាដើមផ្លូវស្រុកសៃឈួន សុំឲ្យលោកលើកកងទ័ពទៅវាយយកស្រុកហាន់តុងឲ្យបានសិន សឹមលើកទៅវាយយកស្រុកសៃឈួន គង់នឹងបានដោយងាយ ឯការខាងស្រុកកាំងតាំងវិញ សឹមគិតជាក្រោយតទៅ ចូចូយល់ឃើញត្រូវផង ក៏ឲ្យកេណ្ឌប្រមូលពលទាហានជាច្រើន ហើយឲ្យវៃហ៊ូអៀនទីងទៀវខាប់ជាមេកងទ័ពមុន ចូចូជាមេទ័ពលួង ឲ្យចៅយិ៉នទីងវៃហ៊ូទុនជាមេកងទ័ពក្រោយ ឲ្យនាំស្បៀង លុះបានឫក្សជ័យមង្គល ក៏រៀបពលយោធាចេញពីក្រុងហ៊ូតោ តម្រង់ទៅស្រុកហាន់តុង ។

ខណៈនោះ មានបំរើសេះដឹងការណ៍ ក៏ស្រូតទៅប្រាប់ទៀវឡូទៅ

ហ្វាយស្រុកហាន់តុង ។ ដឹងហើយក៏ប្រឹក្សានឹងទៀវអ៊ូយថា ចូចូលើកទ័ពមកគ្រានេះ យើងនឹងគិតការពារប្រការម្តេច ទៀវអ៊ូយថា ឯស្រុកហាន់តុងនេះជាទីចង្អៀតចង្អល់ មានតែគយអេងប៉េងគួនជាទីប្រជុំផ្លូវសំខាន់ បើប្រសិនជាខូចទីគយនោះហើយ ស្រុកហាន់តុងក៏នឹងខូចទៅឯង ។ ឯមុខគយអេងប៉េងគួននោះ មានភ្នំជាម្ខាង ព្រៃកម្ខាង សូមឲ្យលោកចាត់ទាហានជាពីរកងទៅតាំងបន្ទាយឲ្យមាំមួននៅទីនោះ ដើម្បីនឹងចាំទទួលរងកងទ័ពចូចូទើបនឹងបាន ឯខ្លួនលោកត្រូវនៅរក្សាការពារស្រុកទុកឲ្យមាំមួន ។

ទៀវឡូស្តាប់យល់ឃើញត្រូវ ក៏ចាត់ឲ្យទៀវអ៊ូយនឹងទៀវហៀម ទៀវង៉ុង លើកទាហានជាច្រើនកបន្ទាយរក្សាគយអេងប៉េងគួននោះ នាយទាហានទាំង ៣ នាក់ក៏នាំទាហានទៅដល់ទីនោះ ទៀវអ៊ូយក៏នៅរក្សាទីគយនោះ អៀវហៀម អៀវង៉ុងក៏នាំទាហានចេញផ្លូវឆ្ងាយប្រហែល ៦០០ សិន ឲ្យតាំងបន្ទាយពាយទ័ពនៅទាំងសង៍ខាងផ្លូវ ម្ខាង ៥០០ បន្ទាយ ហើយត្រួតត្រារក្សាពួកពលយោធា និងការពារបន្ទាយជាមាំមួនណាស់ ។

ឯហាហ៊ួអៀននឹងទៀវខាប់ដែលជានាយទ័ពមុខនោះ លុះលើកពលទៅដល់ប្រទល់មុខគ្នាដឹងថាទាហានទៀវឡូ ចេញមកតាំងបន្ទាយការតាមមុខគយ ក៏ឈប់ទ័ពឲ្យតាំងបន្ទាយនៅឆ្ងាយពីគ្នាប្រមាណ ១៥០ សិន

ក្នុងពេលយប់នោះ ទាហានហៃហ្ស៊ីអៀនទឹងទៀវខាប់នឿយណាស់ ក៏ដាក់ឈប់សម្រាកកម្លាំង តាំងតែធ្វេសប្រហែសប្រមាទពុំសូវគិតយាមល្បាតជាមាំមួន ដូនយប់ជ្រៅដល់យាម ១ ប្លាយ អៀវហៀម អៀវស៊ុនជឹងជាកងទ័ពបូច្ចលើកទ័ពមកតាំងនៅជិតគ្នាដូច្នោះ ក៏ប្រឹក្សាគ្នាថា ទ័ពមុខបូច្ចទើបនឹងមកដល់ ទាហានកំពុងហត់នឿយណាស់ ខ្លះក៏ដេកលក់ដេរដាស យើងត្រូវរកឱកាសចេញទៅប្លន់បន្ទាយ គង់នឹងងាយបានជ័យជំនះជាប្រាកដ លុះគិតស្រេច ក៏ចាត់ចែងចែងទាហានលបចេញទៅ យកភ្លើងដុតឆេះសន្ធោសន្ធៅគ្រប់បន្ទាយហៃហ្ស៊ីអៀនទឹងទៀវខាប់នោះ ហើយក៏បរពលចូលគ្រលុករុកបំពារជុំវិញបន្ទាយ បានបែកធ្លាយប្រកាប់សម្លាប់ទាហានហៃហ្ស៊ីអៀនទឹងទៀវខាប់ស្លាប់ជាច្រើនណាស់ ឯហៃហ្ស៊ីអៀនទៀវខាប់នូវទាហានដែលមិនបានដឹងខ្លួន ក៏បែកប្រពាក់ប្រពូនខ្ចាត់ខ្ចាយរត់ទៅក្រោយបណ្ដោយគ្នា ចូលទៅពណ៌នាប្រាប់បូច្ចគ្រប់ប្រការ ។

បូច្ចដឹងដូច្នោះ ខឹងណាស់ថា ខ្លួនឯងបានធ្វើសឹកសង្គ្រាមជាមួយនឹងយើងរៀងមកជាយូរហើយ មិនគួរឡើយនឹងធ្វេសប្រមាទ គួរតែគិតឲ្យដឹងបទបាទតាមទម្លាប់លើកទ័ពទៅដល់យល់ថា ទាហានកំពុងហត់នឿយត្រូវឲ្យដាក់យាមល្បាតក្រវែលប្រុងប្រយ័ត្នការ ឲ្យមាំមួនឲ្យណាស់ វេលានេះខ្លួនមកធ្វើល្មើសធ្វេសប្រហែស ហេតុការណ៍ឲ្យបរាជ័យដល់សត្រូវដូច្នេះ ទោសខ្លួនជាទម្ងន់ធ្ងន់ប្រមាណណាស់ ថាហើយ ក៏បង្គាប់ឲ្យ

ចាប់ខ្លួនហៃហ៊្វូអៀនទឹងទៀវចាប់ទៅសម្លាប់ ទីប្រឹក្សាទាំងអស់នាំគ្នាចូលទៅគំនាប់សុំទោស ចូឆូអត់សន្ដោសលើកទោសឲ្យ ហើយលើកកងទ័ពស្រូតចូលទៅទៀត ឯផ្លូវដែលទឹងធ្វើដំណើរទ័ពទៅនោះ ជាប្រកជ្រោះជ្រលងដងភ្នំទុរគមញាតស្បាតណាស់ បណ្ដាពលយោធាក៏យាត្រាទៅដោយលំបាកពន់ពេក ចូឆូថា យើងមិនបានដឹងសោះថាផ្លូវមកស្រុកនេះដាច់ស្រយាលលំបាកដូច្នេះសោះ ប្រសិនបើដឹងយ៉ាងនេះ យើងមិនលើកទ័ពមកទេ ហើយឲ្យមានចិត្តគិតព្រួយក្រែងសត្រូវយកទាហានមកពួនបង្កប់នៅទីនោះ ខៅធូទឹងស៊ុឡ្យងឮដូច្នោះ ក៏ចូលទៅខ្សឹបប្រាប់ចូឆូថា វុយកុងកុំមានប្រសាសន៍ដូច្នេះ បើទាហានទាំងអស់ដឹងទឹងនាំឲ្យព្រួយចិត្តពុំបានគិតនឹងខំធ្វើការ ចូឆូយល់ឃើញត្រូវផង លុះដើរឆ្លងទៅដល់កន្លែងបន្ទាយចាស់ ដែលហៃហ៊្វូអៀនទឹងទៀវចាប់តាំងទុក ហើយភ្លើងឆេះអស់ ចូឆូក៏បោះទ័ពនៅទីនោះ ឲ្យកជាបន្ទាយកយចំរូងឡើងវិញ លុះធ្វើរួចក៏កំជាប់នាយទាហានឲ្យប្រុងប្រយ័ត្នត្រួតត្រា រក្សាផ្លាស់ប្ដូរយាមល្បាតក្រវែលមិនឲ្យធ្វេសប្រហែស ។

លុះវេលាព្រឹក ចូឆូក៏ជិះសេះនាំខៅធូ ស៊ុឡ្យងចេញពីបន្ទាយទៅដល់ទីភ្នំមួយ ក៏ឡើងទៅលើកំពូលភ្នំនោះ សំឡឹងមើលទៅឃើញសត្រូវតាំងទ័ពនៅគយជាមាំមួនណាស់ មើលទៅប្រកផ្លូវដែលទឹងចូលទៅតតាំងច្បាំងគ្នាក៏ជាកន្លែងលំបាកទឹងយកជ័យជំនះដោយក្រ និយាយមិន

ទាន់ផុតមាត់ស្រាប់តែឮសំឡេងផាវនឹងសន្ធឹកស្រែក ហ៊ោកឹកកងរំពងចូល
មកចាំងសងខាងផ្លូវ ចូចូភ័យណាស់ក៏និយាយថា យើងនឹងតាំងច្បាំង
យ៉ាងម្ដេច ខៅជូឆ្លើយថា លោកកុំព្រួយ តែខ្លួនខ្ញុំបាទមួយក៏ទទួលតា
សាច្បាំងបាន មិនមានឲ្យអន្តរាយដល់លោកទេ ហើយក៏និយាយនឹងស៊ី
ឡុនថា ឲ្យនាំវុយកុងត្រឡប់ទៅបន្ទាយវិញចុះ ខណៈនោះ អៀវហៀម
អៀវង៉ុងក៏បរសេះនាំទាហានចេញមកពីសងខាងផ្លូវ ខៅជូក៏ចាប់ផាវញាក់
សេះចូលប្រយុទ្ធគ្នា អៀវហៀម អៀវង៉ុងតទល់កម្លាំងពុំបាន ក៏ញាក់
សេះនាំទាហានថយរត់ទៅ ។

ឯហែហ៊ូអៀននឹងខៀវខាប់ បានឮសំឡេងហ៊ោកញ្ជៀវតឹកកង ក៏
នាំទាហានផងធ្ងន់តាមទៅ ដើម្បីនឹងជួយចូចូ លុះទៅដល់មាត់ផ្លូវក្រឡេក
ឃើញស៊ីឡុននាំចូចូចុះពីលើភ្នំមកវិញ ក៏ស្រុតទៅទទួលដោយសេចក្ដី
ត្រេកអរ ឯខៅជូក៏តាមមកពីក្រោយបណ្ដោយគ្នា ចូចូក៏មិម្មានាំទាហាន
ចូលក្នុងបន្ទាយវិញ គិតតែតាំងនៅក្នុងបន្ទាយនោះពេញ ៤០ ថ្ងៃ ហើយ
ចូចូក្លៃនិយាយថា យើងលើកកងទ័ពមកធ្វើការគ្រានេះ ពលទាហានមាន
សេចក្ដីលំបាកណាស់ ឃើញថានឹងវាយយកស្រុកហាន់តុងមិនបានទេ
ត្រូវតែគិតលើកទ័ពត្រឡប់ទៅក្រុងវិញស្រួលជាង កាសៀងឆ្លើយថាលោក
លើកកងទ័ពមកគ្រានេះ នៅមិនទាន់បានច្បាំងតាំងតទល់គ្នាជាមាំមួនសោះ
បានប្រទះគ្នាតែចុងដៃចុងជើង នៅមិនទាន់ឃើញថ្ងៃដ ទាហានស្រុកហាន់
តុងនៅឡើយ ហេតុម្ដេចលោកនឹងចង់លើកកងទ័ពត្រឡប់ទៅវិញ ។

ចូចូនទៀតប្រាប់ថា យើងឃើញទាហានស្រុកហាន់តុងចេញមកតាំងបន្ទាយមាំមួនមិនមានប្រមាទ យើងលើកកងទ័ពត្រឡប់ទៅវិញនោះ ព្រោះចង់ឲ្យឮកិត្តិសព្ទនេះ ទៅដល់សត្រូវខាងនោះ បើឮហើយក៏គង់នឹងប្រមាទមិនខាន បើយើងឃើញបានចំណាប់វេលាណា នឹងបានលើកទាហានទៅព័ទ្ធវាយទំលាយយកបន្ទាយគយអេងប៉េងគួន ក៏នឹងបានដោយងាយ កាសៀងឮដូច្នោះក៏សរសើរថា សេចក្តីត្រិះរិះរបស់វុយកុងនេះប្រពៃណាស់ បីដូចជាទេវតា ។

ចូចូនិយាយនឹងទៀវខាប់នឹងហែហ៊ូអៀនថា ទោសកំហុសរបស់អ្នកទាំងពីរនេះ ជាទម្ងន់គ្រាមុនម្តងហើយ គ្រានេះយើងនឹងឲ្យទៅធ្វើការម្តងទៀតដើម្បីកែខ្លួន បើធ្វើការម្តងទៀតមិនបានការ យើងត្រូវឲ្យប្រហារជីវិតចេញ ទៀវខាប់នឹងហែហ៊ូអៀនក៏ទទួលថា បើលោកនឹងប្រើឲ្យទៅធ្វើការអ្វី ៗ ខ្ញុំបាទក៏សុំទទួលយកអាសាធ្វើការនោះឲ្យបានការ ចូចូថា អ្នកឯងទាំងពីរនាក់ត្រូវនាំទាហានញែកគ្នាព័ទ្ធទៅតាមផ្លូវ តាមក្រោយបន្ទាយអេងប៉េងគួន ខ្លួនយើងនឹងលើកទៅវាយ ទៅវាយពីមុខបន្ទាយ ទៀវខាប់ ហែហ៊ូអៀនទទួលបង្គាប់ហើយក៏ចេញទៅចាត់ការជាស្រេច ។

ឯអៀវស៊ុងក៏ប្រឹក្សានឹងអៀវហៀមថា វេលានេះ ខ្ញុំបាទឮកិត្តិស័ព្ទថា ចូចូប្រុងនឹងលើកទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោវិញ ហើយត្រូវតែលើកទាហានតាមទៅវាយពីក្រោយ មុខជានឹងបែកធ្លាយជាប្រាកដ អៀវហៀមតបថា អ្នកឯងគិតកំរើបដូច្នេះមិនត្រូវទេ ព្រោះចូចូនោះចំណានក្នុងកល

សឹកសង្គ្រាមណាស់ រមែងចេះល្បួងបញ្ឆោតវៀចជាត្រង់ ៗ ជាវៀចដែល មិនជឿតាមកិត្តិស័ព្ទយកជាប្រាកដនោះខ្ញុំមិនយល់ផងទេ អៀវង្សុនមិនស្តាប់ ប្រញាប់ចាត់ចែងទាហានទាំង ៥០០ បន្ទាយ ទើបយកអ្នករក្សាបន្ទាយនោះសុទ្ធតែមនុស្សឈឺទីងពិការ ហើយលើកពលយោធាដែលមាំមួនទៅតាំងពីយាមពីរប្លាយ ក្នុងពេលនោះ មេឃចុះអ័ព្ទងងិតណាស់ ទីងមើលផ្លូវព្រៃក៏មិនឃើញច្បាស់ អៀវង្សុនគិតបារម្ភខ្លាច ក៏បញ្ឈប់ទ័ពតាំងបន្ទាយនៅកណ្តាលផ្លូវ ៗ

ហៃហ៊្វីអៀនលើកទាហានព័ទ្ធពីក្រោយមកក្នុងយប់នោះ មេឃងងឹតណាស់បានឮសំឡេងមនុស្សទីងសេះសន្ធឹកសន្ធាប់ក៏គិតថា ប្រហែលទាហានស្រុកហានតុងមកពួនបង្កប់នៅទីនេះដឹង ក៏បង្គុំលើកទាហានស្រូតទៅឲ្យផុត ឯកងទ័ពហៃហ៊្វីអៀននោះមិនបានលើកតម្រង់ទៅត្រង់ឥយទេ ប៉ុន្តែវង្វេងផ្លូវសំដៅទៅពានលើបន្ទាយអៀវង្សុននោះ លុះទៅដល់បន្ទាយនោះហើយ ទទួលមេឃស្រឡះ អស់ពួកទាហានអៀវង្សុន ដែលនៅក្នុងបន្ទាយស្មានថាអៀវង្សុនលើកទ័ពមកវិញក៏នាំគ្នាបើកទ្វារទទួលហៃហ៊្វីអៀន ក៏លើកទាហានចូលទៅក្នុងបន្ទាយ ដើរត្រួតពិនិត្យមើលគ្រប់បន្ទាយទាំង ៥០០ ឃើញទាហានទាំងនោះសុទ្ធតែមនុស្សឈឺពិការ ហៃហ៊្វីអៀនក៏ឲ្យយកភ្លើងដុតបន្ទាយទាំងអស់នោះឆេះឡើង ពួកទាហានទាំងនោះក៏រត់រួចទៅខ្លះ ក្រៅពីនោះក៏ស្លាប់និងភ្លើងឆេះ ត្រូវប្រហារដោយគ្រឿងសាស្ត្រាវុធស្លាប់ច្រើនណាស់ ៗ

អៀវហៀមឃើញពន្លឺភ្លើងឆេះឡើងគ្រប់បន្ទាយអៀវឌុង ក៏លើកទាហានទៅជួយ ហែហ៊ួអៀនឃើញដូច្នោះ ក៏បរសេះចូលទៅប្រយុទ្ធគ្នានឹងអៀវហៀមបាន ៤ ក្បួន អៀវហៀមទ្រាំកម្លាំងពុំបាន ក៏ញាក់សេះនាំទាហានរត់ចូលបន្ទាយ ទទួលឃើញទៀវខាប់នៅក្នុងបន្ទាយពេញទាំងអស់ អៀវហៀមបកប្រាស់ត្រឡប់នាំទាហានរត់តម្រង់តាមផ្លូវសំដៅទៅស្រុកឡាំគេង ។

ឯអៀវឌុងឃើញពន្លឺភ្លើងឆេះឡើងគ្រប់បន្ទាយដូច្នោះ ក៏ទឹកគិតថាមុខជាកងទ័ពចូចូលបដុតជាពិតប្រាកដហើយ លុះនឹងថយត្រឡប់ទៅក្រោយខ្លាចទ័ពចូចូនឹងលើកដេញតាម ម៉្លោះហើយចេះតែអស់ឯកនៅទីនោះ ទទួលទាហានចូចូលើករាយប្រសប់ខ្ទប់ពេញមកទាំង ៣ ផ្លូវ អៀវឌុងទាល់ប្រចក៏លះបង់ទាហានបរសេះដោះយកតែខ្លួនរត់យកតែឯង ប្រទះនឹងអៀវខាប់ក៏ចូលប្រកាប់គ្នាជាសន្ធឹកណាស់ ទៀវខាប់ក៏លើកលំពែងឡើងចាក់ត្រូវអៀវឌុងធ្លាក់ពីលើសេះស្លាប់ ខណៈនោះភាពោនអៀវឌុងដែលបែករត់ទៅ ក៏យកសេចក្ដីនោះទៅអធិប្បាយប្រាប់ទៀវអ៊ួយគ្រប់ប្រការ ទៀវអ៊ួយឮដូច្នោះក៏ភ័យណាស់ លះចោលបន្ទាយនោះ ហើយនាំទាហានរត់ត្រឡប់ទៅស្រុកហានទុងវិញ ។

ខណៈនោះ ចូចូក៏លើកទាហានទ័ពហ្លួងចូលទៅក្នុងបន្ទាយអេងប៉េងគួន ឯទៀវអ៊ួយបេនោះ កាលរត់ត្រឡប់ទៅក៏ជួបប្រទះនឹងអៀវហៀម

ទើបនាំគ្នាចូលទៅក្នុងស្រុកហានតុង ហើយទៀវអួយនិយាយប្រាប់ទៀវឡូថា ខូចបន្ទាយមុខគយទាំងថ្ងៃស្អាំនោះ ព្រោះអៀវឌុង អៀវហៀមធ្វេសប្រហែសណាស់ ខ្ញុំបាទឃើញសឹកលើសកម្លាំងនឹងទប់ពុំឈ្នះ បានជាលះបង់ចោលបន្ទាយតែចូលមកជំរាបការឲ្យលោកជ្រាប ។

ទៀវឡូឮដូច្នោះក៏ខឹងណាស់ បង្គាប់ឲ្យចាប់ខ្លួនអៀវហៀមទៅសំឡាប់ចេញ អៀវហៀមឆ្លើយដោះសាថា ទោសខ្ញុំបាទនេះខុសណាស់មែនហើយ តែថាមិនទម្ងន់ស្មើនឹងអៀវឌុងទេ ព្រោះដើមហេតុអៀវឌុងលើកទ័ពទៅវាយបន្ទាយចូច ខ្ញុំបាទបាននិយាយហាមឃាត់អៀវឌុងមិនស្តាប់ ចេះតែទទូចលើកទៅទាល់តែសត្រូវកន្ទង់ចូលមកដុតបន្ទាយនេះអស់ ខ្ញុំបាទឃើញពន្លឺភ្លើងឆេះឡើងសន្ធឹកណាស់ ក៏លើកទាហានទៅជួយ លុះថយមកទាហានចូច ក៏លើកគ្នាមកវាយដណ្តើមយកបន្ទាយបាន ដែលទោសខ្ញុំបាទខុសនោះ ស្រេចនៅលោកមេត្តាទុកជីវិតចុះ និងបានធ្វើការកែខ្លួនម្តងទៀត បើក្រោយ ៗ ខ្ញុំបាទលើកទ័ពទៅហើយ បែរជាចាញ់គេឡប់វិញដូចគ្នានេះ សូមឲ្យលោកសម្លាប់ចុះ ទៀវឡូក៏ព្រមអនុញ្ញាតលើកទោស ហើយកេណ្ឌទាហាន ២ម៉ឺន ប្រគល់ឲ្យអៀវហៀមលើកទៅវាយកងទ័ពចូច ដណ្តើមកយកបន្ទាយនោះវិញ អៀវហៀមក៏នាំទាហានទាំង ២ ម៉ឺននោះ លើកចេញទៅដល់ស្រុកឡាំគេង ហើយក៏បោះទ័ពតាំងបន្ទាយនៅទីនោះ ។

(នៅមានត)

# រឿងព្រេងបិន: ការសងសឹកនៃទន្សាយ

La Revanche du lapin (Conte Tibétain)

រឿងព្រេងទីបេ

លោក ក៉យ-ប៊ុត ប្រែពីភាសាបារាំង

---

តាំងពីយូរកាលមកហើយ មានទន្សាយមួយបិតនៅជិតសិង្ហ ។ ពិតមែនតែសត្វទាំងពីរបិតនៅជិតគ្នា តែមានការឈ្លោះគ្នាជានិរន្តរ៍ ។ សិង្ហជាសត្វអំនួត តែងអួតអាងថាខ្លួនមានពលភាពអស្ចារ្យ ។ សិង្ហប្រមាថមើលងាយទន្សាយ ដេរដៀលត្មះទន្សាយរាល់ ៗ ថ្ងៃ ថែមទាំងគំរោញគំរាមទៀត ។ ទន្សាយជញ្ជឹងគិតរិះរក ឧបាយបោកបាយផ្សេង ៗ ដើម្បីសងសឹកឲ្យបាន ។ មានមួយថ្ងៃ ទន្សាយពោលទៅកាន់សិង្ហថា :

« ឱបងសិង្ហ ! ខ្ញុំបានជួបនឹងសត្វមួយមានរូបរាងដូចបងឯង ហើយវាពោលថា : « ឯងស្គាល់អ្នកណាហ៊ានចង់ល្បងនឹងកម្លាំងអញឬទេ ! ចូរឯងហៅវាមក ៗ បើវាមិនមកទេ ត្រូវតែវាស្តាប់បង្គាប់អញ ហើយត្រូវតែវាបម្រើអញ » ។

សិង្ហតបទៅទន្សាយវិញថា : « ឯងមានបាននិយាយប្រាប់វាពីពល-ភាពអញឬទេ ? » ។

ទន្សាយតបទៅវិញថា : « មែនពិត ខ្ញុំបានពណ៌នាពីបងឯង តែត្រូវខ្ញុំបិតនៅស្ងៀមទៅវិញ ព្រោះថា កាលដែលខ្ញុំសរសើរពីពលភាពបងឯង វាទៅជាសើចឡកឡឺយឲ្យខ្ញុំ ហើយវាថាខ្លួនបងឯងមិនដល់

ទាសីភផង» ។

សិង្ហក៏មានចិត្តទោមនស្សឥតឧបមា ហើយស្រែកជាយ៉ាងខ្លាំងថា:

« សត្វនោះវានៅឯណា ? សត្វនោះវាបិតនៅត្រង់ណា ? ប្រាប់ឲ្យឆាប់ ។

ពេលដូច្នោះ សត្វទន្សាយក៏នាំសិង្ហទៅដល់ខាងក្រោយភ្នំមួយ ហើយក៏ចង្អុលបង្ហាញសិង្ហ នូវអណ្តូងមួយ ហើយថា:

« សត្វនុះ វានៅក្នុងអណ្តូងឯនុះ ។

សត្វសិង្ហក៏ចូលទៅជិតអណ្តូង ពេលក្រឡេកទៅក្នុងទឹកអណ្តូងឃើញសត្វមួយមានពលភាពធំក្រៃលែង មានទ្រង់ទ្រាយដូចខ្លួន មានដំណើរប្រហែលខ្លួន ហើយសត្វនោះវាបែរមកមើលខ្លួន មុខកំណាចបំផុតៗ សិង្ហក៏ស្រែកជាយ៉ាងខ្លាំង បច្ចាមិត្តខ្លួន ធ្វើតាមខ្លួនទាំងអស់ ។ សិង្ហខឹងខ្លាំងពាល់តែគេសរសើបឡើងច្រូន សត្វនៅក្នុងអណ្តូងនោះ ក៏មានសភាពដូចគ្នា ។ សត្វសិង្ហបញ្ចេញចង្កូម លោតជើងទៅមុខ ហើយ...ក្រឡេកមើលទៅក្រោមក្នុងអណ្តូង សត្វនោះក៏មានរូបរាងអាកប្បកិរិយាដូចគ្នា ។ សិង្ហមានចិត្តប្រកបដោយទោសៈជាអតិបរមា ទើបលោតទៅក្នុងអណ្តូងនោះ ដើម្បីនឹងខាំសម្លាប់បច្ចាមិត្តខ្លួន (ស្រមោលខ្លួន) ក៏លង់ទឹកស្លាប់នៅទីនោះទៅ ។

ក្នុងរឿងការសងសឹក នៃទន្សាយនេះ អ្នកនិពន្ធ បានចារឹក សុ-

ភាសិត ជាគ្រឿងទូន្មាន មានសេចក្តី ដូចតទៅៈ សិង្ហនោតមានះ តាមទន្រ្ទាយ យល់ស្រមោលកាយអណ្តូងជ្រៅ ស្មានថាបច្ចាមិត្របិតនៅ ទំលុះលោតទៅលង់ទឹកស្លាប់ ។ គ្រូពិចារណាមុនទើងធ្វើកិច្ចការសារ តើកុំប្រញាប់ បើមិនដូច្នោះពុំបានគាប់ ទើងស្លាប់ដូចសិង្ហព្រោះប្រមាទ ។

(នៅមានទៀត)

---

## បម្លើយតបនឹងបំណោទក្នុងទស្សនាវដ្តីកម្ពុជសុរិយា

លេខ ១ ខែមករា ១៩៦៤

### បឥញាក្យ ៧

ពួកសត្វមានក្បាលច្រើនពេញពាស តែសត្វមាសប្លែកពេកក្រៃ កាត់ " រ ,, នៅ " មាស ,, មានតម្លៃ សត្វនេះឯងនៃ ដែលចោទសួរ ។

ភី-ធៀនឡាយ

### សេចក្តីកោតសរសើរ

សូមថ្លែងអំណរគុណ និងកោតសរសើរ យ៉ាងក្រៃលែង ចំពោះប្រាជ្ញាដ៏ភ្លឺថ្លៃ នៃឯកឧត្តម ភី-ធៀនឡាយ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដែលអាចរកឃើញ នូវបំណោទរបស់យើង នៅវេលាដែលឯកឧត្តម បានឃើញនៅទំព័រកម្ពុជសុរិយាភ្លាម ដោយគិតត្រិះរិះដញ្ជឹងយូរឡើយ ។

ដទៃពីឯកឧត្តម ភី ធៀនឡាយ មានយុវជនច្រើនទៀត បានរកឃើញដូចឯកឧត្តមខាងលើដែរ តែចម្លើយមកដល់ក្រោយបន្តិច យើងសូមថ្លែងសេចក្តីសរសើរដ៏យ៉ាងក្រៃលែងណាស់ដែរ ។

ពុទ្ធសាសនបណ្ឌិត្យ សង្ឃឹមថា មិត្រអ្នកអានទាំងឡាយមុខជានឹងយកចិត្តទុកដាក់ក្នុងការដោះស្រាយ បំណោទរបស់យើងតទៅទៀតមិនខាន និងចុះផ្សាយសេចក្តីកោតសរសើរ ដល់អ្នកធ្វើយត្រូវមុនគេជានិរាប ។

ពុទ្ធសាសនបណ្ឌិត្យ

សូមមើលបំណោទទី ២ នៅទំព័រ ១៧០

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

| |
|---|
| ទំនៀមទម្លាប់ នៃខេមរជាតិ<br>ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។<br>ព្រោះខេមរជាតិ ជាជាតិសោភី<br>ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។<br>ប. ព. |

## សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

( នៅឆមាសទី ២ ឆ្នាំ ១៩៦៣ )

នៅឆមាសទី ២ នៃឆ្នាំ ១៩៦៣ គឺពីខែកក្កដា ដល់ខែធ្នូ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានប្រកាសបើកសម័យប្រឡងប្រជែងជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ២ មុខ គឺ :

១– អំពីជឿ ,

២– អំពីរង្វាស់រង្វាល់ ។

ដើម្បីប្រមូលយកឯកសារទាំងពីរមុខនេះ មករក្សាទុក ជាគោលបារីករបស់ជាតិ តទៅអនាគត ។

ក្នុងរវាង ៦ ខែ ក្រោយពេលដែលបានប្រកាសហើយ ក្រុមជំនុំបានទទួលឯកសាររឿងទាំង ២ មុខនេះ ៥៧ រឿង អំពីបេក្ខជនខ្លះ អំពីសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំខ្លះ មានចំនួន ៣៥ រូប ទាំងបព្វជិត

ទាំងគ្រហស្ថ ដែលបានសរសេរមកដាក់ប្រឡង គឺ :

១- លោក ទិន-សុផុន

២- " ពៅ-ឡាច

៣- " គង់-សុន

៤- " រ៉ណ់-គូ

៥- " ឌួង-អ៊ូច

៦- " ស៊ាង-ឡុង

៧- " ឈិន-យ៉ីម

៨- " កែវ-កុល

៩- " ទេព-សៅ

១០- " កង-កែម

១១- " ដោក-ថេង

១២- " គឹម-ម៉ាន

១៣- " កែវ-ហង្ស

១៤- " សេង-គឹមស៊ីង

១៥- " ប្រាក់-ខាត់

១៦- " ម៉ក់-ប៉េង

១៧- " ណុប-ភាង

១៨- " អ៊ុយ-ស៊ុយ

១៩- លោក ទូរ-សុខ

២០- " មាស-សោម

២១- " កែវ-វ៉ែន

២២- " អ៊ុន-ម៉ៅ

២៣- " សុះ-ទូរ

២៤- " គៀត-គី

២៥- " សុខ-ព្រំ

២៦- " ង៉ែត-ហ៊ុន

២៧- " វៀម-យឹម

២៨- ភិក្ខុ ឡុង-ស៊ីសុយ៉ាត់

២៩- " ពេជ្រ-ស៊ុមន៍

៣០- " ចាប-ច័ន្ទ

៣១- " កែវ-ផៃ

៣២- " កែ ប៊ិន

៣៣- " ទួន-ឈន

៣៤- " ប៉ា-ហេង

៣៥- " ទិត្យ-សុខ

ក្រុមជំនុំបានជួបជុំពិនិត្យឯកសារប្រឡងទាំងនោះ ដោយហ្មត់ចត់ទៅ ក៏បានសម្រេចលទ្ធផលពិតប្រាកដដូចតទៅនេះ :

ក- ផ្នែកការរៀងរឿង :

លោក អ៊ុយ-ស៊ុយ នៅឃុំមេព្រីង ស្រុកជើងព្រៃ ខេត្តកំពង់ចាម បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៦០០៛០០ ។

ភិក្ខុ ឡុង-ស៊ីសុយ៉ាត់ លេខាធិការអនុគណ ស្រុកកំចាយមារ គង់នៅវត្តស្មោង ខេត្តព្រៃវែង បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០៛០០ ។

ខ- ផ្នែកការរៀងរង្វាស់រង្វាល់ :

លោក គង់-កែម នៅឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល បានជាប់លេខ ២ ត្រូវបានរង្វាន់ ៨០០៛០០ ។

លោក សារិន-ឡុង គ្រូបង្រៀននៅសាលាព្រៃជ្រាំង ឃុំពានរោង ស្រុកកំចាយមារ ខេត្តព្រៃវែង បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៦០០៛០០ ។

លោក ឌួង-អ៊ួច អតីតមេឃុំ ។ អង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០៛០០ ។

នៅឆមាសទី ២ ជាមួយគ្នានេះ ក្រៅអំពីការប្រឡង ក្រុមជំនុំចង់បានជាបន្ទាន់ នូវឯកសារស្ដីពីរបាំប្រពៃណីរបស់ជាតិ ដូចជារបាំយីកេ រាំស្នែងទន្សោង-រាំកន្ដ្រឹមជាដើម ហើយបានសួរដោយផ្ទាល់ ចំពោះអ្នកចេះដឹងទាំងឡាយ ជាសមាជិកឆ្លើយឆ្លងខ្លះ មិនមែនជាសមាជិកឆ្លើយឆ្លង

ខ្វះ ទាំងបញ្ជិតទាំងគ្រហស្ថ ឲ្យសរសេរឲ្យការណ៍មកក្រុមជំនុំ ។

សំនួរនេះ ក៏បានសម្រេចលទ្ធផលយ៉ាងគាប់ប្រសើរ គឺក្រុមជំនុំបានទទួលឯកសារស្ដីពីរបាំចំនួន ១០ រឿង អំពីអស់លោកចំនួន ១០ រូបគឺ:

| | | | |
|---|---|---|---|
| ១– លោក ម៉ក់-ម៉េង | ៖ | ៦– ភិក្ខុ | ម៉ុ-សាន |
| ២– " កែវ-កុល | ៖ | ៧– " | តាប-ច័ន្ទ |
| ៣– " រៀម-យឹម | ៖ | ៨– លោក | ជឹម-ឈុំ |
| ៤– " កែវ-ហង្ស | ៖ | ៩– " | កែវ-មុំញ |
| ៥– " ទេព-រស់ | ៖ | ១០– " | កួយ-យក់ហូ |

រង្វាន់ដែលត្រូវបានដល់ភិក្ខុជន ដល់សមាជិកផ្ញើយក្ខង និងក្រៅអំពីសមាជិកទាំងនោះ ក្រុមជំនុំបានចែកជូនតាមថ្នាក់រង្វាន់ប្រឡង-រង្វាន់សមាជិក-និងអ្នកធ្វើអំណោយហើយ ។

ក្រុមជំនុំមានសេចក្ដីត្រេកអរក្រៃពេក ចំពោះអស់លោក-អ្នកជាភិក្ខុ-ជន ជាសមាជិកផ្ញើយក្ខង និងក្រៅពីសមាជិកដូចបានរាយនាមខាងលើនេះ ដែលបានយល់នូវឧត្តមប្រយោជន៍នៃការស្រាវជ្រាវ និងការរក្សាទុកនូវអារ្យធម៌របស់ជាតិ ហើយបានសរសេរឯកសារស្ដីអំពីទៀន អំពីរង្វាស់រង្វាល់ និងអំពីរបាំប្រពៃណីរបស់ជាតិ ទៅដាក់ប្រឡង ទៅធ្វើអំណោយដល់ក្រុមជំនុំ ។ សូមប្រកាសជាឧឡារិកទទួលអំណរគុណរបស់លោក-អ្នកទាំងនេះជាកិត្យានុភាព ហើយនៅឆមាសទី ១ ឆ្នាំ ១៩៦៤ នេះ

ក្រុមជំនុំបានបើកសម័យប្រឡងជាថ្មីទៀតស្តីអំពី «ភូមិខ្មែរ» ។ ប្រកាសប្រឡងនេះបានចែកផ្សាយទូទៅហើយ បើអស់លោកអ្នកបានជ្រាបហើយត្រូវការប្រឡងសូមសរសេរតែងទៅឲ្យក្រុមជំនុំ ក្រុមជំនុំនឹងពិនិត្យ ហើយជូនរង្វាន់គេទៅទៀត ។

ក្រុមជំនុំសូមទទួលអំណរគុណនិងសង្ឃឹមទុកជាមុន ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ



ព្រះវិហារវត្តប្រាង្គ ( ឧត្តុង្គ ) ទើបនឹងកសាងថ្មីឡើងវិញ ហើយបញ្ចុះសីមាផ្ទង់ កាលពីថ្ងៃទី ១៩ កុម្ភៈ ១៩៦៤
ក្រោមព្រះអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្ដេចឪ ៗ

ផ្នែកកំណត់ជីវប្រវត្តិការណ៍

# ប្រវត្តិនៃវត្តប្រាង្គ

រៀបរៀងដោយ ព្រះពោធិវង្ស ហួត-តាត

អគ្គាធិការនៃពុទ្ធិកសិក្សា

ហេតុដូចម្តេចបានជាគេហៅថា វត្តប្រាង្គ ? បានជាហៅថាវត្តប្រាង្គ ព្រោះនៅក្នុងនេះមានព្រះប្រាង្គ ១ មានទំហំធំ ជាបូជនីយវត្ថុដ៏ប្រសើរដែលគេបានកសាងទុកមកជាយូរអង្វែងច្រើនសតវត្សរ៍ហើយ ។ រីឯវត្តនេះ គេបានកសាង ក្នុងពេលជាខាងក្រោយនៃព្រះប្រាង្គនោះ ទើបគេយកព្រះប្រាង្គនោះជាឈ្មោះវត្ត ហៅថា វត្តព្រះប្រាង្គ ជួនកាលគេហៅថា វត្តពុទ្ធប្រាង្គ ព្រោះព្រះប្រាង្គនោះ គេតំកល់ព្រះបរមសារីរិកធាតុនៃព្រះពុទ្ធជាម្ចាស់ លុះតមក ដល់បច្ចុប្បន្នកាលនេះ គេហៅថា វត្តប្រាង្គ ៗ តាមនាមនៃព្រះពុទ្ធប្រាង្គនុះឯង ។

វត្តប្រាង្គសព្វថ្ងៃនេះ ឋិតនៅក្នុងឃុំកំពង់ចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ បើធ្វើដំណើរពីក្រុងភ្នំពេញទៅវត្តប្រាង្គនោះ តាមផ្លូវកំពង់ហ្លួង-បាត់ដឹង ចម្ងាយ ៣៩ គីឡូម៉ែត្រ ។

កាលព្រះមហាក្សត្រគង់នៅរាជធានីឧដុង្គមានជ័យនៅឡើយ វត្តប្រាង្គជាវត្តធំស្កុកស្តម្ភណាស់ ទីដីវត្តមានទំហំធំទូលាយ ភាគខាងត្បូងមានព្រំប្រទល់នឹងកំពែងព្រះបរមរាជវាំងស្រះសារតើយុត្ត ភាគខាងជើង

មានព្រំប្រទល់នឹងផ្សារឧដុង្គ ខាងកើតមានព្រំប្រទល់នឹងស្រះកែវ ខាងលិចមានព្រំប្រទល់និងស្លាមក្អោះ ។ វត្តប្រាង្គក្នុងសម័យនោះ មានសភាពរុងរឿងណាស់ ដោយសម្តេចព្រះមហាសង្ឃរាជ ព្រះនាម ទៀង (សុវណ្ណកោសរ:) ទ្រង់គង់នៅជាប្រមុខសង្ឃក្នុងវត្តប្រាង្គនោះ ទាំងព្រះរាជាគណៈឋានានុក្រម ក៏គង់រួមនៅក្នុងវត្តនោះដែរ ។ វត្តប្រាង្គនោះ កាលក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះហរិរក្សរាមា ជាវត្តសម្បូណ៌ដោយគម្ពីរដីកា និងក្បួនច្បាប់ខាងព្រះពុទ្ធសាសនា ទាំងបាលីទាំងសម្រាយដ៏ច្រើន ជាវត្តដែលបានបណ្តុះពូជនៃពួកព្រះសង្ឃជាបណ្ឌិតមានចំនួនច្រើន ជាវត្តព្រះរាជទ្រព្យដូចជាវត្តឧណ្ណាលោម នៅក្រុងភ្នំពេញសព្វថ្ងៃនេះដែរ ។ លុះតមក ក្រោយពេលដែលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមទ្រង់ស្តេចចេញចាករាជធានីឧដុង្គមានជ័យ មកគង់នៅរាជធានីភ្នំពេញ ក្នុងឆ្នាំឆ្លូវសប្តស័ក ព.ស. ២៤០៩ គ.ស.១៨៦៥ សម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង មួយអន្លើដោយព្រះរាជាគណៈឋានានុក្រម ក៏ចេញចាកវត្តប្រាង្គមកគង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្នុងពេលនោះ សម្តេចព្រះមហាសង្ឃរាជ ទ្រង់បាននាំយកមកជាមួយព្រះអង្គ នូវគម្ពីរដីកាក្បួនច្បាប់ជាច្រើន អំពីវត្តប្រាង្គ មកតំកល់ទុកនៅវត្តឧណ្ណាលោម មិនតែប៉ុណ្ណោះ ព្រះរាជាគណៈធំ-តូចទាំងឡាយ ដែលនិមន្តដង្ហែសម្តេចព្រះមហាសង្ឃរាជមកគង់ឯក្រុងភ្នំពេញ ក៏សុទ្ធសឹងតែបាននាំ

យកទូរគម្ពីរដីកាផ្សេងៗ ជាប់ជាមួយមកផង ម្ល៉ោះហើយ នៅទីវត្តប្រាង្គមានសេសសល់គម្ពីរដីកាក្បួនច្បាប់ខ្លះបន្តិចបន្តួច ៗ សភាពរុងរឿងក៏ថយចុះដោយលំដាប់ ប៉ុន្តែមិនមែនថយដល់ថ្នាក់បាត់រូបភាពដើមឡើយ ដោយមានព្រះសង្ឃជាពជាគណៈ ដែលជាបណ្ឌិតគង់នៅជាចៅអធិការតមក មានលោកគ្រូព្រះធម្មឃោសាចារ្យព្រះនាម មាស ជាដើម លោកខំប្រឹងប្រែងឧបត្ថម្ភទប់ទល់ឲ្យនៅមានសេចក្ដីចំរើនរុងរឿងជាលំដាប់ត ៗ មក មិនឲ្យផុត មិនឲ្យដាច់ ។

ចុះវត្តប្រាង្គ គេកសាងពីក្នុងពុទ្ធសករាជប៉ុន្មាន ? អ្នកណាជាអ្នកផ្ដើម កសាងដំបូង ។

បញ្ហានេះ ឥតមានឯកសារអ្វីទីងបញ្ជាក់ឲ្យដឹងច្បាស់លាស់ថាវត្តប្រាង្គ គេកសាងពីកាលណាឡើយ ទាំងអ្នកផ្ដើមកសាងដំបូង ក៏ឥតមានចារឹកអ្វីបញ្ជាក់ឲ្យដឹងបានដែរ ។ តាមព្រះរាជពង្សាវតារប្រទេសកម្ពុជា បានឲ្យពត៌មានមួយអន្លើថា នៅឆ្នាំរកាឯកស័ក ព.ស. ២៣៩៣ គ.ស. ១៨៤៩ ព្រះបាទសម្ដេចព្រះហរិរក្សរាមា (ព្រះអង្គដួង) ទ្រង់មានព្រះបញ្ជាឲ្យកសាងវិហារវត្តពុទ្ធប្រាង្គសព្វថ្ងៃនេះ សេចក្ដីនេះគ្រាន់តែបញ្ជាក់ចំពោះការកសាងវិហារជាឧបោសថាគារតែប៉ុណ្ណោះ មិនមែនបញ្ជាក់ពីការកសាងវត្តទាំងមូលឡើយ ។ តាមការសង្កេតនិងការពិនិត្យមើលដោយល្អិតល្អន់ទៅ ឃើញថា ដែលព្រះបាទសម្ដេចព្រះហរិរក្សរាមា

ទ្រង់មានព្រះបញ្ជាឲ្យកសាងវិហារនោះ មិនមែនកសាងជាដំបូងបំផុតឡើយ គឺរុះរើវិហារចាស់ដែលមានមកយូរយារណាស់ហើយ ។ កសាងពង្រីកឲ្យខ្ពស់ឡើងធំឡើងតែប៉ុណ្ណោះ ព្រោះបានជីកដីត្រង់កន្លែងវិហារឃើញមានជណ្ដើរឥដ្ឋខ្លះ ជញ្ជាំងឥដ្ឋខ្លះ កប់នៅក្នុងដី នាំឲ្យសន្និដ្ឋានបានយ៉ាងជាក់ច្បាស់ថា មានវិហារចាស់ពីបុរាណនៅត្រង់កន្លែងវិហារដែលព្រះបាទសម្ដេចព្រះហរិរក្សរាមា ទ្រង់មានព្រះបញ្ជាឲ្យកសាងនោះ ។

សេចក្ដីខាងលើនេះ អាចនាំឲ្យសន្និដ្ឋានបានថា វត្តប្រាង្គជាវត្តចាស់បុរាណយូរអង្វែងហើយ ។

ម្យ៉ាងទៀត តាមការសង្កេតមើលទីធរណីវត្តតាំងមូល និងកន្លែងស្ថាបនាវិហារដែលជាគោលចារិករបស់វត្ត អាចឲ្យយល់បានថែមទៀតថា វត្តប្រាង្គប្រាកដជាគេកសាងយូរអង្វែងហើយ តាំងពីមុនពេលដែលព្រះបាទសម្ដេចព្រះហរិរក្សរាមា ទ្រង់មានព្រះបញ្ជាឲ្យស្ថាបនាព្រះបរមរាជវាំងស្រះសារពើយុត្តនោះទៅទៀត ដោយមានគ្រឿងសង្កេតដូចតទៅនេះ ៖

១– ទីដីវត្តភាគខាងត្បូង មានព្រំប្រទល់ជាប់នឹងកំពែងព្រះបរមរាជវាំង ស្រះសារពើយុត ។

២– វិហារបិតនៅជិតព្រះបរមរាជវាំង គិតពីកំពែងវិហារទៅទល់នឹងកំពែងព្រះបរមរាជវាំង ប្រមាណជា ២០ ម៉ែត្រប៉ុណ្ណោះ ។

គ្រឿងសង្កេតទាំងពីរយ៉ាងខាងលើនេះ បើគិតពិចារណាទៅ គង់

ឃើញដោយឥតសង្ស័យថា ប្រសិនបើព្រះរាជវាំងកើតមុនវត្ត ទីដីវត្តមុខ
ជាពុំអាចនៅជាប់គ្នានឹងព្រះរាជវាំងបានទេ ចាំងវិហារទៀតសោត ក៏ពុំត្រូវ
អនុញ្ញាតឲ្យកសាងនៅក្បែរព្រះរាជវាំងដែរ ។ តាមការសង្កេតដោយល្អិត
ទៅ ឃើញថា កាលមុនកសាងព្រះរាជវាំង ទីធរណីវត្តប្រាង្គធំទូលាយទៅ
ភាគខាងត្បូង កន្លែងវិហារប្រហែលជានៅចំភាគកណ្ដាលវត្ត ព្រោះតាម
ធម្មតា ការកសាងវត្តនីមួយ ៗ គេតែងតែកសាងវិហារនៅចំភាគ
កណ្ដាល ប៉ុន្តែលុះដល់ពេលដែលកសាងព្រះរាជវាំងស្រះសារពើយុត្តជា
ខាងក្រោយ នៅទីដីភាគខាងត្បូងវត្តប្រាង្គ ក៏កាត់យកទីធរណីវត្ត ១ ភាគ
ទៅ បានជាកន្លែងវិហារបិតនៅកៀកជិតនឹងព្រះរាជវាំង ។

ម្យ៉ាងទៀត បើសង្កេតមើលតាមព្រះរាជពង្សាវតារប្រទេសកម្ពុជា
ឃើញសេចក្ដីកាន់តែច្បាស់លាស់ថែមទៀតថា ព្រះបាទសម្ដេចព្រះហរិ-
រក្សរាមា ទ្រង់សោយរាជសម្បត្តិក្នុង ព.ស. ២៣៩១ គ.ស. ១៨៤៧
ដល់ ព.ស. ២៣៩៣ គ.ស. ១៨៤៩ ទ្រង់មានព្រះរាជបញ្ជាឲ្យកសាង
វិហារវត្តប្រាង្គ លុះដល់ឆ្នាំខាលឆស័ក ព.ស. ២៣៩៨ គ.ស. ១៨៥៤
ទើបទ្រង់មានព្រះរាជបញ្ជាឲ្យកសាងព្រះបរមរាជវាំងស្រះសារពើយុត្ត នៅ
ទីដីខាងកើតឆៀងអគ្នេយ៍នៃព្រះរាជវាំងចាស់ ។ បើគិតតាមកាលបរិច្ឆេទ
ខាងលើនេះ ក៏ឃើញច្បាស់ថា កសាងវិហារវត្តប្រាង្គមុនកសាងព្រះរាជ-
វាំងស្រះសារពើយុត្ត ៥ ឆ្នាំ បើគិតពីពេលដែលកសាងព្រះរាជវាំងនៅ

គ.ស. ១៨៥៤ មកដល់ គ.ស. ១៩៦៣ នេះ ទើបនឹងបាន ១០៩ ឆ្នាំ ប៉ុណ្ណោះ ៗ តាមការពិនិត្យពិចារណាដូចខាងលើនេះ ឃើញច្បាស់ថាវត្តប្រាង្គ គេកសាងមុនព្រះបរមកដាំងស្រះសារពើយុត្ត យូរវង់ឆ្ងាយណាស់ៗ

## សេចក្តីចំរើនរុងរឿងនៃវត្តប្រាង្គពីអតីតកាល

វត្តប្រាង្គ តាមការពិនិត្យមើលដោយសព្វគ្រប់ទៅ ឃើញថាកើតមានឡើងយូរអង្វែងហើយ ប៉ុន្តែក្នុងរជ្ជកាលនៃព្រះមហាក្សត្រមុនៗ វត្តប្រាង្គពុំប្រាកដជាមានសេចក្តីចំរើនរុងរឿងយ៉ាងណាៗឡើយ ដោយពុំមានឯកសារអ្វីនឹងបញ្ជាក់ឲ្យច្បាស់លាស់ ៗ ទើបតែក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះហរិរក្សរាមា (ព្រះអង្គដួង) ឃើញថា វត្តនេះមានសេចក្តីចំរើនរុងរឿងមានកិត្តិនាមដ៏ប្រសើរ ដោយមានពតិមានបញ្ជាក់ឲ្យដឹងក្នុងព្រះរាជពង្សាវតារប្រទេសកម្ពុជាថា ៖

១– សម្តេចព្រះសង្ឃរាជ ព្រះនាម ទៀង ទ្រង់ជាប្រមុខសង្ឃនៅក្នុងព្រះរាជអាណាចក្រកម្ពុជា ទ្រង់គង់នៅវត្តប្រាង្គ ហើយទ្រង់ជាចៅអធិការនៃវត្តប្រាង្គផង ៗ

២– ព្រះរាជាគណៈឋានានុក្រម ជាអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាក៏គង់នៅក្នុងវត្តប្រាង្គនោះដោយច្រើន ៗ

៣– ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមា ទ្រង់ចំបួសព្រះ

រាជឱរសពីរព្រះអង្គគឺ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ កាលទ្រង់នៅជាព្រះរាជកុមារនៅឡើយ ឱ្យចូលកាន់បព្វជ្ជាជាសាមណេរក្នុងសំណាក់លោកគ្រូព្រះមហាព្រហ្មមុនី (ម៉ា) នៅក្នុងវត្តប្រាង្គ និងព្រះអង្គម្ចាស់ស៊ីវត្ថា កាលដែលទ្រង់នៅជាព្រះរាជកុមារឱ្យចូលកាន់បព្វជ្ជាជាសាមណេរក្នុងសំណាក់សម្តេចព្រះមហាសង្ឃរាជ ទៀង កាលទ្រង់ឋិតនៅក្នុងតំណែងជាព្រះមហាវិមលធម្ម ក្នុងវត្តប្រាង្គជាមួយគ្នា ។

៤– ព្រះបាទសម្តេចព្រះហរិរក្សរាមា ទ្រង់បានទុកវត្តប្រាង្គជាវត្តព្រះរាជទ្រព្យ ទ្រង់ជួយឧបត្ថម្ភវត្តប្រាង្គឱ្យបានថ្កុំថ្កើងរុងរឿងមានការកសាងវិហារជាដើម រហូតដល់ផុតរជ្ជកាលរបស់ព្រះអង្គ (គ.ស.១៨៤៧–១៨៦០ ។

(នៅមានត)

មនុស្សស្រវឹងស្រា មនុស្សឆ្កួត មនុស្សកាចកំពេល មនុស្សអស់កម្លាំង មនុស្សអត់ឃ្លាន មនុស្សល្មោភ មនុស្សខ្លាច មនុស្សរហ័សក្លូត និងមនុស្សបរិភោគកាម មនុស្សទាំងអស់នេះ មិនចេះធម៌ទេ ៖

ហិតោបទេស

# អំពីព្រះនាមព្រះតេជព្រះគុណ

## ដែលបានទទួលសញ្ញាប័ត្រតាំង
## ជាចៅអធិការនិងគ្រូសូត្រក្នុងវត្តនានា
## ក្នុងព្រះរាជអាណាចក្រ

(ត)

១២– ព្រះតេជព្រះគុណ សុក-អូន នាមឆាយាពុទ្ធបញ្ញោ អាយុ ៥៤ ឆ្នាំ វស្សា ៣២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តពោធិកមា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣.៤០៧ ចុះថ្ងៃទី ១៩-៩-៦២ ។

១៣– ព្រះតេជគុណ ឃាន-ឃី នាមឆាយាធម្មសរ កើតពី គ.ស. ១៩២២ អាយុ ៤០ ឆ្នាំ វស្សា ២០ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តពោធិកមា ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣.៤០៨ ចុះថ្ងៃទី ១៩-៩-៦២ ។

១៤– ព្រះតេជព្រះគុណ គុប-ជាន់ នាមឆាយាសទ្ធម្មចៅតិបញ្ញោ កើតឆ្នាំមមែ អាយុ ៤៤ ឆ្នាំ វស្សា ២៣ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តប្រាសាទ ឃុំដូង ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣.៤០៩ ចុះថ្ងៃ ១០-១០-៦២ ។

១៥– ព្រះតេជព្រះគុណ ទូច-សុខ នាមឆាយាកន្តធម្មោ កើត

ឆ្នាំថោះ អាយុ ៦០ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តប្រាសាទ ឃុំដូង ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣.៤១០ ចុះថ្ងៃទី ១០-១០-៦២ ។

១៦- ព្រះតេជព្រះគុណ ប៉ែន-ឡាញ់ នាមឆាយាអរុណវតី កើតឆ្នាំមមី អាយុ ២១ ឆ្នាំ វស្សា ១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តប្រាសាទ ឃុំដូង ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣៤១១ ចុះថ្ងៃទី ១០-១០-៦២ ។

១៧- ព្រះតេជព្រះគុណ សៅ-ពាំង នាមឆាយាមង្គលជោតិ កើតពី គ.ស. ១៩២៦ អាយុ ៣៦ ឆ្នាំ វស្សា ១៦ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តពាក់ង ឃុំកប ស្រុកពាក់ង ខេត្តព្រៃវែង លេខសញ្ញា-បត្រ ៣៤១២ ចុះថ្ងៃទី ១៩.១៩-៦២ ។

១៨- ព្រះតេជព្រះគុណ ឃី-ស៊ុមលាង នាមឆាយាទន្តជោតិ កើតពីគ.ស. ១៨៩៧ អាយុ ៦៥ ឆ្នាំ វស្សា ៤៥ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តសំប៉ាន ឃុំ ស្រុក កោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៣ ចុះថ្ងៃទី ២២-១០-៦២ ។

១៩- ព្រះតេជព្រះគុណ ញិល-ជីវ នាមឆាយាតេជវុឌ្ឍោកើតឆ្នាំមមែ អាយុ ៣២ ឆ្នាំ វស្សា ១៣ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តសំ-ប៉ាន ឃុំ ស្រុក កោះធំខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៤ ចុះថ្ងៃទី

២២-១០-៦២ ។

២០- ព្រះតេជព្រះគុណ ទឹម-ដុល នាមឆាយាបញ្ញាបជ្ជោតោ កើតពី គ.ស ១៩៣៤ អាយុ ២៨ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្តស់ប៉ាន ឃុំ ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៥ ចុះថ្ងៃទី ២២-១០-៦២ ។

២១- ព្រះតេជព្រះគុណ តាន់-ស្វាយ នាមឆាយាទន្ធគ្គោ កើតឆ្នាំមមី អាយុ ៦៩ ឆ្នាំ វស្សា ៤៤ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តតាំងនោម ឃុំប្រទះឡាង ស្រុកកំពេញ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៦ ចុះថ្ងៃទី ២២-១០-៦២ ។

២២- ព្រះតេជព្រះគុណ ឡោ-អ៊ុច នាមឆាយាអគ្គឡោ កើតឆ្នាំរកា អាយុ ៣០ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តព្រៃស្តី ឃុំពោមចៅ ស្រុកកំពេញ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៤១៧ ចុះថ្ងៃទី ២២-១០-៦២ ។

២៣- ព្រះតេជព្រះគុណ កែ-ស៊ុន នាមឆាយាសុវណ្ណបញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣៤ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តជុំគ្រៀល ឃុំក្បាលរមាស ស្រុក ខេត្តកំពត លេខសញ្ញាបត្រ ៣៤១៨ ចុះថ្ងៃទី ២៩-១០-៦២ ។

២៤- ព្រះតេជព្រះគុណ វ៉ែន-សួន នាមឆាយាចន្ទប្បជ្ជោតោ

កើតឆ្នាំមមី អាយុ ៤៥ ឆ្នាំ វស្សា ២៥ បានទទួលតែងតាំងជាចៅអធិការគណវត្តពូនភ្នំថ្ម ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣៤១៩ ចុះថ្ងៃទី ២២-១១-៦២ ។

ព្រះតេជព្រះគុណ អ៊ឹង-សាវឿន នាមឆាយា ទត្តវប្បញ្ញោ កើតពី គ.ស ១៩៣១ អាយុ ៣១ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ គណវត្តពូនភ្នំថ្ម ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាបត្រ ៣៤២០ ចុះថ្ងៃទី ២២-១១-៦២ ។

២៦- ព្រះតេជព្រះគុណ ឌី-ប៊ុនធុ នាមឆាយា ញាណគុត្តោ កើតឆ្នាំមមែ អាយុ៣២ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាចៅអធិការគណវត្តវៀមុនីន ឃុំកំកុន ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង លេខសញ្ញាបត្រ ៣៥១៩ ចុះថ្ងៃទី ១២-៦-៦៣ ។

២៧- ព្រះតេជព្រះគុណ ឌី.ស៊ុ នាមឆាយា បធានវឌ្ឍោ កើតឆ្នាំរោង អាយុ ៣៥ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាចៅអធិការគណវត្តបរមជាសុក ឃុំកំកុន ស្រុកខេត្តដដែល លេខសញ្ញាបត្រ ៣៥២០ ចុះថ្ងៃទី ១២-៦-៦៣ ។

២៨-ព្រះតេជព្រះគុណ ស៊ុត.ទាំមី នាមឆាយា ចិត្តហង្សោ កើតឆ្នាំ ច អាយុ ៤១ ឆ្នាំ វស្សា ២១ បានទទួលតែងតាំងជាចៅអធិការគណវត្តឫស្សីកែវ ឃុំ ស្រុក ខេត្តស្ទឹងត្រែង លេខសញ្ញាបត្រ ៣៥២១ ចុះថ្ងៃទី

១២.៦.៦៣ ។

២៩- ព្រះតេជព្រះគុណ ង៉ួន-ម៉ា នាមឆាយាជោតិកោ កើតឆ្នាំជូត អាយុ ៥៣ ឆ្នាំ វស្សា ២៩ បានទទួលតែងតាំងជាចៅអធិការកុដិវត្តគោនសាំង ឃុំកោះសម្លាយ ស្រុក ខេត្តដវែល លេខសញ្ញាបត្រ ៣៥២២ ចុះថ្ងៃទី ១២-៦-៦៣ ។

៣០- ព្រះតេជព្រះគុណ ផែង-ហួត នាមឆាយាឥន្ទប្បញ្ញោ កើតពីគ.ស. ១៩១២ អាយុ ៥១ ឆ្នាំ វស្សា ២៨ បានទទួលតែងតាំងជាចៅអធិការកុដិវត្តប្រធាន ឃុំឆក់ឈើនាង ស្រុកភ្នំពេញ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៥២៣ ចុះថ្ងៃទី ២៥-៦-៦៣ ។

៣១- ព្រះតេជព្រះគុណ ណុប-សួង នាមឆាយាឥន្ទប្បញ្ញោ កើតពីគ ស. ១៩០៨ អាយុ ៥៥ ឆ្នាំ វស្សា ១៦ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្តស្រុក ខេត្តដវែល លេខសញ្ញាបត្រ ៣៥២៤ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣២- ព្រះតេជព្រះគុណ ចៀម-ពុំ នាមឆាយានាគប្បញ្ញោ កើតពីគ.ស. ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្ត ឃុំ ស្រុក ខេត្តដវែល លេខសញ្ញាបត្រ ៣៥២៥ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៣- ព្រះតេជព្រះគុណ អៀ-សំអាន នាមឆាយាឥន្ទគុត្តោ កើត

ឆ្នាំច អាយុ ៤១ ឆ្នាំ វស្សា ២០ បានទទួលតែងតាំងជាចៅអធិការកុដិវត្ត គោកបញ្ចាន់ ឃុំចោមចៅ ស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣៩២៦ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៤- ព្រះតេជព្រះគុណ លុយ-ខុន នាមធាយាធម្មរំពៃ កើតពីគ.ស. ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្ត ឃុំស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣៩២៧ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៥- ព្រះតេជព្រះគុណ អ៊ូ សម នាមធាយាបន្ទុគ្គេរ កើតពីគ.ស. ១៩០៣ អាយុ ៦១ ឆ្នាំ វស្សា ៣៣ បានទទួលតែងតាំងជាចៅអធិការ កុដិវត្តពលសណ្តែក ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៩២៨ ចុះថ្ងៃទី ២៥.៦.៦៣ ។

៣៦- ព្រះតេជព្រះគុណ ចិន-សុខ នាមធាយាសុវណ្ណជោតិ កើតពីគ.ស. ១៩០៨ អាយុ ៥៥ ឆ្នាំវស្សា ៣៣ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្ត ឃុំស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣៩២៩ ចុះថ្ងៃទី ២៥.៦.៦៣ ។

(នៅមានត)

# ដំណឹងអំពីពុទ្ធសាសនបណ្ឌិត្យ

ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមជូនដំណឹងដល់សាធារណជនថា សៀវភៅប្រជុំរឿងព្រេងខ្មែរ « ភាគ ៥ » បានបោះពុម្ពចេញផ្សាយហើយ ។ សៀវភៅនេះ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ បានស្រាវជ្រាវជ្រើសរើសយកឯកសាររឿងព្រេង ដែលទាក់ទងដោយប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ នៃប្រទេសកម្ពុជា ហើយដែលជារឿងនៅមានអាថ៌កំបាំងចំពោះអ្នកសិក្សានៅឡើយ ដូចជារឿងប្រាសាទបុកណោ-ទីក្រុងចាស់ ៗ -ភ្នំ- និងបឹងបួជាច្រើន នៅកម្ពុជាណាចក្រយើង មានរឿងភ្នំបាយ៉ង់កោរ -ភ្នំសំពៅ -ភ្នំព្រះរាជទ្រព្យ - ភ្នំប្រុសភ្នំស្រី – ក្រុងឧត្តុង្គ – ក្រុងភ្នំពេញ – ប្រាសាទតាព្រហ្ម – ប្រាសាទព្រហ្មគិល - និងប្រាសាទនាងខ្មៅជាដើម ដែលសុទ្ធតែជារឿងព្រេងយ៉ាងច្បាស់លាស់ មានអត្ថរស គួរជាទីចាប់អារម្មណ៍ ហើយជារឿងអាចផ្តល់នូវសារប្រយោជន៍ដល់អស់លោកអ្នកអានយ៉ាងវិសេសវិសាល ។

សៀវភៅប្រជុំរឿងព្រេងខ្មែរ « ភាគ៥ » បោះពុម្ពគ្រាដំបូងនេះ មានចំនួនតិចណាស់ ដូច្នេះ សូមលោកអ្នក អញ្ជើញជាវដោយរួសរាន់ នៅក្រុមពុទ្ធសាសនបណ្ឌិត្យ តម្លៃ ២៥៛០០ មួយក្បាល ។